D.L. 23-8-52

Mit salapali

# មិត្តសាលាបាលី

ទស្សនាវដ្ដីផ្សាយពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ

ចេញរាល់ខែ

INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL



ឆ្នាំទី ៣ មករា កុម្ភៈ មីនា លេខ ១-២-៣

ព.ស. ២៤៩៥ — គ.ស. ១៩៥២

# ទស្សនាវដ្ដីអនុមាស

## ផ្សាយព្រះពុទ្ធសាសនា នឹង អក្សរសាស្ត្រខ្មែរ


បណ្ណាធិការ ជាប-ពិន

ទីសំណាក់ការ លេខ ៣៥ អា. វិថីឧកញ៉ាពេជ្រ ក្រុងភ្នំពេញ


## បញ្ជីរឿង


| បញ្ជីរឿង | | ទំព័រ |
|---|---|---|
| សេចក្ដីជូនដំណឹងទស្សនាវដ្ដីមិត្តសាលាបាលី | | ១ |
| វិចារណកថា | | ៥ |
| គោលសំខាន់មួយបទនៃព្រះពុទ្ធសាសនា... | ជាប—ពិន | ៨ |
| ការដឹងប្រមាណ | ព្រះមហា ប៊ុង—ប៉ម | ២៣ |
| ឱវាទ ១៧ បទ | សម្ដេចព្រះសង្ឃនាយក ជួន-ណាត. | ២៤ |
| អបរិហានីយធម៌ | ព្រះទេពមុនី យូ—ប៊ុណ្ណ | ២៦ |
| សុភាសិត ៥០ បទ | ប៊ូ—ប៉ូ | ៣០ |
| បដិភាណរបស់ព្រះពុទ្ធ | ស៊ិន—ហ៊ាន | ៣៦ |
| គតិធម៌ធៀបគតិលោក | ជាប—ពិន | ៤៤ |
| អាយុ | តែ—ង៉ួន | ៤៧ |
| អក្សរសាស្ត្រ | ភ៉ាយ—ប៊ុក | ៥៥ |
| ទេមរវេយ្យាករណ៍ | ព្រះមហា ពេជ្រ—ម៉ាន់ | ៦២ |
| អក្សរអង្គុលីលេខ | អៀង—ថ្លាង | ៧៣ |
| ដីវលេខ | សៀង—ឱន | ៧៩ |
| ឯកសារស្ដីពីប្រវត្តិសាស្ត្រនៃកម្ពុជរដ្ឋ | ភ៉ាយ—ប៊ុក | ៩១ |
| រឿងសម័យថ្មី | ភ៉ាយ—ល្មុត | ១០០ |
| រឿងសកុន្តលា | ហេង—យ៉ាន់ | ១០៣ |
| បញ្ចតន្ត្រៈ | ភិក្ខុ ប៉ាង—ខាត់ | ១០៨ |
| មហាសន្និបាត | | ១១៤ |
| ពិធីបុណ្យព្រហ្មទាន | | ១១៧ |

# សេចក្ដីផ្ដួចផ្ដើម

## ទស្សនាវដ្ដី មិត្តសាលាបាលី ផ្សាយចេញពី

## សមាគមមិត្តសាលាបាលី កម្ពុជរដ្ឋ

ឆ្នាំ ១៩៥២

---

បងប្អូនរួមជាតិ · រួមសាសនាទាំងឡាយ !

ខ្មែរយើង មានព្រះពុទ្ធសាសនា ជាសាសនាសម្រាប់រដ្ឋ សម្រាប់ជាតិ, មានភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ ជាគោលចារិករបស់រដ្ឋរបស់ជាតិ ។ គោលចារិក គឺព្រះពុទ្ធសាសនា និងអក្សរសាស្ត្រខ្មែរនេះឯង បានប្រតិស្ឋានទុកនូវជំហរដ៏រឹងប៉ឹងឲ្យប្រជាជនជាតិខ្មែរអាស្រ័យ ដើម្បីសេចក្ដីចម្រើន និងសេចក្ដីថ្លៃថ្នូរ ចំពោះសង្គមខ្មែរ តាំងពីព្រេងនាយមកហើយ ។

ការលើកដំកើងព្រះពុទ្ធសាសនា និងអក្សរសាស្ត្រខ្មែរ ទុកជាការលើកដំកើងឥទ្ធិពលខ្មែរ ។

សមាគមមិត្តសាលាបាលី មានបំណងនឹងលើកដំកើងឥទ្ធិពលខ្មែរឲ្យខ្ពង់ខ្ពស់ បានជាបង្កើតឲ្យមានទស្សនាវដ្ដី មិត្តសាលាបាលី នេះឡើង ។

ទស្សនាវដ្ដី មិត្តសាលាបាលី ឆ្នាំ១៩៥២ នេះ នឹងផ្សាយចេញនូវអត្ថរសនៃព្រះពុទ្ធសាសនា និងវិជ្ជាតិកនិក គឺវិជ្ជាដ៏ផ្រាលផ្រៅនៃ

អក្សរសាស្ត្រខ្មែរ ព្រមទាំងគតិធម៌ គតិលោក នឹងគតិបុរាណ គតិសម័យ ជាគ្រឿងប្រដាប់ សម្រាប់បណ្តុះវិជ្ជាខាងព្រះពុទ្ធសាសនា នឹងអក្សរសាស្ត្រខ្មែរ ជាប្រយោជន៍សាធារណៈ ។

ដូច្នេះ បងប្អូនរួមជាតិ រួមសាសនាទាំងឡាយ ដែលបានដំកល់ខ្លួននៅក្នុងឧត្តមគតិខាងលើនេះ សូមជាវទស្សនាវដ្ដី មិត្តសាលាបាលី ទុកសម្រាប់អាន ដើម្បីប្រយោជន៍ខ្លួន ប្រយោជន៍សមាគម ប្រយោជន៍ប្រទេសជាតិ នឹងប្រយោជន៍ព្រះពុទ្ធសាសនា ។

ទស្សនាវដ្ដី មិត្តសាលាបាលី នឹងផ្សាយបញ្ចេញនូវអត្ថបទផ្សេង ៗ ដូចរាយមាតិកាតទៅនេះ :

១ – ផ្នែកវិចារណកថា

២ – ផ្នែកព្រះពុទ្ធសាសនា

ក) អធិប្បាយបញ្ជាក់ពាក្យមួយម៉ាត់ៗ ដូចពាក្យថា វិជ្ជា អវិជ្ជា បុណ្យ បាប មគ្គ ផល និព្វាន ជាដើម

ខ) គតិធម៌ ធៀប គតិលោក

គ) សេចក្តីពិសេសនៃព្រះពុទ្ធសាសនា

ឃ) បកិណ្ណកបរិយាយ

៣ – ផ្នែកអក្សរសាស្ត្រ

ក) ពន្យល់របៀបវេយ្យាករណ៍ .

ខ) ពន្យល់របៀបតែងសេចក្ដី

គ) ពន្យល់ពាក្យមួយម៉ាត់ ៗ នឹងអត្ថផ្សេង ៗ

ឃ) ពន្យល់ពាក្យវប្បធម៌ នឹងពាក្យដែលត្រូវបញ្ជូនទៅឲ្យគណៈកម្មការវប្បធម៌ប្រែ ព្រមទាំងអធិប្បាយ

ង) របៀបអក្សរអង្គុលីលេខ

ច) របៀបអក្សរជវលេខ

ឆ) បរិវត្តនៃអក្សរសាស្ត្រខ្មែរ នឹងប្រវត្តិព្រមទាំងរូបភាពនៃអ្នកប្រាជ្ញខាងអក្សរសាស្ត្រខ្មែរ

ជ) របៀបតែងកាព្យឃ្លោង

ឈ) គតិលោក

ញ) គតិបុរាណ

ដ) គតិសម័យ

ឋ) ភាសិតផ្សេង ៗ

ឌ) និទានផ្សេង ៗ

ឍ) កំណត់នឹងប្រវត្តិការណ៍

## ដំឡៃជាវទស្សនាវដ្ដី

ទស្សនាវដ្ដី មិត្តសាលាបាលី ឆ្នាំ ១៩៥២នេះ នឹងផ្សាយចេញរាល់ខែ ១ ឆ្នាំ ឬ ១ ចប់ មាន ១២ ក្បាល, ១ ក្បាលមាន ៤០ ទំព័រ សៀវភៅខ្នាតធំប៉ុនសៀវភៅនេះ ៗ

គណៈកម្មការទស្សនាវដ្ដី មិត្តសាលាបាលី ចង់ដឹងចំនួនលោក-អ្នកត្រូវការជាវប្រចាំឆ្នាំនូវទស្សនាវដ្ដីនេះថា មានប៉ុន្មានចប់ក្នុងពេលឆាប់ៗ ដើម្បីប្រមូលនាមលោក - អ្នកជាវទៅគណនាឲ្យដឹងចំនួនអ្នកត្រូវការលើកដំកើងឥទ្ធិពលខ្មែរ ។

ដូច្នេះ គណៈកម្មការ សូមធ្នូៈអំពីសំណាក់ព្រះសង្ឃទាំងអស់ លោកអ្នក បើត្រូវការជាវទស្សនាវដ្ដី មិត្តសាលាបាលី ឆ្នាំ ១៩៥៦ សូមចុះនាមជាវតាមដំរៀបដូចខាងក្រោម :-

ដំឡៃជាវមាន ២ ប្រភេទ :

ក) ក្នុងកម្ពុជរដ្ឋ ថ្លៃ ១២០រ.០០

ខ) ក្រៅកម្ពុជរដ្ឋ ថ្លៃ ១៥០រ.០០

ក្នុងកម្ពុជរដ្ឋ : សូមលោក-អ្នកត្រូវការជាវដោយបង់ប្រាក់ជាមុនគ្រប់ចំនួនតាមប្រភេទ ( ក ) នៅមន្ទីរសំណាក់ការ សមាគមមិត្ត-សាលាបាលី ផ្ទះលេខ ៣៥ អា វិថីឧកញ៉ាពេជ្រ ភ្នំពេញ ។

ក្រៅកម្ពុជរដ្ឋ: សូមផ្ញើនាមត្រកូលនាមខ្លួន ទាំងឈ្មោះទីលំនៅ ព្រមទាំងបង់ប្រាក់ជាមុនគ្រប់ចំនួនតាមប្រភេទ (ខ) ដោយផ្លូវអាណត្តិប្រៃសណីយ៍ទៅលោក អ៊ុច-រស់ អគ្គហេរញ្ញិក ផ្ទះលេខ ៣៥ អា. វិថីឧកញ៉ាពេជ្រ ភ្នំពេញ (M. Ouch-Ros Trésorier Général 35-a Rue Oknha Peich Phnom-Penh)

# វិចារណកថា

ការរៀបចំស្រុកទេស ជាទីនៅរបស់មនុស្សឲ្យមានគ្រឹះស្ថាន គ្រឿងប្រដាប់សម្រាប់ប្រើប្រាស់ សម្លៀកបំពាក់តាក់តែងកាយ ឲ្យសប្បាយឲ្យល្អមើល ឲ្យមានអាហារសម្រាប់បរិភោគ មានថ្នល់ ស្ពាន យានជំនិះសម្រាប់ទៅមកដោយស្រួល ឬ តាក់តែងឲ្យមានសាលាបង្រៀនចំណេះវិជ្ជា នឹងសិល្បសាស្ត្រគ្រប់យ៉ាង ។ល។ ឲ្យទាន់សម័យលោកនិយម ហៅថា តាក់តែងផ្លូវលោក ។

ការរៀបចំស្រុកទេស ឲ្យមានក្បួនច្បាប់ គម្ពីរដីកា ឬ តាក់តែងឲ្យមានសាលាបង្រៀនធម៌អាថ៌ មានបណ្ណាល័យ ទំនុកបម្រុងអ្នកប្រាជ្ញខាងផ្លូវសាសនា ឲ្យរៀនធម៌អាថ៌ ក្បួនច្បាប់ ផ្សាយចេញទៅប្រដៅប្រដាជន ឲ្យដឹងបាបបុណ្យគុណទោស ខុសត្រូវ អាក្រក់ល្អ ឲ្យលះបង់រាគៈ ទោសៈ មោហៈ ។ល។ ហៅថា តាក់តែងផ្លូវធម៌ ។

ផ្លូវលោកនឹងផ្លូវធម៌ជាគូគ្នា លះបង់គ្នាពុំបានដាច់ខាត ដូចព្រះអាទិត្យនឹងព្រះចន្ទ ។

ប្រទេសនីមួយៗ ឬ លោកទាំងមូល លុះតែមានទាំងផ្លូវលោកផ្លូវធម៌ស្មើភាគគ្នាជាលំដាប់សព្វកាល ទើបបានរុងរឿងហើយសុខសប្បាយជានិរន្តរ៍ ។ បើមានតែផ្លូវលោកមួយចំណែក មិនមានផ្លូវធម៌សោះ លោកនឹងឆេះជាភ្លើង ដោយហេតុមនុស្សមានរាគៈ ទោសៈ មោហៈ ខ្លាំងប្រណាំងប្រជែងគ្នាហួសហេតុពេក មិនដឹងបាបបុណ្យ គុណទោសសោះ,

បើមានតែផ្លូវធម៌មួយចំណែក មិនមានផ្លូវលោកសោះ លោកនឹងក្លាយទៅជាព្រៃ ដោយហេតុមនុស្សមិនយកចិត្តទុកដាក់រៀបចំស្រុកទេសសោះឡើយ ។

ហេតុដូច្នេះ បានជាប្រមុខនៃការប្រទេសទាំងឡាយ ក្នុងលោកតែងតាក់តែងសាងទាំងផ្លូវលោកផ្លូវធម៌ ឲ្យមានស្មើភាគទាំងពីរផ្លូវ ដើម្បីឲ្យពលរដ្ឋធ្វើដំណើរទាំងផ្លូវកាយផ្លូវចិត្ត បានចំរុងចំរើន ហើយសុខសប្បាយជានិច្ច ។

ព្រះពុទ្ធទាំងឡាយដែលទ្រង់បានត្រាស់ហើយក្នុងអតីតក្តី នឹងបានត្រាស់ទៅក្នុងអនាគតក្តី តែងទ្រង់ធ្វើពុទ្ធកិច្ចឲ្យសម្រេចទាំងផ្លូវលោកផ្លូវធម៌គ្រប់ព្រះអង្គ ដើម្បីប្រោសស្រង់សត្វលោកឲ្យបានបរមសុខ ។ ព្រះសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើង ដែលទ្រង់ប្រតិស្ឋានព្រះពុទ្ធសាសនាទុកក្នុងបច្ចុប្បន្ននេះ ទោះបីធម៌វិន័យមានច្រើនដល់ ៨៤.០០០ធម្មក្ខន្ធ ក៏គង់រួមចុះក្នុងផ្លូវទាំងពីរ គឺផ្លូវលោក ១ ផ្លូវធម៌ ១ ឬ រួមចុះក្នុងប្រយោជន៍ ៣ ប្រការ គឺ ប្រយោជន៍លោកនេះ ១ ប្រយោជន៍លោកខាងមុខ ១ ប្រយោជន៍ខ្ពស់ផុតលោក គឺព្រះនិព្វាន ១, សូម្បីប្រយោជន៍ ៣ ប្រការនោះសោត ក៏រួមចុះក្នុងផ្លូវលោកផ្លូវធម៌ដែរ គឺដែលទ្រង់ប្រដៅឲ្យខំរកប្រយោជន៍ឥធលោកនឹងបរលោក ក៏គឺទ្រង់ប្រដៅផ្លូវលោក, ដែលទ្រង់ប្រដៅឲ្យខំរកប្រយោជន៍ខ្ពស់ផុតលោក ក៏គឺទ្រង់ប្រដៅផ្លូវធម៌នោះឯង ។ សូម្បីទ្រង់ប្រដៅអំពីធុរៈ ២ ប្រការ គឺគន្ថធុរៈ ( ការសិក្សាតាម

គម្ពីរ) ១ វិបស្សនាធុរៈ (ការចំរើនភាវនា) ១ ក៏រួមចុះក្នុងផ្លូវលោក ផ្លូវធម៌ដែរ គឺចំណែកគន្ថធុរៈ ជាធុរៈលាយទាំងផ្លូវលោកផ្លូវធម៌, វិបស្ស-នាធុរៈ ជាធុរៈសុទ្ធតែផ្លូវធម៌មួយយ៉ាង ។

ក្នុងផ្នែកទស្សនាវដ្តីមិត្តសាលាបាលី ដែលមានទំព័រក្រាស់យ៉ាងច្រើនខាងមុខនេះ សឹងមានចុះផ្សាយទាំងពីរផ្លូវ គឺទំព័រដើមៗ ចុះផ្សាយនូវអត្ថរសនៃព្រះពុទ្ធសាសនាដែលមានព្រមទាំងផ្លូវលោកផ្លូវធម៌, ទំព័រចុងៗ ចុះផ្សាយនូវអត្ថរសនៃអក្សរសាស្ត្រខ្មែរ ដែលទាក់ទងដោយផ្លូវលោក ជាគតិបុរាណ គតិសម័យ ។ល។

សមាគមមិត្តសាលាបាលី ប្រាថ្នានឹងញ៉ាំងពន្លឺនៃគតិធម៌ គតិលោក ឲ្យភ្លឺថែងចាំងពាសពេញទាំងកម្ពុជរដ្ឋ ទើបបង្កើតឲ្យមានទស្សនាវដ្តីមិត្តសាលាបាលីនេះឡើង ដើម្បីលើកដំកើងនូវឥទ្ធិពលនៃព្រះពុទ្ធសាសនា នឹងអក្សរសាស្ត្រខ្មែរ ឲ្យចំរើនរុងរឿង ឲ្យមានជំហររឹងប៉ឹង សម្រាប់ជាទីពឹងអាស្រ័យនៃសង្គមខ្មែរក្នុងកម្ពុជរដ្ឋ ។

ការលើកដំកើងនូវឥទ្ធិពលនៃព្រះពុទ្ធសាសនា នឹងអក្សរសាស្ត្រខ្មែរ ឈ្មោះថា លើកដំកើងឥទ្ធិពលខ្មែរ ។

លោកអ្នកដ៏មានឆន្ទៈល្អ ប្រាថ្នានឹងលើកដំកើងឥទ្ធិពលខ្មែរ គួរជាវទស្សនាវដ្តីនេះទុកអានតទៅ ដើម្បីប្រយោជន៍ខ្លួន ប្រយោជន៍ព្រះពុទ្ធសាសនា នឹងប្រយោជន៍ប្រទេសជាតិ ។

សូមសេចក្ដីសុខសេចក្ដីចម្រើនកើតមានដល់លោកអ្នកអានទាំងឡាយ !

បណ្ណាធិការ

ជនណាបានឃើញធម៌
ជននោះឈ្មោះថាបានឃើញព្រះតថាគត,
ជនណាបានឃើញព្រះតថាគត
ជននោះឈ្មោះថាបានឃើញធម៌ ។

ធម្មបទដ្ឋកថា ភាគ ៨

## គោលសំខាន់មួយបទនៃព្រះពុទ្ធសាសនា

## នាម-រូប នឹង កម្ម-ផល

នាម គឺចិត្តនិងចេតសិក រូប គឺរាងកាយ, ពីរយ៉ាងនេះជាសភាព អាស្រ័យគ្នានិងគ្នា ។ នាមតែមួយចំណែកធ្វើអ្វីមិនបាន ស៊ីមិនបាន ចេញសំឡេងមិនបាន អង្គុយដេកឈរដើរមិនបាន, រូបក៏ធ្វើអ្វីតាមទំនើងខ្លួនឯងតែមួយចំណែកមិនបានដូចគ្នា ឥតមានប្រាថ្នានឹងស៊ី នឹងចេញសំឡេង ឬ នឹងកម្រើកទៅមកទេ, តែរូបធ្វើអ្វីគ្រប់យ៉ាងបានដោយសារការឧបត្ថម្ភរបស់នាម, ឯនាមក៏ដូចគ្នា នឹងធ្វើអ្វីៗគ្រប់យ៉ាងបានក៏ដោយសារការឧបត្ថម្ភរបស់រូបដែរ ដូចនាមមានប្រាថ្នានឹងស៊ី នឹងផឹក នឹងចេញសំឡេង ឬ នឹងកម្រើកទៅមកវេលាណា, រូបក៏ស៊ីផឹក ចេញសំឡេង ឬ កម្រើកទៅតាមនាមវេលានោះ ។

រឿងនេះ ដូចមនុស្សពីរនាក់ សុទ្ធតែពិការមកពីកំណើត, មនុស្សម្នាក់ខ្វាក់ មនុស្សម្នាក់ខ្វិន ។ ពេលមួយអ្នកទាំងពីរត្រូវការដើរផ្លូវសំដៅទៅដំបន់មួយត្រូវគ្នា, កាលអ្នកទាំងពីរប្រទះគ្នា មនុស្សខ្វាក់អ្នកជាក់មនុស្សខ្វិនថា "នែ! ភ្នែកយើងខ្វាក់មើលមិនឃើញទេ, តែជើងយើងជាដើរបាន", ឯមនុស្សខ្វិនក៏អ្នកតបមកវិញភ្លាមថា "មែនហើយ! ជើងយើងខ្វិនដើរមិនបានទេ, តែភ្នែកយើងជាមើលឃើញ"; លុះអ្នកទាំងពីរប្រឹក្សាមូលមតិគ្នាហើយ មនុស្សខ្វាក់ក៏ឲ្យមនុស្សខ្វិនឡើងជិះកបោបរទៅរកអាហារចិញ្ចឹមជីវិត, មនុស្សខ្វិនបង្ហាញផ្លូវមនុស្សខ្វាក់ឲ្យឆាកឆ្វេងឆាកស្តាំ ចៀសផុតជង្ហុករណ្ដៅទីឧបសគ្គទាំងឡាយ បានទៅដល់ទីសំដៅរបស់ខ្លួន សម្រេចតាមប្រាថ្នា ។

មនុស្សខ្វាក់ងងឹតភ្នែកអំពីកំណើត អ្នកផងតែងឃើញថា មិនអាចដើរតាមទំនើងចិត្តបានទេ, មនុស្សខ្វិនខ្វះជើងក៏មិនមានកម្លាំងនឹងដើរទៅបានដោយខ្លួនឯងដូចគ្នា, តែកាលមនុស្សទាំងពីរនាក់ព្រមព្រៀងគ្នា ឧបត្ថម្ភគ្នា ក៏នាំគ្នាទៅដល់ទីដែលសំដៅបានទាំងគូ ឧបមានេះពិតយ៉ាងណា; ឯនាមនឹងរូបដែលមិនមានកម្លាំងរៀងខ្លួន បើមិនជួយឧបត្ថម្ភគ្នាទេ រមែងធ្វើអ្វីឲ្យសម្រេចមិនបាន, លុះតែធម្មជាតិទាំងពីរចូលរួមជួយឧបត្ថម្ភគ្នា ទើបធ្វើកិច្ចនានាឲ្យសម្រេចទៅដោយសុវត្ថិភាពបាន ក៏មានឧបមេយ្យដូច្នោះ ។

តាមធម្មតា កាលដែលនាមនឹងរូបទាំងមូលផ្សំចូលគ្នាបានកើតប្រាកដឡើងជារបស់អ្វីមួយហើយ លោកតែងសន្មតហៅដោយរួមថា មនុស្ស ឬ សត្វ មានខ្លួន, តែក្នុងមនុស្ស ឬ សត្វនោះ បើនិយាយតាមពិតឥតមានរបស់ណាមួយដែលហៅថា "ខ្លួន" ឡើយ ដូចជារថ, ដែលយើងហៅថា "រថ" នោះ ដោយយើងសំគាល់ដល់ដុំ ដល់ដែកភ្លៅដែលស៊កចូលក្នុងដុំ ដល់ធ្នុះ ដល់ប្រែកទប់ ប្រែកបាំង និងគ្រឿងសម្ភារៈឯទៀតៗ ដែលរួមគ្នាឡើង ដរាបដល់គ្រប់គ្រាន់, តែរបស់ដែលហៅថា "រថ" នោះ ឥតមានទៅត្រង់ទីណាមួយទេ គឺរួមអវយវៈទាំងអស់ទៅទើបសន្មតហៅថា "រថ" សូម្បីមនុស្សក៏ដូចគ្នា ដែលយើងហៅថា "មនុស្ស" នោះ ដោយយើងសំគាល់ដល់នាមផ្សេងៗ និងធាតុទាំង ៤ ដែលរួមចូលគ្នាតាក់តែងឡើងជាអង្គបរិបូណ៌, តែរបស់ដែលហៅថា "ខ្លួន" នោះ ឥតមានក្នុងមនុស្សសោះឡើយ គឺដែលយើងហៅថា "មនុស្ស ឬ សត្វ" នោះ ដោយរួមអាការៈទាំងពួងសន្មតទៅ ហើយសេចក្តីសន្មតនោះ គ្រាន់តែជាសន្មតដោយប្រកាន់តាមទិដ្ឋិរបស់យើងខ្លួនឯងប៉ុណ្ណោះ ៗ នេះជាបរមត្ថសច្ចៈ គឺកំពូលនៃសេចក្តីពិតដែលមិនចេះប្រែក្លាយ, ហើយអ្នកណាៗ ក៏ប្រកែកប្រណាំងពុំបាន ៗ

ទិដ្ឋិដែលយល់ថា "មានខ្លួននៅក្នុងខ្លួនមនុស្ស" ជ. ទិដ្ឋិខុសស្រឡះ ៗ ការកើត ការរស់នៅ និងការប្រព្រឹត្តទៅគ្រប់យ៉ាង របស់

មនុស្សនិងសត្វក្នុងលោក សុទ្ធតែជាស្រាយទាំងអស់ ឥតខ្លឹមទេ ដូចដើមចេក ឬ ដូចពពុះទឹក ជារបស់ប្រហោងទទេ ។

ធម្មជាតិដែលភាសាបាលីហៅថា "សង្ខារ គឺគ្រឿងផ្សំរៃលក" ឲ្យកើតនាមនិងរូបប្រាកដឡើង ហើយដែលលោកសន្មតថា "មនុស្ស ឬ សត្វ" នោះ ជារបស់មិនទៀង, កាលបើនាមនិងរូបដែលកើតអំពីសង្ខារនោះបែកធ្លាយទៅ ក្នុងវេលាដែលត្រូវបែកធ្លាយ, សាបសូន្យទៅក្នុងវេលាដែលត្រូវសាបសូន្យ, អស់ទៅ ក្នុងវេលាដែលត្រូវអស់ ; សង្ខារនោះក៏បែកធ្លាយទៅ សាបសូន្យទៅ អស់ទៅផង ឥតមានសល់នៅក្នុងទីណាមួយឡើយ ។

ខ្លួនដែលយើងសន្មតគ្នាក្នុងលោកនេះ វិលកើតវិលស្លាប់ពុំបាន, តែកម្ម គឺអំពើ ឬ ការងារដែលមនុស្សយើងបានធ្វើហើយ តែងមានជាប្រាកដណាស់, កម្មអាចស្ទុះទៅនឹងត្រឡប់មកវិញបាន ហើយកម្មជារបស់ត្រូវមានជាប់ជាតំណតគ្នាទៅជាជាន់ៗ គឺកម្មអាចកើតទៀតបាន ។ កម្មគ្រានេះ នឹងប្រាកដឡើងក្នុងគ្រាមុខ កំណើតរបស់កម្មនេះតែមានជាប់ទាក់ទងគ្នាទៅ ជាចង្វាក់ៗ ដូចជ្រលប្រាក់តាមកំណែននៃហេតុនឹងផល គ្រួនាដូចផ្លែគ្រាដែលគេបោះលើភាគល័ខតែងមានរូបគ្រាជាប់នៅច្បាស់លាស់រាល់វេលាដែលបោះយ៉ាងណាមិញ, – សំឡេងស្រែកបង្កកដែលចេញពីមាត់មនុស្សគឺកកងទៅក្នុងទីនានា មានដងព្រៃជាដើម

តែងត្រឡប់មកឲ្យពុទ្ធវិញបាន យ៉ាងណាមិញ, - គ្រូបង្ហាត់សិស្សឲ្យថាតាម កាលគ្រូប្រាប់ប្រយោគជាថ្នាក់ៗ ប្រយោគនោះៗ តែងចូលទៅចាប់ផងសន្ធិនៅក្នុងដួងចិត្តនៃសិស្ស សិស្សតែងត្រឡប់ថាតាមគ្រូវិញបានយ៉ាងត្រឹមត្រូវដូចដើមយ៉ាងណាមិញ; គំនិត សេចក្ដីប្រាថ្នាអធ្យាស្រ័យចំណុចចិត្តរបស់មនុស្សយើងរមែងកើតជាកម្មដ៏ប្រាកដតទៅទៀត ក៏យ៉ាងនោះដែរ ។ កម្មបណ្ដាលឲ្យកើតទៅជាផល ។ កម្មល្អតែងឲ្យផលល្អ កម្មអាក្រក់តែងឲ្យផលអាក្រក់ គឺកម្មតែងបណ្ដាលឲ្យមនុស្សអ្នកធ្វើ ជាមនុស្សល្អ អាក្រក់ មាន ខ្សត់ មានអំណាច ឥតអំណាច ក្នុងខាងមុខ ជាប្រាកដណាស់ ។

ហេតុនេះ បានជា ព្រះសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើង ទ្រង់ត្រាស់ប្រដៅថា :

"ចូរអ្នកដកជំនឿក្នុងតួខ្លួនដែលជាជំនឿខុសចេញឲ្យស្រឡះ ហើយកុំប្រកាន់ស្អិតក្នុងវត្ថុដែលមិនស្ថាពរ, ចូរអ្នកប្រឹងបំពេញសេចក្ដីល្អ ព្រោះសេចក្ដីល្អ ជារបស់ស្ថាពរ ហើយសេចក្ដីល្អនោះឯងនឹងជាកម្ម គឺអំពើល្អរបស់អ្នក ឲ្យផលល្អដល់អ្នកតទៅក្នុងខាងមុខទៀត ជាជាន់ៗ, អ្នកបានធ្វើកម្មបែបណា

អ្នកត្រូវតែទទួលយកផលនៃកម្មបែបនោះជាដរាប  និងប្រកែកប្រណាំងពុំបាន” ។

ដូច្នេះ គួរយើងប្រយ័ត្នឲ្យណាស់, គួរយើងខំប្រព្រឹត្តល្អឲ្យណាស់, កុំបីប្រព្រឹត្តអាក្រក់ឡើយ !

ជាប ពិន

---

## សម្លច្រើនគ្រឿង - ច្រើនពិសា,
## កូនច្រើនបា - ច្រើនល្អ

ទស្សនាវដ្ដីនេះ ដែលនឹងមានឧជារសឆ្ងាញ់ពិសា ជាកិយោគភាពទៅបាន លុះតែមានវិញ្ញូជនច្រើនរូបជួយផ្សំគ្រឿងផង ។ ដូច្នេះ សូមវិញ្ញូជនទាំងឡាយ ជាបព្វជិត ឬគ្រហស្ថ បុរស ឬស្ត្រី និពន្ធអត្ថបទផ្សេងៗ ជាផ្លូវធម៌ ផ្លូវលោក ឬ ផ្លូវអក្សរសាស្ត្រ ផ្ញើទៅចុះផ្សាយ, បើគណៈកម្មការពិនិត្យឃើញថាគួរ នឹងចុះប្រគេន ជូន ដើម្បីជាប្រទីបកម្ពុជា ។

សូមអរគុណយ៉ាងខ្ពស់ទុកជាមុន ។

# ការដឹងប្រមាណ

លោក អ្នកសាធុជនទាំងឡាយ !

រឿងដែលនឹងបរិយាយតទៅនេះ គឺរឿង "ការដឹងប្រមាណ" ។ បើយើងបានសិក្សាវិជ្ជាការផ្សេងៗ ខ្លះល្មមសមគួរហើយ យើងនឹងរឹងរឹតតែចេះគោរពគប់អានព្រះសម្មាសម្ពុទ្ធច្រើនឡើង ៗ ទាំងនេះ ព្រោះវិជ្ជាការអម្បាលនោះ កាលបើយើងសិក្សាទៅៗ ច្រើនឡើងៗ អាចនឹងឃើញថា មានរលកនៃសេចក្ដីដឹងផ្សេងៗ ជាអនេក ចូលមកជួយបន្ថែមព្រះតម្រាស់ប្រៀនប្រដៅ របស់ព្រះអង្គទៀត ព្រោះវិជ្ជាសាស្ត្រតាមធម្មតា រមែងត្រូវគ្នានឹងពុទ្ធសាស្ត្រ ៗ អ្នកសិក្សាវិជ្ជាសាស្ត្រច្រើនឡើង រឹងរឹតតែឃើញពុទ្ធសាស្ត្រ មានដំឡៃខ្លាំងឡើងដែរ ដូចជានឹងលើកតួយ៉ាង ពាក្យប្រៀនប្រដៅ ក្នុងព្រះពុទ្ធសាសនាខ្លះ មកបរិយាយ ព្រមទាំងនាំវិជ្ជាការខ្លះមកអធិប្បាយ បំពេញពុទ្ធោវាទនោះ ដូចតទៅនេះ :–

លោកអ្នកជាពុទ្ធសាសនិកជនគង់ធ្លាប់បានអាន បានឮពាក្យប្រដៅក្នុងព្រះពុទ្ធសាសនា ដែលពោលអំពីរឿង "មត្តញ្ញុតា គឺភាពជាអ្នកដឹងប្រមាណ" ដែលសំដៅយកសេចក្ដីថា ឲ្យស្គាល់ប្រមាណខ្លះមកហើយ ៗ ពាក្យប្រដៅនេះ បើយើងសំឡឹងមើលត្រឹមតែសើៗ ក៏នឹងឃើញថាជារឿងបន្តិចបន្តួច មិនជាសំខាន់អ្វី មិនគួរនឹងលើកយកមក

ពោលទេ តែបើយើងបានទាញយកមករិះគិតពិចារណាមើលដោយពិនិត្យពិច័យហើយ ក៏នឹងឃើញថា ពុទ្ធភាសិតដែលជាប់ទាក់ទងដោយភាពជាអ្នកដឹងប្រមាណនេះ ជាពាក្យប្រដៅដ៏ជ្រាលជ្រៅ មានប្រយោជន៍ដល់អ្នកដែលបង្អោនយកមកប្រព្រឹត្តប្រតិបត្តិជាច្រើន ជាពាក្យប្រៀនប្រដៅដ៏មានដំឡៃដូចជា ពេជ្របរិសុទ្ធ ដែលយើងទាំងឡាយមិនគួរនឹងមើលហួសទៅឡើយ ។

មត្តញ្ញុតា ភាពជាអ្នកដឹងប្រមាណ គឺស្គាល់ប្រមាណនេះ មានផ្លូវប្រើបានច្រើនយ៉ាង មិនមានទីបំផុត, តែក្នុងទីនេះ នឹងនាំមកពោលត្រឹមតែ ៣ ប្រការ គឺ

១ – ភាពជាអ្នកដឹងប្រមាណក្នុងការបរិភោគអាហារ
២ – – ដ៏ – ការព្យាយាមសិក្សា
៣ – – ដ៏ – ការប្រើប្រាស់ទ្រព្យសម្បត្តិ ។

## ភាពជាអ្នកដឹងប្រមាណក្នុងការបរិភោគអាហារ

ពិតមែន. អាហារជារបស់សំខាន់សម្រាប់សត្វដែលមានជីវិតទូទៅ មិនកំណត់ថា មនុស្សឬសត្វតិរច្ឆានទេ ដោយហោចទៅ សូម្បីតែ

ដើមឈើក៏ត្រូវការស្រ័យអាហារគឺជីជាតិដូចគ្នា ៗ តាមគោលវិទ្យាសាស្ត្រពោលថា អាហារមាននាទីសំខាន់ ២ ប្រការ គឺ

ក) ធ្វើនាទីជាឥន្ធនភ្លើង = អាហារកាលទៅរួមនឹងខ្យល់អុកស៊ីហ្សែន ក៏កើតការដុតនេះឡើងយ៉ាងធំយូរ ហើយកើតទៅជាបំហាយកម្ដៅធ្វើឲ្យរាងកាយមានកំដៅឧណ្ហ ៗ ជានិច្ច នឹងធ្វើឲ្យយើងផ្លាស់ប្ដូរឥរិយាបថ រហូតដល់ធ្វើការងារផ្សេង ៗ បាន ។

ខ) ធ្វើនាទីកសាងរាងកាយឲ្យធំប៉ោឡើងនឹងជួសជុលត្រង់កន្លែងដែលបាក់បែកជាប់ដោយគ្រាំគ្រា ឲ្យជាប់លាប់ពេញលេញរឹងប៉ឹងឡើង = កន្សៀននៃការកសាងរាងកាយដែលយើងអាចឃើញច្បាស់លាស់យ៉ាងងាយ ៗ នោះ ក៏គឺកាលជាន់ដំបូងយើងនៅក្មេងតមកយើងក៏ចំរើនធាត់ធំឡើងតាមលំដាប់ សូម្បីរាងកាយបានចំរើនឡើងរហូតដល់កំណត់ទីបំផុតហើយក៏ដោយ ពណ៌ស្បែកក៏នៅតែមិនឈប់ចំរើន ហើយអាហារដែលសល់ក្រៅអំពីការកសាងពណ៌ស្បែកនោះនឹងធ្វើឲ្យចំណែកមួយរបស់រាងកាយទៅជាវត្ថុដែលស្លាប់ សម្រាប់ការពារចំណែកដែលនៅខាងចុង ៗ ដូចយ៉ាងក្រចកជាដើម ។ ត្រង់ពាក្យថាជួសជុលចំណែកដែលបាក់បែកជាប់ដោយគ្រាំគ្រាឲ្យជាប់លាប់ពេញលេញរឹងប៉ឹងឡើងវិញនោះ គួយ៉ាងដែលល្មមឃើញបានងាយ ក៏គឺកាល

រាងកាយបានទទួលរបួសជាមុខសាស្ត្រ ឬ ដំបៅ ធាតុក៏នឹងបែងអាហារយកមកធ្វើជាសាច់ថ្មីឡើងជំនួស ។ ការកសាងរាងកាយឲ្យធំធាត់ឡើង នឹងជួសជុលចំណែកដែលគ្រាំគ្រារបស់រាងកាយឲ្យល្អឡើងនោះ ក៏មកអំពីអាហារដែលយើងបរិភោគនោះឯង ។

អាហារជារបស់សំខាន់ នឹងមានប្រយោជន៍ ដូចពោលមកហើយក៏ពិត, តែអាហារនោះឯង នឹងឲ្យទោសយ៉ាងខ្លាំងក្លាដល់យើងវិញ បើប្រសិនណាជាយើងមិនស្គាល់ប្រមាណ ។

រឿងបរិភោគហួសប្រមាណនេះ សូម្បីក្នុងផ្លូវវិទ្យាសាស្ត្រក៏ត្រូវគ្នានឹងពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធដែរ គឺខាងផ្លូវវិទ្យាសាស្ត្រគេពោលថា ការបរិភោគច្រើនហួសប្រមាណ រមែងជាភ័យដល់សុខភាពរបស់អ្នកបរិភោគ ធ្វើអ្នកបរិភោគឲ្យទៅជាមនុស្សខ្ជិលច្រអូស ឲ្យទៅជាមនុស្សល្ងង់ខ្លៅ តពីនោះទៅទៀត គឺធ្វើឲ្យរបៀបនៃការកិនអាហារ នឹងក្រពះអាហារ ត្រូវធ្វើការហួសកំឡាំង ហើយក្នុងទីបំផុត នឹងធ្វើឲ្យកើតការឈឺថ្កាត់ឡើង ។ បើកើតការឈឺថ្កាត់ឡើងហើយ កិច្ចការដទៃៗដែលគួរធ្វើដើម្បីសេចក្ដីចំរើនដល់ខ្លួនឯង ដើម្បីសេចក្ដីសុខសប្បាយដល់គ្រួសារ នឹងដើម្បីសេចក្ដីចំរើនដល់ប្រទេសជាតិស្រុកនគរ ក៏នឹងត្រូវឈប់ស្ងៀមទៅដែរ ។ កាលបើដូច្នេះ យើងទាំងឡាយ ទើបគួរធ្វើដំណើរតាមព្រះតម្រាស់ប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ត្រង់ថាឲ្យស្គាល់ប្រមាណក្នុងការបរិភោគអាហារ ។

# ភាពជាអ្នកដឹងប្រមាណក្នុងការព្យាយាមសិក្សា

តាមធម្មតា បុគ្គលគ្រប់រូប ដែលនឹងអាចបែរមុខឆ្ពោះទៅកាន់សេចក្ដីចំរើនរុងរឿងទាំងខាងផ្លូវលោក ទាំងខាងផ្លូវធម៌បាន ក៏ព្រោះអាស្រ័យការសិក្សាជាខាងដើម ៗ ការសិក្សាជាចំណែកមួយដែលលើកដំកើងអ្នកសិក្សាឲ្យចំរើនក្នុងសង្គម នឹងឲ្យរឹងរឹតតែមានសេចក្ដីប្រព្រឹត្តិល្អឡើង ទើបចាត់ថាជាការប្រសើរវិសេសមួយចំណែក ៗ ប៉ុន្តែលុះតែអ្នកនោះជាមនុស្សមានចំណេះចេះដឹងល្អ ទាំងមានសេចក្ដីប្រព្រឹត្តិល្អទៀតផង ទើបអាចធ្វើខ្លួនឲ្យទៅជាទីគប់អានគោរពកោតក្រែង ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់បុគ្គលទូទៅ ៗ តែសូម្បីយ៉ាងនេះក៏ដោយ ការព្យាយាមរៀនសូត្រនោះ យើងត្រូវដឹងប្រមាណផង ទើបជាប្រយោជន៍ ៗ នេះមិនមែនពោលដឹកនាំឲ្យខ្ជិលច្រអូសទេ គឺដឹកនាំឲ្យស្គាល់ប្រមាណ ព្រោះថាបើរៀនហួសប្រមាណទៅហើយ ក៏នឹងទទេឥតប្រយោជន៍ ៗ ក្នុងរឿងនេះ គប្បីឃើញរឿងភិក្ខុ ១ រូបឈ្មោះសោណកោឡិវិសៈ ជាតួយ៉ាង ព្រោះលោកព្យាយាមខ្លាំងពេក ដើម្បីនឹងឲ្យបានសម្រេចព្រះអរហត្តផលក្វាម ៗ ដើរចង្ក្រមទាល់តែពុះពងបែកបាតជើង ៗ សូម្បីដូច្នោះ ក៏មិនបានសម្រេចដូចប្រាថ្នា ព្រោះចិត្តនៅអណ្ដែតអណ្ដូងដោយមានពេក ៗ លុះដំណឹងនេះជ្រាបដល់ព្រះពុទ្ធជាម្ចាស់ ព្រះអង្គក៏ទ្រង់ស្ដេចទៅប្រទានឱវាទថា ឲ្យធ្វើសេចក្ដីព្យាយាមតែ

ល្មមប្រមាណ ។ ព្រះអង្គធៀបការធ្វើសេចក្ដីព្យាយាមដោយពិណខ្សែ ៣ កាលបើរឹតតឹងហួសពេក ដេញទៅខ្សែនឹងដាច់ បើបន្ធូរឲ្យធូរពេក ដេញទៅក៏មិនឮ លុះតែរឹតឲ្យតែល្មម ទើបដេញទៅពិរោះ ឬតួយ៉ាងដទៃទៀតក៏មានច្រើន ។ ក្នុងផ្លូវចិត្តវិទ្យា មានពាក្យពន្យល់ថា អ្នកសិក្សាប្រាថ្នានឹងសិក្សាវិជ្ជាជាន់ខ្ពស់តទៅទៀត ដើម្បីនឹងទទួលយកបរិញ្ញាបត្រ គួរឲ្យគ្រូពេទ្យពិនិត្យមើលកាយសិនថា អាចនឹងសិក្សាទៅបានសម្រេចឬទេ? កាលបានសម្រេចហើយ នឹងបានផលប្រយោជន៍យ៉ាងណា? ហើយផលប្រយោជន៍នោះ សមនឹងសេចក្ដីព្យាយាមដែរឬទេ? មានអ្នកសិក្សាខ្លះកាលឲ្យពេទ្យពិនិត្យហើយ ពេទ្យប្រាប់ថាមិនគួរនឹងសិក្សាតទៅទៀតទេ ព្រោះសុខភាពមិនសម្បូរ ក៏មិនជឿ ចេះតែខំព្យាយាមរៀនទៅយ៉ាងពេញបន្ទុក ទាល់តែបានសម្រេចសមតាមបំណងមែន តែលុះបានសម្រេចហើយ នៅមិនទាន់បានធ្វើប្រយោជន៍អ្វីឲ្យកើតឡើងដល់ខ្លួនឯងនឹងប្រទេសជាតិជាដុំកំភួននៅឡើយ តមកទៀត ១ ឆ្នាំ ឬ ២ ឆ្នាំក៏អស់ជីវិតទៅ ។ ទាំងនេះ ព្រោះការត្រាំត្រែងក្នុងការសិក្សានោះឯងជាហេតុ ។ នេះសំដែងឲ្យឃើញទោសនៃការមិនដឹងប្រមាណក្នុងការសិក្សារៀនសូត្រ ។ ពិតណាស់ វត្ថុគ្រប់យ៉ាង ដែលមិនហួសវិស័យរបស់យើង យើងអាចប្រើសេចក្ដីព្យាយាមនោះ ធ្វើឲ្យសម្រេចគ្រប់ប្រការទៅបាន ។ តែយើងត្រូវពិចារណាមើលសិនថា ផលដែលបាន

ទទួលនោះសមគ្នាដែរឬទេ? ព្រោះកាលដែលយើងសិក្សាបានសម្រេច
មកហើយ តមកទៀត ១ ឆ្នាំ ឬ ២ ឆ្នាំ ក៏អស់ជីវិតទៅនេះ ជាការគួរឲ្យ
ស្តាយពន់ពេក ព្រោះបើយើងនៅមានជីវិត សូម្បីការសិក្សាមិនខ្ពស់
ដូចចិត្តយើងតាំងក៏នឹងអាចធ្វើប្រយោជន៍ ធ្វើសេចក្តីចំរើនឲ្យដល់ខ្លួននឹង
ប្រទេសជាតិក្នុងផងដែរទៀតបានច្រើនយ៉ាង ។ ដូច្នេះ ក្នុងការសិក្សារៀន
សូត្រ យើងទើបគួរបង្អោនព្រះតម្រាស់ប្រៀនប្រដៅរបស់ព្រះពុទ្ធជា
ម្ចាស់ត្រង់ថា មត្តញ្ញុតា មកជាគ្រឿងតឿនចិត្តនឹងជាគ្រឿងប្រព្រឹត្ត
ប្រតិបត្តិកុំខាន ។

## ភាពជាអ្នកដឹងប្រមាណក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិ

ពិតមែន ទ្រព្យសម្បត្តិទាំងអស់ ទោះជាសង្ហារិមៈទ្រព្យដែលរើរុះ
បានក្តី ជាអសង្ហារិមៈទ្រព្យដែលរើរុះមិនបានក្តី សុទ្ធតែជារបស់ដែល
យើងរកបានមកដោយលំបាក ។ តែទ្រព្យទាំងអម្បាលនេះ ព្រះ
សម្មាសម្ពុទ្ធទ្រង់ត្រាស់ប្រដៅឲ្យយើងទាំងឡាយចេះប្រើប្រាស់ ចេះ
ចាយវាយ តែល្មមសមគួរ មិនឲ្យត្បិតត្បៀតពេក មិនឲ្យខ្ជះខ្ជាយពេក ។
នេះជារឿងធម្មតាដែលយើងទាំងឡាយដឹងគ្រប់គ្នា ទូទៅស្រាប់ហើយ ។
ទ្រព្យដែលយើងរកបានមកហើយ យើងត្រូវតែប្រើប្រាស់ចាយវាយ
ព្រោះទ្រព្យទាំងនោះ បើមិនប្រើ ក៏មិនអាចឲ្យកើតប្រយោជន៍បាន
មិនខុសអ្វីអំពីដុំដីឬអង្កត់ឈើសោះទេ ។ ដូច្នេះ យើងត្រូវតែប្រើ ត្រូវតែ

បេះប្រើ គឺត្រូវប្រើចំពោះតែវត្ថុដែលជាប្រយោជន៍ កុំប្រើខ្ជះខ្ជាយ គួរស្គាល់ប្រមាណក្នុងការប្រើប្រាស់ កុំឲ្យហួសប្រមាណ ។ មនុស្សដែលប្រើហួសប្រមាណនោះ សូម្បីមានទ្រព្យសម្បត្តិច្រើនយ៉ាងណាក៏ដោយ មិនយូរទេ ទ្រព្យដែលច្រើននោះ គង់អន្តរធានអស់ទៅ, ផលទីបំផុត ត្រូវធ្លាក់ខ្លួនទៅជាមនុស្សក្រលំបាក ។ ក្នុងរឿងដូច្នេះ មានតួយ៉ាងឲ្យយើងឃើញបានជាច្រើន គឺមនុស្សខ្លះមានទ្រព្យរាប់ចំនួនលានកោដិ តែប្រើប្រាស់ចាយវាយក្នុងផ្លូវដែលមិនជាប្រយោជន៍ ដូចយ៉ាងលេងល្បែងភ្នាល់ជាដើម, ផលទីបំផុត ត្រូវលក់បញ្ចាំស្រែចំការផ្ទះសម្បែង ផ្លាស់ឋានៈពីផ្ទះធំមកនៅខ្ទម ដូច្នេះក៏មាន ។ នេះពោលចំពោះបុគ្គលខ្លួនទៅតាមដែលបានសង្កេតឃើញ, បើពោលយ៉ាងឆ្ងាយទូលាយតាមគោលនៃសង្គមវិទ្យាក្នុងផ្នែកសេដ្ឋកិច្ចនោះ គេពោលថាទ្រព្យាករធម្មជាតិទាំងអស់ ប្រជាជនពលរដ្ឋក្នុងលោក គួរនាំគ្នាជួយគ្រប់គ្រងថែរក្សាប្រមូលទុកឲ្យបានច្រើន ៗ ដូចយ៉ាងធ្យូងថ្មដែលជាវត្ថុមានប្រយោជន៍យ៉ាងសំខាន់ក្នុងរោងឧស្សាហកម្មជាដើម នឹងត្រូវស្គាល់ប្រមាណក្នុងការប្រើប្រាស់ផង ៗ ដូច្នេះ ទ្រព្យាករធម្មជាតិនោះ ទើបនឹងមានឲ្យយើងប្រើទៅបានយូរ ៗ បើមិនដូច្នោះទេ នាំគ្នាជីកយកធ្យូងថ្មមកដុតដោយមិនស្គាល់ប្រមាណ បង្គុតខ្ជះខ្ជាយពេក មិនយូរទេ ធ្យូងថ្មដែលជាទ្រព្យាករធម្មជាតិគង់នឹងអស់ទៅ ។ នេះពោលចំពោះប្រយោជន៍រួមគ្នា

នៃប្រជាជនពលលោក ៗ ព្រោះហេតុនោះ ក្នុងការប្រើប្រាស់ទ្រព្យរបស់ដែលជាមាសប្រាក់ក្តី ក្នុងការប្រើប្រាស់ទ្រព្យាករធម្មជាតិក្តី យើងទើបគួរបង្អោនយកព្រះតម្រាស់ របស់ព្រះអរហន្តមុនី ត្រង់ ១ ថា មត្តញ្ញុតា មកប្រើឲ្យកើតជាប្រយោជន៍បានដូចគ្នាទៀត ៗ

ក្នុងធម្មប្បដិបត្តិជាន់ខ្ពស់ = រឿង មត្តញ្ញុតា ដូចបានពោលមកហើយនេះ ចំពោះតែជាប្រយោជន៍ជួយឧបត្ថម្ភដល់ផ្លូវលោកត្រង់ប្រការខ្លះប៉ុណ្ណោះ ៗ តែប្រយោជន៍របស់ មត្តញ្ញុតា នេះ មិនមែនចំពោះតែត្រឹមប៉ុណ្ណោះទេ សូម្បីក្នុងធម្មប្បដិបត្តិជាន់ខ្ពស់ ក៏ត្រូវតែប្រើផងដែរ ៗ ព្រោះក្នុងផ្លូវដែលល្អិតប្រណីតបញ្ចូនក្រៃលែងតទៅទៀត ក៏រឹងរឹតតែត្រូវការ ១ នេះយ៉ាងហ្មត់ចត់ទៅទៀត ទើបអាចនឹងប្រព្រឹត្តទៅបាន ធៀបនឹងគ្រឿងចក្ររបស់នាឡិកាដក់ បើតូចចុះទៅ ក៏រឹងរឹតតែត្រូវការសេចក្តីល្មមប្រមាណច្រើនឡើងជាងគ្រឿងចក្រធំដូច្នោះ ៗ ឧទាហរណ៍យ៉ាងងាយទៅទៀត ដូចជាអ្នកបើករថយន្ត បើថ្នល់ធំទូលាយអ្នកបើកអាចបណ្តោយស្មារតី ប្តូចង្កូតឲ្យវៀចវេរខ្លះបន្តិចបន្តួចបាន មិនជាគ្រោះថ្នាក់អ្វីទេ តែបើថ្នល់តូច ឬ ចង្អៀតវិញ អ្នកបើកតែងប្រុងស្មារតី នឹងប្រយ័ត្នចង្កូតណាស់ ហើយបើថ្នល់នោះ រឹងរឹតតែតូចឬចង្អៀតល្មមចុះតែរថយន្តមួយ អ្នកបើកក៏រឹងរឹតតែប្រុងប្រយ័ត្នស្មារតី

ទីឯចំណាយតែប៉ុណ្ណោះទៅទៀត បើមិនដូច្នោះទេ ភ្ញាក់តែបន្តិច ក៏អាចឲ្យខូចប្រយោជន៍ធំបាន ។

លោកអ្នកអានទាំងឡាយ ! ធម៌ក្នុងព្រះពុទ្ធសាសនា បើយើងបានសិក្សា ហើយនាំមកប្រព្រឹត្តប្រតិបត្តិតាម រមែងឲ្យកើតប្រយោជន៍ដល់ខ្លួនទីងមនុស្សដទៃច្រើន ដូចជារឿង "មត្តញ្ញុតា ការដឹងប្រមាណ" ដែលតាំងមាតិកាជាប្រធាន ៣ ប្រការ គឺ ការដឹងប្រមាណក្នុងការបរិភោគ, ក្នុងការសិក្សា និងក្នុងការប្រើប្រាស់ចាយវាយទ្រព្យសម្បត្តិ ដែលបានពោលរួចមកហើយ ។

ខ្ញុំសូមបញ្ចប់ពាក្យបរិយាយ ដែលបានឲ្យឈ្មោះថា "ការដឹងប្រមាណ" ត្រឹមតែប៉ុណ្ណេះ, សូមសិរីសួស្តីជយមង្គលកើតមានដល់អស់លោក-អ្នកអានទីងអ្នកស្តាប់គ្រប់គ្នា !!!

ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៉ម

| | |
|---|---|
| ទស្សនាវដ្តី ជាឱសថ | មួយមុខប្រាកដ ពូកែពិត |
| អ្នកមានទស្សនា វដ្តីមិត្ត... | ដំកល់នៅជិត រាល់អង្គា ។ |
| ដូចមានឱសថ ដ៏ស័ក្តិសិទ្ធ | មួយអែបនែបនិត្យ រាល់វេលា |
| អានមើលពិនិត្យ ម្តងមួយគ្រា | បានសះស្បើយជា រោគល្ងង់ខ្លះ ។ |

ប. ៣.

# ឱវាទ ១៧ បទ

១ – ការមិនធ្វេសស្មារតី ជាឧបាយមិនស្លាប់ ។

២ – ការធ្វេសស្មារតី ជាឧបាយស្លាប់ ។

៣ – អ្នកដែលមិនធ្វេសស្មារតី មិនស្លាប់គំនិត ទោះបីស្លាប់បាត់ទៅហើយ ក៏ទុកដូចជានៅរស់ ។

៤ – អ្នកដែលធ្វេសស្មារតី ស្លាប់គំនិត ទោះបីមានជីវិតរស់នៅឡើយ ក៏ទុកដូចជាស្លាប់ស្រេចទៅហើយ ។

៥ – រូបកាយតែងតែចាស់ជរា ឯកេរ្តិ៍ឈ្មោះល្អមិនចេះចាស់ជរាឡើយ, ទាំងធម៌របស់សប្បុរស ក៏មិនចេះជរាដែរ ។

៦ – ជីវិតរាល់រូបតិចតួចណាស់ ប៉ុន្តែយើងត្រូវប្រឹងរៀន ប្រឹងរក ប្រឹងគិត ប្រឹងប្រព្រឹត្តល្អ ហាក់ដូចជាយើងនឹងមានជីវិតរស់នៅរាប់ពាន់ឆ្នាំ ។

៧ – ការសិក្សាជាអង្គការរបស់ជាតិ ។

៨ – កិច្ចការដំបូង តែងតែមានខុសខ្លះ លុះត្រាតែថ្នឹកស៊ប់ស៊ាំ ទើបមិនភ្លាត់ភ្លាំងខុសទៀត ។

៩ – បានត្រូវមកពីស្គាល់ខុស បើមិនដូច្នោះទេ គេត្រូវពុំឃើញឡើយ ។

១០ – ឃើញគេចំរើន កុំចចើងតាមគេហួសមាឌខ្លួន ប៉ុន្តែមិនត្រូវបន្ធូរបន្ថយព្យាយាមឡើយ ។

១១ – កើតមកជាកូនប្រុស ត្រូវតែខំប្រឹងបំពេញករណីយកិច្ច លុះត្រាតែបានសម្រេច ។

១២ – ការអ្វីមិនទាន់សម្រេច កុំអាលប្រញាប់ពោលអួត ។

១៣ – ត្រូវប្រដៅខ្លួនឲ្យបានហ្មត់ចត់សិន សឹមប្រដៅអ្នកដទៃ ។

១៤ – ប្រទូស្តទៅរកអ្នកឥតទោស រមែងធ្លាក់ទោសមកលើខ្លួនវិញ ។

១៥ – ប្រាំបួនទ័ល ដប់ទ័ល កុំឲ្យតែទ័លគំនិត ។

១៦ – ការបំពានលើច្បាប់តែងសម្លាប់ប្រយោជន៍ខ្លួន ។

១៧ – បំណាច់កើតមកជាមនុស្ស កុំធ្វើខ្លួនឲ្យជាអ្នកបំព្រៃលោក ។

សម្តេចព្រះមហាសុមេធាធិបតី ជួន–ណាត សង្ឃនាយក
ថ្លែងក្នុងឱកាសពិធីបុណ្យស្រង់ទឹកទទួលសមណសក្តិ ជាសម្តេច
ពីថ្ងៃទី ១០ ឧសភា ១៩៥០

សច្ចំ វេ អមតា វាចា

ពាក្យសត្យហ្នឹងឯង ជាវាចាមិនស្លាប់

ខៃសេចក្តី :

ពាក្យសត្យ គឺពាក្យពោលពិតៗ ជាពាក្យស័ក្តិសិទ្ធ មិនចេះស្លាប់
រមែងរស់នៅ ជាច្រើនកប្ប ឥតប្រែក្រឡាប់ សាបសូន្យឡើយ ។

សំ. ស. ខុ. ថេរ.

ប. ព.

# អបរិហានិយធម៌

(មហាបរិនិព្វានសូត្រ ទីឃនិកាយ)

សម័យ ១ ព្រះមានព្រះភាគទ្រង់គង់លើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង ព្រះបាទអជាតសត្តុ មានព្រះបំណងនឹងញាំញីជិះជាន់ដែនដីរបស់ពួកវជ្ជីក្សត្រ មកជាបំណុះព្រះអង្គ ។ ទើបត្រាស់បង្គាប់វស្សការព្រាហ្មណ៍ ជាមហាមាត្យថា “អ្នកចូរទៅក្រាបបង្គំគាល់ព្រះមានព្រះភាគ ទូលសួរមើលសិនអំពីដំណើរការណ៍ ដែលខ្ញុំមានបំណងនឹងទៅញាំញីជិះជាន់ដែនដីរបស់ពួកវជ្ជីក្សត្រ, បើព្រះមានព្រះភាគទ្រង់ព្យាករណ៍ដូចម្តេច ចូរអ្នកចាំឲ្យច្បាស់ ហើយមកប្រាប់ខ្ញុំវិញ ព្រោះព្រះសព្វញ្ញូពុទ្ធ ទ្រង់មានព្រះបន្ទូលពិតណាស់” ។ វស្សការព្រាហ្មណ៍ ក៏ទៅក្រាបបង្គំទូលដំណើរការណ៍នោះ ចំពោះព្រះសម្មាសម្ពុទ្ធ តាមព្រះរាជបញ្ជា ។

លំដាប់នោះ ព្រះបរមគ្រូទ្រង់ត្រាស់នឹងវស្សការព្រាហ្មណ៍ថា: ម្នាលព្រាហ្មណ៍! សម័យ ១ តថាគតនៅក្នុងសារន្ទទចេតិយ ទៀបក្រុងវេសាលី តថាគតបានសំដែងអបរិហានិយធម៌ ៧ ប្រការ ដល់ពួកក្សត្រក្នុងដែនវជ្ជី ។ ម្នាលព្រាហ្មណ៍! បើអបរិហានិយធម៌នេះ តាំងនៅក្នុងពួកវជ្ជីក្សត្រ ឬក៏ពួកវជ្ជីក្សត្រនឹងប្រតិបត្តិក្នុងអបរិហានិយធម៌នោះ អស់កាលត្រឹមណា, ម្នាលព្រាហ្មណ៍! សេចក្តីចម្រើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រ អស់កាលត្រឹមណោះ; មិនមែនជាសេចក្តីសាបសូន្យឡើយ ។

អបរិហានិយធម៌ ៧ ប្រការនោះ គឺ

១ – បើពួកវជ្ជីក្សត្រនឹងមានការប្រជុំគ្នារឿយៗ មានការប្រជុំគ្នាដោយច្រើន អស់កាលត្រឹមណា, សេចក្តីចម្រើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រ អស់កាលត្រឹមណោះ; មិនមែនជាសេចក្តីសាបសូន្យឡើយ ។

២ – បើពួកវជ្ជីក្សត្រនឹងព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាលើកប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចក្នុងដែនវជ្ជី អស់កាលត្រឹមណា, សេចក្តីចម្រើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រអស់កាលត្រឹមណោះ; មិនមែនជាសេចក្តីសាបសូន្យឡើយ ។

៣ – បើពួកវជ្ជីក្សត្រនឹងមិនបញ្ញត្តច្បាប់ ដែលពួកក្សត្រពីដើមមិនបានបញ្ញត្តហើយ មិនដកច្បាប់ដែលបានបញ្ញត្តរួចហើយ ប្រព្រឹត្តកាន់តាមច្បាប់ក្នុងដែនវជ្ជីអំពីបុរាណដែលបានបញ្ញត្តរួចហើយយ៉ាងណា អស់កាលត្រឹមណា, សេចក្តីចម្រើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រ អស់កាលត្រឹមណោះ; មិនមែនជាសេចក្តីសាបសូន្យឡើយ ។

៤ – បើពួកវជ្ជីក្សត្រនឹងធ្វើសក្ការៈ គោរព រាប់អាន បូជា ពួកវជ្ជីក្សត្រដែលមានព្រះជន្មច្រើនជាងវជ្ជីក្សត្រទាំងឡាយ ទាំងជឿពាក្យគួរស្តាប់របស់ពួកក្សត្រដែលមានព្រះជន្មច្រើនទាំងនោះ អស់កាលត្រឹមណា, សេចក្តីចម្រើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រ អស់កាលត្រឹមណោះ; មិនមែនជាសេចក្តីសាបសូន្យឡើយ ។

៥ – បើពួកវជ្ជីក្សត្រ ទាំងមិនកំហែងបង្ខំពួកស្ត្រីកូនត្រកូល ពួកកុមារីកូនត្រកូលឲ្យនៅរួម (សំវាស) អស់កាលត្រឹមណា, សេចក្ដីចម្រើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រអស់កាលត្រឹមណោះ; មិនមែនជាសេចក្ដីសាបសូន្យឡើយ ។

៦ – បើពួកវជ្ជីក្សត្រទាំងធ្វើសក្ការៈ គោរព រាប់អាន បូជាចេតិយក្នុងដែនវជ្ជី របស់ពួកអ្នកដែនវជ្ជី ដែលនៅខាងក្នុងនគរក្ដី ខាងក្រៅនគរក្ដី ទាំងមិនធ្វើគ្រឿងបូជាប្រកបដោយធម៌ដែលគេធ្លាប់បូជា ធ្លាប់ធ្វើដល់ចេតិយទាំងនោះឲ្យសាបសូន្យទៅ អស់កាលត្រឹមណា, សេចក្ដីចម្រើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រ អស់កាលត្រឹមណោះ; មិនមែនជាសេចក្ដីសាបសូន្យឡើយ ។

៧ – បើពួកវជ្ជីក្សត្រទាំងចាត់ចែងដោយត្រឹមត្រូវ នូវការរក្សាការពារគ្រប់គ្រងប្រកបដោយធម៌ ចំពោះអរហន្តទាំងឡាយ ដោយបំណងថា "ធ្វើម្ដេចហ្ន៎! ព្រះអរហន្តទាំងឡាយដែលមិនទាន់មក ក៏សូមឲ្យមកកាន់ដែនរបស់យើង, ព្រះអរហន្តទាំងឡាយដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅជាសុខក្នុងដែនរបស់យើង" ដូច្នេះ អស់កាលត្រឹមណា, សេចក្ដីចម្រើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រ អស់កាលត្រឹមណោះ; មិនមែនជាសេចក្ដីសាបសូន្យឡើយ ។

កាលបើព្រះមានព្រះភាគមានព្រះបន្ទូលយ៉ាងនេះហើយ វស្សការព្រាហ្មណ៍ ជាមហាមាត្យ ក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តាប្រោស! សេចក្ដីចម្រើនតែងមានប្រាកដ សេចក្ដីសាបសូន្យមិនមានដល់ពួកវជ្ជីក្សត្រ ដែលប្រកបដោយអបរិហានិយធម៌ សូម្បីតែមួយៗ ចាំបាច់និយាយថ្វីដល់ទៅគ្រប់អបរិហានិយធម៌ទាំង ៧ នោះ, សូមទ្រង់ព្រះមេត្តាប្រោស! ព្រះបាទអជាតសត្តុវេទេហីបុត្រ មាគធិករាជ មិនងាយនឹងចាប់ពួកវជ្ជីក្សត្រដោយការច្បាំងបានទេ លុះណាតែលួងលោមយកចិត្ត ឬធ្វើឲ្យបែកសាមគ្គីគ្នា ទើបអាចច្បាំងជិះជាន់ដណ្ដើមយកបានដោយងាយ ។

វស្សការព្រាហ្មណ៍ត្រេកអររីករាយចំពោះពុទ្ធភាសិត ហើយក៏ក្រាបបង្គំលាក្រោកចាកអាសនៈចេញមក ទូលព្រះបាទអជាតសត្តុតាមដំណើរការណ៍នោះសព្វគ្រប់ ។

ព្រះទេពមុនី យូ-ប៊ុន

សេចក្ដីរុងរឿង ពុទ្ធសាសនា

ព្រះពុទ្ធត្រាស់ថា មានអង្គ ៥:

១ – ស្ដាប់ ២ – រៀន ៣ – ចងចាំ

៤ – ចេះ និង ៥ - បានកាន់តាម ។

អ. និ. ប. និ.

ប. ព.

# អារម្ភបទ នៃ សុភាសិត

អំពើដែលយើងធ្វើ លោកហៅថា “កម្ម” ។ នោះសម្រេចមកពីគំនិត ។ គំនិតល្អ កម្មក៏ល្អ គំនិតអាក្រក់ កម្មក៏អាក្រក់ ។ កម្មល្អឲ្យផលល្អ កម្មអាក្រក់ឲ្យផលអាក្រក់ ។ គំនិតជាគោលដើមសម្រាប់កសាងជីវ-ភាពរបស់មនុស្ស, ដូចមានសុភាសិតថា ‘ចិត្តតែងដឹកនាំសត្វលោក” ។ គំនិតល្អតែងធ្វើឲ្យកើតផលប្រយោជន៍យ៉ាងធំទូលាយ ។ ការពិចារណាសុភាសិតនាំឲ្យកើតបញ្ញាសម្រាប់ត្រិះរិះរកផ្លូវចំរើន ចៀសវាងផ្លូវវិនាស កំចាត់គំនិតអាក្រក់ស្មុគស្មាញឲ្យឃ្លាតចេញពីខន្ធសន្តាន ជាអនាម័យមួយដ៏ប្រសើរសម្រាប់ចិត្ត ។ ក្នុងមួយថ្ងៃ នៅពេលស្ងាត់ យើងគួរខំដកចិត្តចេញពីការកង្វល់ធម្មតា ដើម្បីពិចារណាសុភាសិតបទណាមួយឲ្យយល់សេចក្តីច្បាស់ ហើយខំសង្កេតយកទុកជាគោលសម្រាប់ប្រតិបត្តិតទៅ, បើអាចធ្វើបាន គួរកត់ត្រាការពិចារណានោះទុក ជាកិច្ចទូន្មានចិត្តដ៏មានប្រយោជន៍យ៉ាងធំក្រៃលែង, ហើយបើបានពិចារណាសុភាសិតដដែលៗ នោះ អស់វេលាពីរបីថ្ងៃថែមទៀត ជាការគាប់ប្រសើរណាស់ ។

# សុភាសិត ៥០ មខ

ស្រង់ចាកច្បាប់ផ្សេងៗ មានធម្មបទខុទ្ទកនិកាយជាដើម

១ – មនុស្សឧស្សាហ៍ធ្វើការងារ រមែងបានទ្រព្យ ។

២ – ចាយវាយតែល្មម ជាវិធីនៃអ្នកមានសម្បត្តិ ។

៣ – ការប្រុងប្រយ័ត្ន ជាសម្បត្តិរបស់អ្នកមានសម្បត្តិ ។

៤ – សេដ្ឋកម្ម គួរយើងប្រាថ្នាគ្រប់វេលា ។

៥ – ការសម្បូរ នឹងកើតមានបាន ដោយសារតែប្រឹងស្វែងរក ។

៦ – ចូរពិចារណាដល់ប្រយោជន៍នៃការចាយវាយទ្រព្យ ។

៧ – ទ្រព្យរបស់យើងដែលនឹងបានគ្រប់ចំនួនរយ ក៏ព្រោះតែរក្សាចំនួនមួយទុកឲ្យគង់ ។

៨ – គប្បីចេះកាន់យកប្រយោជន៍ដែលកើតអំពីភោគទ្រព្យ ។

៩ – ទ្រព្យរបស់យើង សូម្បីមានតែបន្តិចបន្តួច ក៏ប្រសើរជាងទ្រព្យអ្នកដទៃដែលមានច្រើន ។

១០ – ស្រីសួស្តី គឺបុណ្យ ជាទីមកដេកនៅនៃទ្រព្យសម្បត្តិទាំងឡាយ ។

១១ – កើតមកជាប្រុស ត្រូវតែព្យាយាមឲ្យទាល់តែបានសម្រេចប្រយោជន៍ ។

១២ – គួរតែប្រញាប់ធ្វើសេចក្តីព្យាយាមក្នុងថ្ងៃនេះឲ្យរួចស្រេច ។

១៣ – បើនឹងធ្វើ ក៏ត្រូវធ្វើការនោះឲ្យមែនទែន ។

១៤ – អ្នកមានសេចក្ដីព្យាយាមមាំ ទោះបីមានជីវិតរស់នៅតែ ១ថ្ងៃក៏ប្រសើរណាស់ ។

១៥ – ចំណេះវិជ្ជាព្រមទាំងសេចក្ដីប្រព្រឹត្តល្អ រមែងទំនុកបំរុងមនុស្សឲ្យមានសក្ដិយសខ្ពង់ខ្ពស់ឡើងបាន ដូចជាភ្នំដ៏ខ្ពស់ ។

១៦ – អ្នកដែលមានចំណេះវិជ្ជាល្អ ប៉ុន្តែមិនប្រព្រឹត្តឲ្យសមតាមចំណេះវិជ្ជានោះទេ ទឹងឈ្មោះថាជាមនុស្សល្អព្រមមិនបាន ។

១៧ – មនុស្សសូម្បីកើតក្នុងត្រកូលថោកទាប ប៉ុន្តែប៉ិនប្រសប់ធ្វើការងាររមែងរុងរឿងបាន ដូចជាពន្លឺភ្លើងអាចបំភ្លឺក្នុងវេលាយប់បាន ។

១៨ – អ្នកដែលធ្វើការអ្វីៗ បើមិនបានប្ដេជ្ញាទុកក្នុងចិត្តឲ្យដាច់ស្រេចជាមុនទេ, ការនោះៗ ច្រើនតែមិនបានសម្រេច បើទុកជាសម្រេចក៏មិនរៀបរយល្អ ។

១៩ – គួររក្សាពាក្យសត្យ ដូចរក្សាទ្រព្យដែលគេប្រាថ្នាទៅក្នុងលោក ។

២០ – អ្នកប្រាថ្នាសេចក្ដីសុខ ប៉ុន្តែមិនប្រកបហេតុនៃសុខ រមែងបានទទួលសេចក្ដីទុក្ខជាដរាប ។

២១ – មនុស្សឥតចំណេះវិជ្ជា ប្រៀបដូចជាមនុស្សគ្មានមិត្តសំឡាញ់ក្នុងវេលាធ្វើដំណើរ ព្រោះចំណេះវិជ្ជាទុកជាមិត្តសំឡាញ់យ៉ាងស្និទ្ធ ។

២២ – អ្នកមានសេចក្ដីអង់អាចក្នុងកិច្ចការ រមែងរក្សាការៈ សូម្បី ជួនធុរច្រើនមុខឲ្យរៀបរយល្អបាន ដូចជាមេទ័ពអ្នកអង់អាចក្នុងសង្គ្រាម ។

២៣ – ទ្រព្យសម្បត្តិរមែងជាប្រយោជន៍ដល់អ្នកដែលស្គាល់កាល នឹងដឹងប្រមាណក្នុងការប្រើប្រាស់ចាយវាយ ។

២៤ – គួរនិយាយទូន្មានគ្នា នឹងគួរហាមឃាត់គ្នាឲ្យបានមុនធ្វើអំពើខុស ឬការអាក្រក់ ។

២៥ – ប្រយោជន៍ឯណាដែលខ្លួននឹងត្រូវបានត្រូវដល់ដោយសុចរិតធម៌ មិនគួរបណ្ដោយឲ្យប្រយោជន៍នោះ កន្លងរំលងខ្លួនយើងទៅឡើយ ។

២៦ – ប្រយោជន៍អ្នកដទៃសូម្បីមានច្រើន ក៏មិនល្អស្មើនឹងប្រយោជន៍របស់ខ្លួនយើងសូម្បីមានតែបន្តិចបន្តួចដែរ ។

២៧ – ទ្រព្យសម្បត្តិក្នុងផ្ទះកើតមានអន្តរាយ ក៏ព្រោះតែម្ចាស់ផ្ទះមិនល្អ គឺមិនចេះថែរក្សាឲ្យផុតចាកអន្តរាយ ។

២៨ – សព្វបំណោះវិជ្ជា មិនថាផ្នែកណាទេ បើអាចរៀនសូត្របាន គង់តែបានសម្រេចប្រយោជន៍គ្រប់យ៉ាង ។

២៩ – លោកិយទ្រព្យ ជាចំណែកនៃសេចក្ដីកង្វល់, ឯលោកុត្តរទ្រព្យមិនមែនដូច្នោះទេ ។

៣០ – ស្ថានសួគ៌នឹងស្ថាននរកមិនមែនបានមកអំពីដទៃក្រៅអំពីខ្លួនឯងទេ, ហេតុនេះ ចូរពិចារណាឲ្យសព្វគ្រប់ចុះ ។

៣១ – ប្រទេសណាមិនមានអ្នកប្រាជ្ញ ប្រទេសនោះទុកដូចជាខ្វះព្រលឹងដ៏សំខាន់ ។

៣២ – ការងារឯណាដែលត្រូវអាស្រ័យមនុស្សច្រើននាក់ បើមិនមានមេអ្នកចាត់ចែងការនោះទេ, ការនោះច្រើនតែផ្តេសផ្តាសមិនរៀបរយ ។

៣៣ – មិត្តសំឡាញ់ដែលល្អ តែងស្គាល់គ្នាក្នុងវេលាមានទុក្ខភ័យ នឹងសេចក្ដីខ្វះខាតគាល់ក្រទ្រព្យសម្បត្តិ ។

៣៤ – មិត្តសំឡាញ់ដែលអាក្រក់ ទុកដូចជាច្រែះស៊ីដែក ។

៣៥ – គួរសេពគប់តែនឹងមនុស្សជាកល្យាណមិត្តពិតៗ, ចំណែកមិត្តក្រៅអំពីនេះគ្រាន់តែស្គាល់គ្នាបានហើយ ។

៣៦ – មាតាលោកពោលថាជាកល្យាណមិត្តក្នុងផ្ទះ ។

៣៧ – ភរិយាបើជាស្ត្រីស្មោះត្រង់សុចរិត នឹងស្រឡាញ់ស្វាមីមែនពិត ក៏គួររាប់ថាជាកល្យាណមិត្តដ៏ស្និទ្ធបាន ។

៣៨ – សំពត់ដែលស្អាត កាលបើមានមន្ទិលមកប្រឡាក់សូម្បីតែបន្តិច ក៏មើលឃើញបានច្បាស់យ៉ាងណា, មនុស្សដែលធ្លាប់ប្រព្រឹត្តល្អមកពីដើមហើយ កាលបើធ្វើអំពើអាក្រក់សូម្បីតែបន្តិច ការអាក្រក់នោះក៏ប្រាកដច្បាស់យ៉ាងនោះដែរ ។

៣៩ – សេចក្ដីខ្ជិលច្រអូស ជាបុសគល់នៃសេចក្ដីអាក្រក់ទាំងឡាយ ។

៤០ – សេចក្ដីចេះដឹងរបស់មនុស្សពាល បើទុកជាមានប៉ុន្មានក្ដី ក៏មានដើម្បីតែសេចក្ដីវិនាសមួយចំណែកប៉ុណ្ណោះ ។

៤១ – បើបានប្រយោជន៍យ៉ាងណា គប្បីធ្វើខ្លួនយ៉ាងនោះ ។

៤២ – សេចក្ដីសុខ មិនមែនជាផលដែលបុគ្គលធ្វើអំពើអាក្រក់ ត្រូវបានដោយងាយឡើយ ។

៤៣ – កិច្ចការឯណាដែលមិនល្អ ទាំងមិនជាប្រយោជន៍ដល់ខ្លួន កិច្ចការនោះគេធ្វើបានដោយងាយ ។

៤៤ – មនុស្សស្អាតរមែងមិនត្រេកអរក្នុងបាប ។

៤៥ – មនុស្សជាទីស្រឡាញ់របស់ជនច្រើននាក់ រមែងបានសេចក្ដីសុខបរិបូណ៌ ។

៤៦ – មនុស្សអ្នកមានចំណេះវិជ្ជា ទាំងស្អាត (ក្នុងការងារ) រមែងធ្វើទីពឹងបានក្នុងលោក ។

៤៧ – បញ្ញាជាអណ្ដូងកើតនៃទ្រព្យសម្បត្តិទាំងបរិវារទាំងពួង ។

៤៨ – មនុស្សយើងមិនត្រូវបណ្ដោយឲ្យពេលកន្លងផុតទៅឥតប្រយោជន៍ឡើយ ។

៤៩ – មនុស្សដែលទាំងទីពឹងគេបាន ក៏ព្រោះសេចក្ដីល្អខ្លួនឯង ។

៥០ – មនុស្សដែលព្រមទទួលសេចក្ដីទុក្ខលំបាកក្នុងខាងដើម តែងបានទទួលសេចក្ដីសុខសប្បាយក្នុងខាងក្រោយ ។

# បដិភាណ (ប្រាជ្ញា) របស់ព្រះពុទ្ធ

ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងធម៌ ដោយប្រាជ្ញាឲ្យអ្នកស្ដាប់បាន ទទួលប្រយោជន៍ដោយព្រះមេត្តា សូម្បីអ្នកស្ដាប់ខ្លះពោលអាក្រក់ចំពោះ ព្រះអង្គ ក៏ទ្រង់កែសេចក្ដីអាក្រក់នោះ ឲ្យត្រឡប់ជាសេចក្ដីល្អ ព្រោះតែ អ្នកនោះកើតសេចក្ដីជ្រះថ្លាក្នុងព្រះប្រាជ្ញាញាណ ។

សម័យនោះ[១] ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់គង់នៅក្បែរដើមស្ដៅ ជាលំនៅរបស់នឡេរុយក្ស ជិតស្រុកវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃមាន ប្រមាណច្រើនចំនួន ៥០០ រូប ។ វេរញ្ជព្រាហ្មណ៍បានចូលទៅគាល់ ក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំបានឮពាក្យ ថា ព្រះសមណគោតមមិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយ ដែលចាស់គ្រាំគ្រាជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅបានយូរឆ្នាំ មកហើយ មានអាយុក៏ដល់ចូលមកក្នុងបច្ឆិមវ័យហើយ ទោះបីគ្រាន់តែ អញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះ ឲ្យអង្គុយលើអាសនៈ ព្រះអង្គក៏មិន ធ្វើ, កិច្ចមានកិរិយាមិនសំពះជាដើមនោះ ជាទំនងពុំសមគួរឡើយ ។

ព្រះដ៏មានព្រះភាគត្រាស់តបថា ម្នាលព្រាហ្មណ៍ ក្នុងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំង

---

១ វិនយបិដក មហាវិភង្គ ភាគ ១ ទំព័រ ១ ។

សមណៈនឹងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនឹងមនុស្សដ៏សេស តថាគតមិនឃើញអ្នកណាមួយល្មមឲ្យតថាគតសំពះ ឬក្រោកទទួល ឬអញ្ជើញហៅរកឲ្យអង្គុយលើអាសនៈនោះឡើយ ។

វេរញ្ជព្រាហ្មណ៍ក៏ពោលពាក្យប្រឡោះបោះទៅរកព្រះសាស្ដាថា ព្រះសមណគោតមដ៏ចំរើន ជាមនុស្សសោះកក្រោះឥតរសជាតិ ។ (រសជាតិក្នុងទីនេះ ព្រាហ្មណ៍សំគាល់ដល់សាមគ្គីរស គឺការសំពះអ្នកចាស់ព្រឹទ្ធាចារ្យ ដែលជាគុណមួយយ៉ាងធ្លាប់ប្រកាន់មកថាជាប្រពៃណីដ៏សំខាន់) ។

ព្រះដ៏មានព្រះភាគត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតមជាមនុស្សសោះកក្រោះឥតរសជាតិ ដែលគេថានោះត្រូវហើយ ព្រោះរសជាតិ គឺរូប សំឡេង ក្លិន រស សម្ផស្សទាំងប៉ុន្មាននោះ តថាគតបានលះស្រឡះហើយ បានផ្ដាច់ឫសគល់អស់ហើយ ។

ព្រាហ្មណ៍ពោលថា ព្រះសមណគោតមដ៏ចំរើន ជាមនុស្សគ្មានគ្រឿងបរិភោគ ។ (គ្រឿងបរិភោគក្នុងទីនេះ ព្រាហ្មណ៍សំគាល់ដល់សាមគ្គីរសដូចគ្នា ព្រោះគុណធម៌នេះនិយមរាប់អានប្រកាន់ថាជាសម្បត្តិដ៏ល្អ) ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតមជាមនុស្សគ្មាន

គ្រឿងបរិភោគ ដែលគេថានោះត្រូវហើយ ព្រោះគ្រឿងបរិភោគ គឺ រូប សំឡេង ក្លិន រស សម្ផស្សទាំងប៉ុន្មាននោះ តថាគតបានលះស្រឡះហើយ បានផ្ដាច់ផ្ដិលបុសគល់អស់ហើយ ។

ព្រាហ្មណ៍ពោលថា ព្រះសមណគោតមដ៏ចំរើន ជាអ្នកពោលពាក្យឃាត់កិច្ចការថាមិនត្រូវធ្វើ ។ (ខនេះ ព្រាហ្មណ៍សំគាល់ដល់ការមិនធ្វើសេចក្ដីសាមគ្គីរសជ្ជនិគ្គា) ។

ព្រះសាស្ដាទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យឃាត់កិច្ចការថាមិនត្រូវធ្វើ ដែលគេថានោះត្រូវហើយ ព្រោះតថាគតប្រកាន់និយាយហាមឃាត់ថា មិនត្រូវអ្នកណាមួយធ្វើកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតឡើយ, តែងនិយាយហាមឃាត់ថា មិនត្រូវអ្នកណាមួយធ្វើនូវធម៌ទាំងឡាយជាអកុសលលាមកច្រើនប្រការនោះឡើយ ៗ

ព្រាហ្មណ៍ពោលថា ព្រះសមណគោតមដ៏ចំរើន ជាអ្នកពោលពាក្យកាត់ផ្ដាច់ផ្ដិល ។ (ខនេះ ព្រាហ្មណ៍សំគាល់ដល់ការកាត់ផ្ដាច់ផ្ដិលទំនៀមទម្លាប់ដ៏ល្អរបស់លោក) ។

ព្រះសាស្ដាទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យកាត់ផ្ដាច់ផ្ដិល ដែលគេថានោះត្រូវហើយ ព្រោះតថាគតប្រកាន់និយាយ

ថាឲ្យសត្វកាត់ផ្តាច់ផ្តិលនូវរាគៈ ទោសៈ មោហៈ, តថាគតតែងនិយាយថាឲ្យសត្វកាត់ផ្តាច់ផ្តិលនូវធម៌ទាំងឡាយ ជាអកុសលដ៏អាក្រក់ច្រើនយ៉ាងនោះចេញ ។

ព្រាហ្មណ៍ពោលថា ព្រះសមណគោតមដ៏ចំរើន ជាអ្នកខ្ពើមរអើម ។ (ខនេះ ព្រាហ្មណ៍សំគាល់ដល់ការខ្ពើមរអើមសាមគ្គីរស) ។

ព្រះសម្ពុទ្ធទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកខ្ពើមរអើម ដែលគេថានោះត្រូវហើយ ព្រោះតថាគតខ្ពើមសេចក្តីប្រព្រឹត្តិអាក្រក់ដោយកាយ វាចា ចិត្ត, តថាគតខ្ពើមសេចក្តីប្រកបចិត្តផ្តេកផ្តិតទៅរកអកុសល-ធម៌ទាំងឡាយដ៏អាក្រក់ច្រើនប្រការនោះណាស់ ។

ព្រាហ្មណ៍ពោលថា ព្រះសមណគោតមដ៏ចំរើន ជាអ្នកបំផ្លាញ ។ (ខនេះ ព្រាហ្មណ៍សំគាល់ដល់សេចក្តីបំផ្លាញប្រពៃណីសាមគ្គីរសរបស់លោកឲ្យវិនាស) ។

ព្រះលោកនាថទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកបំផ្លាញ ដែលគេថានោះត្រូវហើយ ព្រោះតថាគតសំដែងធម៌ចំពោះផ្លូវប្រតិបត្តិដែលបំផ្លាញបង់នូវរាគៈ ទោសៈ មោហៈ, តថាគតសំដែងធម៌ចំពោះផ្លូវប្រតិបត្តិដែលរំលាងបង់នូវអកុសលធម៌ទាំងឡាយដ៏អាក្រក់ច្រើនប្រការ ។

ព្រាហ្មណ៍ពោលថា ព្រះសមណគោតមជាអ្នកដុតកំដៅ ។ (ខនេះ ព្រាហ្មណ៍សំគាល់សេចក្តីថា អ្នកដែលមិនធ្វើសេចក្តីគោរពចំពោះចាស់ព្រឹទ្ធាចារ្យនោះ រមែងដុតកំដៅអ្នកជាចាស់ព្រឹទ្ធាចារ្យឲ្យក្តៅក្រហាយ គឺឲ្យទោមនស្សតូចចិត្ត) ។

ព្រះសព្វញ្ញូជាម្ចាស់ទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែនមានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកដុតកំដៅ ដែលគេថានោះត្រូវហើយ ព្រោះតថាគតប្រកាន់និយាយថាការប្រព្រឹត្តិអាក្រក់ដោយ កាយ វាចា ចិត្ត ជាទីតាំងនៃសេចក្តីក្តៅក្រហាយជាអកុសលធម៌ដ៏អាក្រក់ ។ បើអ្នកណាបានលះបង់ស្រឡះហើយបានផ្តាច់ផ្តិលឫសគល់អស់ហើយ តថាគតហៅអ្នកនោះថាជាអ្នកដុតកំដៅម្នាលព្រាហ្មណ៍ អកុសលធម៌ទាំងឡាយដ៏អាក្រក់ ជាទីតាំងនៃសេចក្តីក្តៅក្រហាយនោះតថាគតឯងបានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ ។

ព្រាហ្មណ៍ពោលថា ព្រះសមណគោតមដ៏ចំរើន ជាមនុស្សឥតកំណើត ។ (ខនេះ ព្រាហ្មណ៍សំគាល់ដល់ការមិនគោរពចំពោះចាស់ព្រឹទ្ធាចារ្យ ថាជាការឥតកំណើត ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែនមានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សឥត

កំណើត ដែលគេថានោះត្រូវហើយ ព្រោះកិរិយាដេកក្នុងគភ៌ ដំណើរកើតក្នុងគភ៌តៗ ទៅមុខទៀត បើអ្នកណាបានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលបុសគល់អស់ហើយ តថាគតហៅអ្នកនោះថា អ្នកឥតកំណើត, ម្នាលព្រាហ្មណ៍ កិរិយាដេកក្នុងគភ៌ ដំណើរកើតក្នុងគភ៌តតទៅមុខទៀតនោះ តថាគតឯងបានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលបុសគល់អស់ហើយ. ទ្រង់ត្រាស់តទៅទៀតថា ម្នាលព្រាហ្មណ៍ ប្រៀបដូចស៊ុតមាន់ទាំងឡាយ ៨ ក្តី ១០ ក្តី ១២ ក្តី ស៊ុតមាន់ទាំងនោះ គឺមេក្រាបដោយប្រពៃហើយ ធ្វើឲ្យកក់ក្តៅដោយប្រពៃហើយ លុះដល់វេលាញាស់ កំបណ្តាកូនមាន់ទាំងនោះ កូនមាន់ណាទំលាយសម្បកស៊ុតដោយចុងក្រចកជើង ឬ ដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួលមុនគេបំផុត បើដូច្នេះតើ អ្នកផងគួរហៅកូនមាន់នោះ ថាកូនច្បងឬកូនពៅហ្ន៎? ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតមដ៏ចំរើន កូនមាន់នោះ គេគួរហៅថា កូនច្បង ពីព្រោះវាជាបងគេបំផុត ៗ ព្រះសាស្តាទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ កាលបើពពួកសត្វដូចជាស៊ុតមាន់កើតហើយ មានអវិជ្ជាគឺសេចក្តីល្ងង់ដូចជាសម ស៊ុតកំពុងរបវ្ទឹតក្នុងលោក មានតែតថាគតម្នាក់ឯងដែលទំលាយសម្បកស៊ុតគឺសេចក្តីល្ងង់ហើយត្រាស់ដឹងខ្លួនឯងដោយប្រពៃនូវសម្មាសម្ពោធិញ្ញាណ ដែលមិនមានគុណជាតឯទៀតប្រសើរជាងឡើយ, ម្នាលព្រាហ្មណ៍ តថាគតឯង

ជាចម្បង ជាបុគ្គលប្រសើរបំផុតជាងសត្វលោក ។ តអំពីនេះ ទ្រង់សំដែងធម៌ គ្រឿងចំលាយសម្បកស៊ុត គឺអវិជ្ជាឲ្យព្រាហ្មណ៍ស្ដាប់ជាលំដាប់ទៅ ។ ទីបំផុត ព្រាហ្មណ៍ក៏កើតសេចក្ដីជ្រះថ្លា ទូលសរសើរព្រះធម្មទេសនាថា ពីរោះណាស់ ភ្លឺច្បាស់ណាស់ គួរនាដូចជាមនុស្សចាប់របស់ដែលគេផ្កាប់ចុះឲ្យផ្ងារឡើង ពុំនោះដូចជាមនុស្សបើកបង្ហាញរបស់ដែលគេលាក់បិទបាំង ពុំនោះសោតដូចជាមនុស្សប្រាប់ផ្លូវដល់អ្នកវង្វេងទិស ឬក៏ដូចជាមនុស្សកាន់ប្រទីបព្រោលបំភ្លឺក្នុងទីងងឹតឲ្យមនុស្សមើលឃើញនូវរូបទាំងឡាយ ខ្ញុំព្រះអង្គនោះ សូមដល់នូវព្រះគោតមដ៏ចំរើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក ចាប់ដើមតាំងអំពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចំរើន ជ្រាបនូវខ្ញុំព្រះអង្គថា ជាឧបាសកដល់សរណគមន៍ស្មើដោយជីវិត ។

សរុបសេចក្ដីតាមដែលមានមកក្នុងមហាវគ្គនេះថា ពួកព្រាហ្មណ៍ស្រុកវេរញ្ជាបានដឹងថា ព្រះពុទ្ធជាម្ចាស់មិនទ្រង់ធ្វើសេចក្ដីគោរពចំពោះពួកព្រាហ្មណ៍ដែលជាចាស់ព្រឹទ្ធាចារ្យ ក៏មានសេចក្ដីក្រោធខឹង រករឿងនិយាយតាក្រកចំពោះព្រះអង្គដោយប្រការផ្សេងៗ រួមជា ៨ យ៉ាង គឺ

១ - ជាមនុស្សសោះកក្រោះឥតរសជាតិ

២ - ជាមនុស្សគ្មានគ្រឿងបរិភោគ

៣ - ជាអ្នកពោលពាក្យឃាត់កិច្ចការ ថាមិនត្រូវធ្វើ

៤ – ជាអ្នកពោលពាក្យកាត់ផ្តាច់ផ្តិល

៥ – ជាអ្នកខ្ទើមរអើម

៦ – ជាអ្នកបំផ្លាញ

៧ – ជាអ្នកផុតកំដៅ

៨ – ជាមនុស្សឥតកំណើត

តែព្រះពុទ្ធជាម្ចាស់ទ្រង់មានព្រះប្រាជ្ញាឈ្លាសក្នុងទេសនាវិធី បានទ្រង់កែពាក្យនិយាយអាក្រក់ទាំងនោះ ឲ្យក្លាយជារឿងល្អទៅទាំងអស់ ដរាបដល់ព្រាហ្មណ៍នោះកើតសេចក្តីជ្រះថ្លា លែងក្រោធខឹងចំពោះព្រះអង្គ ថ្វាយខ្លួនជាឧបាសកអ្នកកាន់អានព្រះពុទ្ធសាសនា ។

ព្រះពុទ្ធជាម្ចាស់ទ្រង់អាចកែខៃផ្លាស់ប្តូរពាក្យពោលអាក្រក់ៗ ដែលព្រាហ្មណ៍ពោលដោយសេចក្តីក្រោធ ឲ្យត្រឡប់ជាពាក្យពោលដ៏មានគុណប្រយោជន៍ឡើងដោយរហ័សក្លាមៗ, នេះឯងជាគ្រឿងសំដែងព្រះបដិភាណរបស់ព្រះអង្គឲ្យប្រាកដ ។

ស៊ុន - ហ៊ាន

| | |
|---|---|
| ព្រះពុទ្ធទុកដូច | អ្នកផ្តើមផុតព្រៃ |
| ព្រះធម៌ប្រពៃ | ទុកដូចគប់ភ្លើង |
| ព្រះសង្ឃទុកដូច | មនុស្សក្នុងលោកយើង |
| ឃើញដីស្អាតរៀង | ប្រកបការងារ |

ប. ព.

---

# និទានមនុស្សខ្វាក់

បុរសម្នាក់ខ្វាក់ភ្នែកទាំងពីរតាំងពីកំណើត ។ ថ្ងៃមួយ បុរសនោះនិយាយនឹងបុរសភ្នែកជាជាសំឡាញ់ថា "ខ្ញុំមិនជឿទេ ដែលគេថាក្នុងលោកនេះមានពន្លឺ មានពណ៌សម្បុរផ្សេងៗ ... មានព្រះអាទិត្យព្រះចន្ទនឹងផ្កាយ ...នោះ, គ្មានអ្នកណាធ្លាប់បានជួបប្រទះឡើយ; ពាក្យដែលថាមាននេះមាននោះ ជាពាក្យនិយាយគ្រាន់តែបញ្ឆើចបញ្ឆើគ្នាទៅទទេៗ ទាំងអស់" ។

បុរសជាសំឡាញ់ព្យាយាមពន្យល់ថា "របស់អំបាលនោះ ជារបស់មានពិតណាស់" តែទោះបីខំពន្យល់យ៉ាងណា ក៏ឥតអំពើ ។

បុរសខ្វាក់ត្រឡប់ជាតបថា "ដែលអ្នកផងនិយាយថាមានពន្លឺ ...នោះ សុទ្ធតែជាសេចក្ដីយល់សប្តិទៅទាំងអស់ ព្រោះបើប្រសិនជាមានពន្លឺនៅក្នុងលោកមែន មុខជាខ្ញុំបានប៉ះពាល់ខ្លះពុំខានទេ" ។

បំណោរកាលតមក មានគ្រូពេទ្យវិសេសម្នាក់ដ៏ពូកែសក្ដិសិទ្ធមកពិនិត្យអាការរោគ ឃើញថាមានផ្លូវនឹងព្យាបាលឲ្យជាបាន ក៏ផ្សំឧសថ ១ បែប មានថ្នាំ ៤ មុខដាក់ឲ្យបុរសនោះ ។ មិនយូរប៉ុន្មាន ភ្នែកបុរសនោះក៏ជា មើលឃើញពន្លឺបាន ដូចជនទាំងពួង ។ កាលបុរសនោះជាភ្នែកហើយ ទើបផ្ដើមប្រាប់សំឡាញ់ថា "ខ្ញុំជឿថា ក្នុងលោកនេះមានពន្លឺ

មានពណ៌សម្បុរសខ្មៅ . . . មានព្រះអាទិត្យព្រះចន្ទនឹងផ្កាយ . . . មែនពិតហើយ" ។

គ្រូពេទ្យអ្នកព្យាបាលរោគ បានខាងព្រះសព្វញ្ញូពុទ្ធជាបរមគ្រូ ។ សេចក្ដីងងឹតភ្នែក បានខាងសេចក្ដីវៀច សេចក្ដីវង្វេងរបស់មនុស្សដែលយល់ខុសជាត្រូវ មិនស្គាល់សេចក្ដីពិត ។ ថ្នាំ ៤ មុខ បានខាងអរិយសច្ច ៤ គឺ ទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច ។

*
* *

## និទានបុត្រព្រាត់បិតា

គហបតីបុត្រម្នាក់ បានត្រាច់ទៅលេងក្នុងទីក្រុងផ្សេងៗ បែកចិត្តមិនត្រឡប់មកស្រុកវិញ ។ ចំណេរមក បិតាខំប្រកបវណិជ្ជាជីវៈ បានជាអ្នកមានទ្រព្យច្រើនឡើងជាងដើម, ឯបុត្រទៅជាអ្នកកំសត់ ។ ថ្ងៃមួយ បុត្រនោះត្រាច់សុំទានគេតាមច្រកល្ហកនានា ក៏បានដល់ផ្ទះបិតា តែចាំមិនបាន ព្រោះបិតារុះរើភូមិចាស់ផ្លាស់ធ្វើជាថ្មី ។ បិតាឃើញស្គាល់ជាបុត្ររបស់ខ្លួន ក៏មានអំណរណាស់ ប្រើបម្រើឲ្យទៅនាំបុត្រនោះមកជាប្រញាប់ ។

ឯបុត្រដោយឃើញភូមិផ្ទះគេធំប្រហែលវាំងព្រះអង្គម្ចាស់ ក៏គិតថា "អញមានរូបយ៉ាងនេះ ប្រហែលជាគេសំគាល់ថាអញជាចោរ, ដែលគេមកនេះច្បាស់ជាគេមកចាប់ខ្លួនអញហើយ" គិតដូច្នោះហើយក៏ស្ទុះរត់ឥតមើលក្រោយ ។

កាលបិតាឃើញបុត្រស្ទុះរត់ដូច្នោះ ក៏ឲ្យមនុស្សជាច្រើននាក់ស្ទុះដេញតាមចាប់ខ្លួនបានយកមកប្រើឲ្យធ្វើការ មានមនុស្សថែរក្សាស្រួលបួល ទឹងផ្តល់គ្រូមកបង្រៀនសិល្បវិជ្ជា ដើម្បីអប់រំបន្ទុំនិស្ស័យឲ្យត្រឡប់ជាមនុស្សល្អឡើងវិញ ។ កាលឃើញថាបុត្រធ្វើការងាយៗ ទាបៗ បានល្អហើយ ក៏សន្សឹមៗ ដាក់ការក្រៗ ខ្ពស់ៗ ឲ្យធ្វើ ជាការអប់រំនិស្ស័យបុត្រឲ្យប្រណីតល្អិតសុខុមឡើងជាជាន់ៗ ។ លុះបុត្រមានសមត្ថភាពសមគួរហើយ ទើបបានប្រាប់ថា "ខ្លួនជាបិតា" ។ ឯបុត្រកាលបានដឹងដូច្នោះក៏សោមនស្សជាខ្លាំង ។

និទាននេះ ជានិទានប្រៀបធៀបអំពី បិត្តរបស់មនុស្សយើងកាលដែលមិនទាន់បានហាត់ពត់ តែងមានសេចក្តីភ័ន្តច្រឡំយល់ឃ្លាងចាកសេចក្តីពិត, ដល់ចិត្តបានទទួលការហ្វឹកហ្វឺនការអប់រំបន្ទុំនិស្ស័យបន្តិចម្តងៗ ជាលំដាប់ៗ ឡើងទៅ, ក្នុងទីបំផុត ក៏អាចយល់សេចក្តីពិតបានពេញទី ។

ចាប - ពិន

---

ព្រះពុទ្ធជាគ្រូ ពេទ្យធំមហិមា នាមថា "វៃទ្យ គុរុ" មានឫទ្ធិ
ប្រែថា "គ្រូពេទ្យ ជាធំសក្តិសិទ្ធិ លើគ្រូពេទ្យ" ពិត ឥតគេផ្ទឹមបាន ៕

ព. ព.

ដូចម្ដេចបានជាមានពាក្យថា "អាយុមិនទាន់អស់មិនស្លាប់"?

# អាយុ គឺអ្វី?

អាយុ គឺការប្រព្រឹត្តិទៅតាមសភាពនៃសង្ខារទាំងឡាយ ដែលតាំងនៅក្នុងកាមភព, រូបភព និងអរូបភព ដ៏សមគួរដល់សកម្មនៃខ្លួន ៗ ការដល់នូវទីបំផុតនៃសន្តតិកិច្ចរបស់សង្ខារទាំងឡាយនោះ មួយលើកៗ លោកពោលថា "អស់អាយុ" គឺស្លាប់ ៗ

សភាពដែលជាគ្រឿងគាំទ្រនូវអាយុ មាន ៧ យ៉ាង គឺ

កម្ម ១, ភព ១, ធាតុ ១, អាហារ ១, កាល ១, សង្ខារ ១, ធម្មជ្ជិតិ ១, ៗ

អាយុ មានអវិជ្ជាជាមូល អវិជ្ជាមានធាតុ ៥ គឺ អាបោ, តេជោ, វាយោ, បឋវី, អាកាស ជាបច្ច័យ ៗ

## អំពីកម្ម

១ — ធម្មជាតិកកម្ម សំដៅយកអំពើដែលសង្ខារបានតុបតែងឡើង ទៅតាមសភាវៈនៃលោក ៗ

២ — មនោកម្ម សំដៅយកអំពើដែលមនោបានតុបតែងឡើង ទៅតាមសភាពនៃអារម្មណ៍ដែលខ្លួនកំណត់ ហើយញ៉ាំងឲ្យបានសំរេចទៅតាមទ្វារទាំង ៣ ៗ

កម្មទាំង ២ នេះ  អាចញុំាងករណីយកិច្ចនៃខ្លួនឲ្យប្រព្រឹត្តទៅក្នុងកាលទាំង ៣ គឺ អតីត - បច្ចុប្បន្ន - អនាគត ។

## អំពីភព

១ — កាមភព  សំដៅយកទីកើតនៃសត្វលោកដែលប្រកបដោយកាមគុណ ជាគ្រឿងឧបត្ថម្ភ ។

២ — រូបភព  សំដៅយកទីកើតនៃសត្វលោកដែលប្រកបដោយរូប ជាគ្រឿងឧបត្ថម្ភ ។

៣ — អរូបភព  សំដៅយកទីកើតនៃសត្វលោកដែលប្រាសចាករូប ជាគ្រឿងឧបត្ថម្ភ ។

ភពទាំង ៣ នេះ  ជាសន្តតិនៃសង្សារវដ្ត ដែលសត្វមិនទាន់អស់អាសវៈធ្វើឲ្យផុតទៅមិនបាន ។

## អំពីធាតុ

១ — ធម្មធាតុ  សំដៅយកចិត្តនិងចេតសិក ដែលជាធម្មជាតិសម្រាប់ញុំាងរូបធាតុនិងអរូបធាតុទាំងឡាយ ឲ្យគួរដល់កាតព្វកិច្ច ។

២ — រូបធាតុ  សំដៅយកទសន្ទវត្ថុទាំងឡាយគឺទឹក - ដី - ភ្លើង ខ្យល់ - អាកាស  ដែលជាគ្រឿងគាំទ្រលោកឲ្យតាំងនៅជាប្រក្រតី ។

ធាតុទាំង ២ នេះ  ជាសម្ភារៈនៃសឧបាទិន្នកសង្ខារនិងអនុបាទិន្នកសង្ខារ ឲ្យមានឋាមវន្តគ្រប់គ្រាន់ក្នុងការគុបតែងលោក ។

## អំពីអាហារ

១ — កវលិង្កាហារ សំដៅយកដុំអាមិស ដែលត្រូវសត្វបរិភោគ លេបចូលទៅ មានឱជារសអាចនឹងញុំាងធាតុទាំងឡាយ ឲ្យបានចំរើនរឹងប៉ឹងមួនមាំឡើង; ។

២ — ធម្មាហារ សំដៅយកចិត្តចេតសិក នឹងសភាវៈជាគ្រឿង ផ្សព្វផ្សាយឲ្យជ្រួតជ្រាបទៅក្នុងសន្ធតរូបទាំងឡាយ តាមទ្វារទាំង ៦ គឺ ចក្ខុ. សោតៈ, ឃានៈ, ជិវ្ហា, កាយៈ, មនោ;

៣ — ផស្សាហារ បានដល់ការប៉ះពាល់ត្រូវនៃខន្ធ, ធាតុ អាយតនៈ ដែលនាំទៅក្នុងការត្រូវប្រស្រ័យគ្នា ឲ្យចំរើនឡើងឬឲ្យវិនាសទៅ ។

អាហារទាំង ៣ ចំណែកនេះ សម្រាប់ញុំាងសត្វលោកឲ្យមានចិរភាព ទៅតាមយថាភូត ។

បើនិយាយអំពីអាហារសម្រាប់អនុបាទិន្នកសង្ខារវិញ សំដៅយក ដីជាតិនឹងសភាវកិច្ចនៃវត្ថុធាតុទាំងឡាយ ដែលមានសមត្ថកិច្ចញុំាង សកម្មឲ្យគួរដល់ការប្រព្រឹត្តទៅនៃសង្ខារនេះ ។

## អំពីកាល

១ — សំសន្តិកាល សំដៅយកកំរិតពេល, ម៉ោង, ថ្ងៃ, ខែ, ឆ្នាំ ដែលចេះតែកន្លងទៅៗ រកទីបំផុតគ្មាន;

២– បរិច្ឆេទកាល សំដៅយកកំរិតនៃកម្ម, កំរិតនៃធម្មជាតិ, ដែលសន្មតធម៌ទាំងឡាយ បានចាត់ធ្វើឡើងទៅតាមយថាហេតុ ។

កាលទាំង២ នេះជាគ្រឿងគាំទ្រនូវសភាពនៃលោកឲ្យបានតាំងនៅតាមធម្មតា ឬជាគ្រឿងញុំាងសភាពនៃលោកឲ្យប្រែប្រួលប្រាសចាកធម្មតា ។

## អំពីសង្ខារ

១– សឩបាទិន្នកសង្ខារ សំដៅយកការតុបតែងឲ្យកើតឡើងជារូបនិទស្សន៍ក្តី អរូបនិទស្សន៍ក្តី ដែលប្រកបដោយធាតុ, ខន្ធ, អាយតនៈ សម្រាប់សវិញ្ញាណកសត្វ ក្នុងភពទាំងបី;

២– អនុបាទិន្នកសង្ខារ សំដៅយកការតុបតែងឲ្យកើតឡើងជារូបនិទស្សន៍ ដែលផ្សំដោយវត្ថុធាតុទាំងឡាយ គឺ បឋវី, អាបោ, តេជោ, វាយោ, អាកាសោ, ឲ្យបានកើតឡើងជាដុំ, ជាគំនរ ឬ ជាបាច់ ដ៏គួរតាមការណ៍ ។

សង្ខារទាំង ២ ជាធម្មជាតិសម្រាប់ទ្រទ្រង់នូវលោកឲ្យបានតាំងនៅជាប្រក្រតី នឹងជាធម្មជាតិសម្រាប់ធ្វើលោកឲ្យមានការពិសេសប្លែកអំពីគ្នាទៅតាមសភាពនៃខ្លួន នឹងសភាពនៃកម្មរបស់សត្វ ។

## អំពីធម្មដ្ឋិតិ

ធម្មដ្ឋិតិ គឺចិត្តនឹងចេតសិក ដែលជាធម្មជាតិសម្រាប់បណ្តុះនូវ

សវិញ្ញាណកសត្វ ឲ្យកើតពាសពេញនៅក្នុងត្រៃភព ទៅតាមយថាកម្ម ដែលសត្វបានកសាងហើយ ។

សភាវធម៌ទាំង ៧ នេះ ជាគ្រឿងតាំងទ្រទ្រង់អាយុនៃសវិញ្ញាណកជាតិ និងអវិញ្ញាណកជាតិទាំងឡាយឲ្យបានតាំងនៅ តាមសភាពជាធម្មតា ។

សង្ខារដែលអាចប្រព្រឹត្តទៅបាន ក៏មកអំពីសភាវធម៌ទាំង ៧ នេះតាំងនៅតាមប្រក្រតីនៃខ្លួន ។ កាលបើសភាវធម៌ទាំងឡាយនេះប្រាសចាកប្រក្រតីនៃខ្លួនហើយ អាយុនៃសវិញ្ញាណកជាតិ និងអវិញ្ញាណកជាតិក៏ឈ្មោះថាបែកធ្លាយ ។

ហេតុនេះ បានជាមានសុភាសិតថា "អាយុមិនអស់មិនស្លាប់" ប្រែជាសេចក្ដីថា "ការប្រព្រឹត្តទៅនៃសង្ខារមាននៅដរាបណា, ការរស់នៅនៃសវិញ្ញាណកជាតិ និងអវិញ្ញាណកជាតិ ក៏មាននៅដរាបនោះ" ។

មួយទៀត អ្នកវិទ្យាសាស្ត្រទាំងឡាយបានរិះរកនូវការបំរើនឡើង, ការទ្រុឌទ្រោម និងការវិនាសទៅនៃអាយុដោយបច្ចុប្បន្នហេតុ និងបច្ចុប្បន្នផល ក៏បានឃើញនូវពិធីតាំងពារ ២ យ៉ាង គឺវេជ្ជកម្មវិធី ១ អនាមយវិធី ១ ដោយពិសោធនូវរូបនិទស្សន៍ នៃសកម្មរបស់ធាតុ ។

ពិធីទាំង ២ យ៉ាងនេះ នឹងទុកជាស្ថាពរមិនបាន ព្រោះគ្រាន់តែជាគ្រឿងផ្សំធាតុ ដែលនៅមានកំឡាំងគួរឲ្យផ្សំបានប៉ុណ្ណោះ មិនមែន

ជាពិធីសម្រាប់កែប្រែនូវសភាវធម៌ទាំង ៧ នេះទេ ប៉ុន្តែពិធីនេះត្រូវប្រើប្រាស់ ដោយកិច្ចជាស្ពានសម្រាប់ឋានមនុស្ស ។

ហេតុនេះ ឃើញថាអ្នកវិទ្យាសាស្ត្រទាំងឡាយមិនអាចនឹងរិះរកនូវពិធីធ្វើសត្វមិនឲ្យស្លាប់បានឡើយ ។

ព្រះសម្ពុទ្ធជាម្ចាស់ បានរិះរកឃើញមុនគេបង្អស់នូវការកើត-ស្លាប់នៃសវិញ្ញាណកនិងអវិញ្ញាណកជាតិទាំងឡាយ ។ លុះទ្រង់រិះរកឃើញហើយ ទ្រង់ក៏រិះរកនូវពិធីធ្វើមិនឲ្យស្លាប់តទៅទៀត ។ ទ្រង់ត្រិះរិះឃើញថា ការកើតនិងការស្លាប់នេះ នៅជាប់ជាមួយគ្នា បើឃាត់តែការស្លាប់ មិនឃាត់ការកើតផង ឃើញថា ឃាត់មិនបាន ។ ត្រង់នេះពុទ្ធ-សាស្ត្របានបញ្ជាក់ថា អាយុគឺការប្រព្រឹត្តទៅនៃសង្ខារ ដែលមានអវិជ្ជាជាបច្ច័យនេះ តែងមានប្រាកដនៅក្នុងសត្វនិងវត្ថុធាតុនីមួយៗ ដែលមានទស្សនភាពប្រាកដឡើង ។ ប៉ុន្តែជាធម្មជាតិតែងវិនាសទៅដោយអំណាចការបែកធ្លាយនៃសម្ភារធម៌ទាំង ៧ ខាងលើនេះ ជាស្វយប្បវត្តិ ។

លុះទ្រង់រិះរកឃើញនូវព្រំដែននៃការកើត-ស្លាប់យ៉ាងនេះហើយ ទ្រង់ក៏តាំងព្យាយាមធ្វើចិត្តរបស់ព្រះអង្គឲ្យប្រាសចេញស្រឡះអំពីលោកសម្ភារៈ ហើយទ្រង់តាំងព្យាយាមរម្ងាប់ចិត្តនោះ ដោយនិរោធប្បដិបទា គឺទ្រង់តាំងព្យាយាមរម្ងាប់នូវចិត្តដែលជាប់ជំពាក់ដោយកិលេស និងតណ្ហា ទាល់តែចិត្តនោះឃ្លាតចេញអំពីកិលេសនិងតណ្ហាដាច់ស្រឡះ ។

ចិត្តដែលដាច់ស្រឡះអំពីកិលេសនឹងតណ្ហាយ៉ាងនេះក៏ប្រែក្លាយទៅ ជាញាណមួយ ហៅថា "អរហត្តផលញ្ញាណ" ជាញាណសម្រាប់នៅអាស្រ័យក្នុងព្រះនិព្វាន ដែលជាទី គឺការអស់ទៅនឹងតាំងនៅនៃអាយុរបស់សត្វ មិនបានប្រតិស្ឋានទៅផងឡើយ, ព្រោះញាណនេះគ្មានអាយុ ។

ដូច្នេះឃើញថា ពិធីធ្វើមិនឱ្យអស់អាយុមានតែមួយ គឺពិធីធ្វើមិនឱ្យមានអាយុ, តែប៉ុណ្ណោះជាការស្រេច ព្រោះអ្វីដែលកើតឡើងហើយតែងតែវិនាសទៅវិញជាធម្មតា ។

ពាក្យថា "អាយុមិនទាន់អស់មិនស្លាប់" នេះត្រូវពិតហើយ តែជាអាយុមិនមែនជាមិនចេះអស់ទៅនោះទេ ព្រោះអាយុនេះជារបស់អនិច្ចំ, ទុក្ខំ, អនត្តា ។

ពិធីធ្វើមិនឱ្យមានអាយុនេះ មានតែមួយគឺធ្វើចិត្តឱ្យក្លាយទៅជាអរហត្តផលញ្ញាណ ដែលជាញាណគ្មានអាយុ ។ ការធ្វើចិត្តឱ្យក្លាយទៅជាញាណនេះ ជាអំពើមួយយ៉ាងកម្រ ព្រោះចិត្តតែងជ្រកនៅក្នុងកាមាវចរភូមិ, រូបាវចរភូមិ នឹងអរូបាវចរភូមិ ដែលជាភូមិសម្រាប់ទ្រទ្រង់នូវអាយុ ។

សេចក្តីព្យាយាមបង្វែរចិត្តឱ្យងាកចេញពីភូមិទាំង ៣ នេះ ដាច់ស្រឡះឥតវិលត្រឡប់មកវិញបាន ហៅថា អសិថិលបរក្កម: ។ ចិត្ត

ដែលផ្លាស់គេទទៅជាញាណដោយអំណាចសេចក្ដីព្យាយាមនេះ ហៅថា អសិថិលបរក្កមញ្ញាណ ។ នេះ ជាតួអរហត្តផលញ្ញាណ។ នេះហើយ ដែលជាធម្មជាតិ ១ ចូលទៅផ្ចិតនៅក្នុងព្រះនិព្វាន ឥតមានកើត-ចាស់ ឈឺ-ស្លាប់ ។

ការធ្វើចិត្តឲ្យក្លាយទៅជាញាណនេះ ជាការមួយយ៉ាងក្របំផុត ជាងការស្លដែកឲ្យក្លាយជាពេជ្រទៅទៀត, ប៉ុន្ដែការទាំង ២ នេះ លោកអាចយកមកប្រៀបគ្នាបានដោយល្បឿន ។

ជាងដែកយ៉ាងពិសេសអាចយកដែកដុលមកស្ល ឲ្យនៅសល់តែសាច់ដែក, យកសាច់ដែកនោះមកស្លឲ្យនៅសល់តែទឹកដែក, យកទឹកដែកនោះមកស្លឲ្យខះរឹងទៅជាដុំពេជ្រមានពន្លឺផ្លេក នេះឧបមាយ៉ាងណា; ការធ្វើចិត្តឲ្យក្លាយទៅជាអរហត្តផលញ្ញាណ ក៏ឧបមេយ្យយ៉ាងនោះដែរ ។

ពិធីធ្វើឲ្យអស់សេចក្ដីស្លាប់ត្រូវស្លចិត្តយ៉ាងនេះ ។

តែ-ជុន

ទស្សនាវដ្ដី ទុកដូចជា ប្រទីបឆ្លាណ ដ៏ភ្លឺពិត
អ្នកមានទស្សនា—វដ្ដីមិត្ត... ទុកអែបនែបជិត រាល់វេលា ។
ដូចមានប្រទីប ទុកជិតប្រាណ ត្រូវការមើលអាន ម្ដងមួយគ្រា
ប្រាជ្ញាភ្លឺស្វាង ដូចឆ្លាណ លោក—អ្នករាល់គ្នា គួរតែមាន។

ប. ព.

អក្សរសាស្ត្រ ជាគោលរបស់ជាតិ
វិន័យលោកនាថ ជាគោលនៃសាសនា
ព្យាយាម ជាគោលអ្នកសិក្សា
ភស្ដា ជាគោលនៃមហេសី

## អារម្ភកថា នៃអក្សរសាស្ត្រខ្មែរ

ខ្ញុំមានបំណងចង់សរសេរសៀវភៅអក្សរសាស្ត្រខ្មែរជាយូរហើយ, ដល់ខ្ញុំបានកាន់មុខងារជាអធិបតីសមាគមមិត្តសាលាបាលី ពីថ្ងៃទី ៥ ខែសីហា គ.ស. ១៩៤៩ មក គំនិតនេះក៏រឹតតែដុះក្នុងហទយវត្ថុរបស់ខ្ញុំជានិច្ចថែមឡើងទៀត, ទើបខ្ញុំបានចាត់ការស្ថាបនា នូវគណៈកម្មការស្រាវជ្រាវអក្សរសាស្ត្រខ្មែរ ពីថ្ងៃទី ៨ ខែវិច្ឆិកា ១៩៤៩ ដើម្បីនឹងរករកមធ្យោបាយផ្សេងៗ ព្រមទាំងព្យាយាមធ្វើដំណើរការនេះតមក, តែមានឧបសគ្គមកកាំងកជាខ្លាំងដោយខ្វះឯកសារ ទំនងដោយលំបាកក្នុងការស្រាវជ្រាវរកប្រវត្តិនៃបណ្ឌិតខាងអក្សរសាស្ត្រខ្មែរ ៗ

ដោយឆន្ទៈចង់ឲ្យកើតសៀវភៅអក្សរសាស្ត្រខ្មែរកាន់តែខ្លាំងក្លាឡើង ទើបប្រជុំគណៈកម្មការអក្សរសាស្ត្រខ្មែរ ពីថ្ងៃ ២៦ ខែវិច្ឆិកា ១៩៤៩ ចាត់កម្មវិធីដូចតទៅនេះ:

១ – ស្រាវជ្រាវរកនាមទីឯស្នាដៃអ្នកប្រាជ្ញខាងអក្សរសាស្ត្រខ្មែរ តាំងពីសតវត្សទី ១ មកដល់សតវត្សទី ១៩

២ – ធ្វើជីវប្រវត្តិអ្នកប្រាជ្ញទាំងនោះ

៣ – ធ្វើរូបសំណាក (Cliché)

៤ – ប្រមូលរឿងរ៉ាវដែលអ្នកប្រាជ្ញនោះៗ តែងមករៀបចំតាមលំ-ដាប់សតវត្ស ។

កិច្ចការទាំងនេះ សមាគមមិត្តសាលាបាលី រកបានរូបសំណាក នឹងជីវប្រវត្តិជាដើមខ្លះហើយ, បំណែកអ្នកប្រាជ្ញខាងអក្សរសាស្ត្រខ្មែរពីសតវត្សទី ១ សម័យហ្វូណន៍មកទល់នឹងសម័យអង្គរ ឬ លង្វែក រកពុំទាន់បាន ដោយលំបាកស្រាវជ្រាវពន់ពេក ។

អត្ថបទទាំងឡាយក្នុងសៀវភៅនេះ ខ្ញុំបានដកស្រង់ខ្លះពីសិលាចារឹក, ពីកាសាសំស្ក្រឹតនឹងបាលីយកមកចុះតាមលំដាប់ ។

រឿងអក្សរសាស្ត្រខ្មែរនេះ ខ្ញុំប្រមូលតាំងពីអក្សរសាស្ត្រសតវត្សទី ១ មកទល់នឹងសតវត្សទី ១៩ តែម្តង ។

រឿងនេះ បើតាមពិនិត្យឲ្យច្បាស់លាស់ មិនបានពេញជារឿងអក្សរសាស្ត្រខ្មែរទេ ព្រោះខ្លះឈ្មោះបណ្ឌិតដែលមិនស្គាល់ ឬ រកមិនឃើញជាច្រើនណាស់ ។ ខ្ញុំសូមអភ័យទោសពីបណ្ឌិតទាំងឡាយ

ចំពោះការខ្វះខាតនេះ, បើមានខ្វះខាត ឬខុសលើសលោះត្រង់ណា សូមបណ្ឌិតខាងអក្សរសាស្ត្រខ្មែរក្នុងសម័យបច្ចុប្បន្ននឹងសម័យអនាគត បំពេញថែមថយឱ្យបាន ហើយសូមផ្ញើសេចក្ដីកែនោះទៅខ្ញុំ, បើខ្ញុំឃើញថាគួរដល់បោះពុម្ពលើកក្រោយនឹងកែតាម, ខ្ញុំសូមទទួលអរគុណលោកទុកជាមុន ក្នុងការដែលបានជួយបំពេញសេចក្ដីខ្វះខាតនោះ ព្រោះពិបាកស្រាវជ្រាវណាស់ ដោយសៀវភៅ ឬ សាស្ត្រាស្លឹករឹតនានាពីបុរាណ ច្រើនតែមិនមានដាក់ឈ្មោះអ្នកនិពន្ធនឹងមិនដាក់សករាជ, ដាក់តែនាមអ្នកចារ ហើយនឹងពាក្យប្រាថ្នាប៉ុណ្ណោះ ។

សមាគមមិត្តសាលាបាលី មានបំណងនឹងផ្ញើរឿងអក្សរសាស្ត្រខ្មែរនេះឱ្យមានរបៀបរៀបរយតាំងពីសតវត្សទី ២០ នៃគ្រិស្តសករាជ ឬសតវត្សទី ២៤ នៃពុទ្ធសករាជតទៅ គ្រាន់ជាប្រដាប់សតិបញ្ញា សម្រាប់ប្រជាជនជាតិខ្មែរសិក្សាដើម្បីឱ្យស្គាល់នាម ឬជីវប្រវត្តិនៃបណ្ឌិតខាងអក្សរសាស្ត្រ សាស្ត្រខ្មែរ ដើម្បីនឹងរក្សាកិត្តិនាមនៃបណ្ឌិតទាំងនោះទុកក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា ជាហេតុញុំាងអក្សរសាស្ត្រខ្មែរ ឱ្យចំរើនតទៅអនាគត ។

ភ៉យ — ប៊ុក

អ្នកមិនធ្វើ, មិនខុស

# វគ្គទី ១

## ភាសាសាស្ត្រសាកល

### ១– បុព្វហេតុ

ភាសា, បើតាមឯកឧត្ដម អៀវ-កើស អតីតប្រធានរដ្ឋសភាកម្ពុជរដ្ឋ លោកបាននិពន្ធទុកក្នុងសៀវភៅមួយ នាម "ភាសាខ្មែរ" ភាគទី ១ ថា: "ភាសាជាការសំដែងចិត្តគំនិតដោយពាក្យសំដី" ភាសាគឺការបញ្ចេញសំឡេងមកក្រៅដែលជាផលនៃគំនិតរបស់ចិត្ត គឺសំឡេងរបស់ចិត្តនោះឯង ។ ភាសា, បើតាម "វចនានុក្រមខ្មែរ" ប្រែថា "សំដី, ពាក្យ" ។ តែយើងមិនអាចនឹងរកឃើញនូវបុព្វហេតុនៃភាសា មានភាសាមនុស្ស, សត្វ ជាដើម ។ អ្នកប្រាជ្ញខាងភាសាសាស្ត្រប្រទេសអឺរ៉ុបបានព្យាយាមស្រាវជ្រាវរកបុព្វហេតុ នៃភាសារបស់មនុស្ស ក៏រកមិនឃើញមិនយល់, ប្រៀបដូចជាម្ជុលមួយបោះទៅក្នុងទន្លេ ដូច្នោះ, ប្រាជ្ញមនុស្សសាមញ្ញ មិនអាចចាក់ធ្លុះនូវធម៌ដែលជ្រាលជ្រៅពន់ពេកដូចភាសាឡើយ ។ លោកអេតមង់សែញេ (Edmond Ghaignet) បានពោលទុកក្នុងសៀវភៅ នាម "ទស្សនវិជ្ជានៃវិទ្យាសាស្ត្រខាងភាសា (La philosopbie du langage)" ថា: "គ្មានអ្នកប្រាជ្ញណាអាចរកឃើញសំឡេងដំបូង ឬបុព្វហេតុនៃភាសាសត្វ, មនុស្សនោះទេ ។ មានអ្នកប្រាជ្ញ

ខុះបានចំស្រាវជ្រាវរក តើភាសាជាតិក្នុងសកលលោកដែលមានសំឡេង ខុសគ្នា តែសំដែងចិត្តគំនិតដូចគ្នា ដូចពាក្យថា: Manger ស៊ី, Ang គិន Chéak ជាដើម តាមជាតិសត្វៗខ្លួន; គួរឲ្យសង្ស័យពន់ពេកណាស់ ហេតុដូចម្ដេចបានជាពាក្យមានសូរសំឡេងខុសគ្នា តែមានន័យដូចគ្នា?, ក្នុងរឿងនេះលោកបូឌ្រី (F. Baudry បានសរសេរទុកក្នុងសៀវភៅមួយនាម "វេយ្យាករណ៍ប្រៀបធៀបភាសានឹងសូរសាស្ត្រ (Grammaire comparée des langues phonétique) ថា: "ពាក្យសំដីដែលជាតិក្នុងសកលលោកពោលគ្រប់ៗគ្នាមិនអាចនឹងប្រៀបធៀបគ្នាបាន បើមិនស្រាវជ្រាវរកនូវបុព្វហេតុនៃសំឡេងផ្សេងៗ នោះឲ្យដល់ឯកភាព គឺសំឡេងដំបូង; កិច្ចការទាំងនេះនឹងធ្វើបាន លុះត្រាតែយកសេចក្ដីប្រៀបធៀបនោះមកត្រិះរិះរកដោយសុខុមភាពតាំងពីវត្ថុធាតុដែលជាឫសគល់នៃអក្សរ ហើយត្រូវកត់ត្រានូវភាពនឹងលក្ខណៈនៃសំឡេងដែលដូចគ្នា នឹងភាពសំឡេងដែលខុសគ្នា រួចទើបប្រៀបធៀបសំឡេងណាខ្ពស់, ទាប, ខ្លី, វែង, ធ្ងន់, ស្រួយ, ស្រាល, គ្រលួចជាដើម ដែលគេហៅថាសូរសាស្ត្រ (Phonétique) គឺវិជ្ជាស្ដាប់សូរសំឡេងនៃភាសា ។

## ២ — សមាសភាព

ក) ភាសាគឺគំនិតរបស់មនុស្សសន្មតប្រើតាមសំដីសត្វៗខ្លួន; គំនិតនោះមានសភាពច្រើនបែប-យ៉ាង, លោកវ៉ង់ឌ្រី (J. Vendryes) សាស្ត្រា

ចាប់នៅសាលាឧត្តមវិជ្ជាប៉ារីស, លោកបានពោលទុកនៅសៀវភៅ "ភាសាសាស្ត្រ (Le langage) ថា: "ភាសាមានច្រើនយ៉ាង, បើញែកទៅតាមអារម្មណ៍មាន ៤ យ៉ាង គឺភាសាដែលកើតពីឃានប្បសាទ (langage olfactif) ១, ភាសាដែលកើតពីសម្ផស្សឬកាយបសាទ (langage tactile) ១, ភាសាដែលកើតពីចក្ខុបសាទ (langage visuel) ១, ភាសាដែលកើតពីសោតបសាទ (langage auditif) ១,

២) ភាសាបើពោលដោយហេតុមាន ៤ យ៉ាង គឺ

១ – ភាសាកើតពីបឋមហេតុ (langage primitif);

២ – ភាសាសត្វតិរច្ឆាន (langage des animaux, des oiseaux);

៣ – ភាសាមនុស្សព្រៃ (langage des sauvages);

៤ – ភាសាមនុស្សសាមញ្ញ (langage des hommes, des races);

១ – ចំណែកភាសាដែលកើតពីបឋមហេតុនោះ គឺភាសាដែលកើតដំបូងបង្អស់គង់លោកធាតុ: បញ្ហានេះមានអត្ថដ៏គម្ភីរភាពហើយលាយឡំជាមួយគ្នានឹងបុព្វហេតុនៃមនុស្សនឹងបឋមហេតុនៃសង្គមរបស់មនុស្សឯណោះ:

២ – ភាសាសត្វតិរច្ឆានមានសត្វចតុប្បាទទ្វិបាទជាដើម, សំឡេងដែលសត្វទាំងនោះស្រែកយំមានលក្ខណៈច្រើនបែប – ស្ថាន ដូចជាសេកមួយហើរទៅឃើញដើមស្វាយមួយដើមមានផ្លែទុំជាច្រើន ស្រាប់តែហើរ

វិលត្រឡប់មកវិញបបួលប្រែពន្ធក្ដួនក្ដួកទកជាច្រើន មកអាស្រ័យស្វាយ នោះបាន, នេះជាភាសាសេកបក្សា, សត្វខ្លះមានសំឡេងខ្លឹង, ស្អប់, ស្រឡាញ់, មានសំដែងចិត្តមេត្តា, សត្វខ្លះចេះធ្វើពលិកម្ម (sacrifice) ឬជីវិតនឹងម្ចាស់កដូចជាសុនខជាដើម ។ ឧទាហរណ៍ប៉ុណ្ណោះនាំឲ្យឃើញថាសត្វតិរច្ឆានមានភាសាមួយបែប បើពិនិត្យឲ្យច្បាស់លាស់ឃើញថាវិជ្ជាមួយយ៉ាងដែរ ។ អ្នកណាថាសត្វបង់មិនដឹងអី, ប៉ុន្តែបណ្ដាសត្វទាំងអស់ សត្វដែលមានកុសលច្រើន ជិតបានមកបដិសន្ធិជាមនុស្សជាងគេ គឺដំរី នឹងសុនខ;

៣ – ភាសាមនុស្សព្រៃ គឺភាសាមួយដែលមានការសំដែងទឹកចិត្តជាមូល តែមានលក្ខណៈសភាវៈដូចភាសាប្រជាជាតិស៊ីវិល័យដែរ, ភាសាមនុស្សព្រៃនឹងភាសាទារក ដែលទើបនឹងចេះពោលពាក្យមិនច្បាស់រអាក់រអួល ទើសៗ ទាក់ៗ ក៏ប្រហែលៗ គ្នា៖

៤ - ភាសាមនុស្សសាមញ្ញ គឺភាសាជាតិទាំងអស់ក្នុងសកលលោក, ភាសានេះមានពីរយ៉ាង គឺ មាតុភាសា (langue mère) នឹងភាសាឯទៀតមានគ្រាមភាសា (dialecte) ជាដើម ។

(មានត)

សំដីជាឯក, លេខជាទោ

# អនុមោទនកថា នៃខេមរវេយ្យាករណ៍

កាលពីថ្ងៃសុក្រ ១៤ រោច ខែស្រាពណ៍ ឆ្នាំថោះ ត្រីស័ក ព.ស. ២៤៩៤ (៣១ សីហា គ.ស. ១៩៥១) ភិក្ខុមហា ពេជ្រ-ម៉ាន់ (ធម្មកេសរេ) សិស្សសាលាបាលីជាន់ខ្ពស់ ថ្នាក់ឆ្នាំទី ២ (ខ) នៅវត្តលង្កា បានយកសំណៅសៀវភៅខេមរវេយ្យាករណ៍នេះ មកឲ្យខ្ញុំពិនិត្យកែសម្រួល ខ្ញុំកំពុងមានកិច្ចការរវល់ស្ទើររើខ្លួនពុំរួច ប៉ុន្តែបានបើកមើលទ្រួសៗ ភ្លាមទៅឃើញមានរបៀបរៀបរៀងគួរពេញចិត្ត គួរទទួលអនុមោទនាត្រេកអរជាមួយផង, ដោយយល់ឃើញថា សៀវភៅនេះ បើទុកជាមានរបៀបការខ្វះខាតខ្វះបន្តិចបន្តួច, ក៏គង់មានប្រយោជន៍ដ៏សំខាន់ជាជំនួយការសិក្សាអក្សរសាស្ត្រខ្មែរ ជាគ្រឿងដឹកនាំកុលបុត្រកុលធីតាជាតិខ្មែរ ឲ្យមានការចេះដឹងលូតលាស់ចំរើនតាមលំដាប់កាលទៀងពុំខាន ។ ដោយយល់ឃើញដូច្នេះ, ខ្ញុំក៏ឆ្លៀតជួយពិនិត្យផ្ទៀងផ្ទាត់កែសម្រួលបន្តិចម្តងៗ ដរាបដល់ចប់ ។ តាមយោបល់របស់ខ្ញុំថា សៀវភៅនេះ អាចរាប់បញ្ចូលក្នុងការសិក្សាអក្សរសាស្ត្រខ្មែរបានដោយពេញទី ។ មួយទៀតខ្ញុំមានសង្ឃឹមថា គង់នឹងមានវេយ្យាករណ-បណ្ឌិតឯទៀតមានព្យាយាមខំប្រឹងតែង ឬរៀបរៀងសៀវភៅ សម្រាប់សិក្សាអក្សរសាស្ត្រខ្មែរ ឲ្យកាន់តែមានបរិបូណ៌ឡើងទៀតពុំខាន ។

ថ្ងៃទី ១៦ កញ្ញា ២៤៩៤ / ១៩៥១

សម្តេចព្រះមហាសុមេធាធិបតី

(ជោតញ្ញាណោ) ជ. ណ.

# ខេមរវេយ្យាករណ៍

## អក្សរ

(១) ស្នាមគំនូសមានតួពាងផ្សេងៗ សម្រាប់ប្រើសរសេរកត់ពាក្យសំដីនឹងសេចក្ដីទាំងពួង ប្រើមិនចេះអស់ប្ដូមិនរើង ហៅថា "អក្សរ", ចែកចេញជាពីរពួក គឺ ស្រៈ នឹង ព្យញ្ជនៈ ។

## ស្រៈ

(២) អក្សរដែលអាចបញ្ចេញសំឡេងខ្លួនឯងបានផង អាចនាំព្យញ្ជនៈឲ្យចេញសំឡេងបាន មានសូរឮតាមរំពងរបស់ព្យញ្ជនៈផង ហៅថា "ស្រៈ" ។

ស្រៈសម្រាប់ប្រើក្នុងភាសាបាលីមាន ៨ តួ គឺ អអា, ឥឦ, ឧឩ, ឯឱ ។ សម្រាប់ប្រើក្នុងភាសាសំស្ក្រឹតមាន ១៣ តួ គឺ អអា, ឥឦ, ឧឩ, ឫឬ, ឭ, ឯឰ, ឱឳ; ថែមស្រៈឮដោយឡែកមកទៀតជា ១៤ តួ ។ សម្រាប់ប្រើក្នុងភាសាខ្មែរ (សម័យបច្ចុប្បន្ននេះ), រាប់ស្រៈដែលផ្សំជាមួយនឹងនិគ្គហិត នឹងវិសជ្ជនីយផង មាន ២១ តួ គឺ អអា. អិអី, អឹអឺ, អុអូ, អួអើ, អឿអៀ, អេអែ. អៃអោ អៅអុំ អំអាំ អះ; រាប់ទាំង ឫឬ. ឭឮ នឹងស្រៈ ឳ ផង ជា ២៦ តួ ។ ស្រៈទាំងនេះ លើកតែ ឫឬ, ឭឮ, នឹង ឳ ចេញ ចែកជា ២ យ៉ាង គឺ ស្រៈសុទ្ធដែលចេញសំឡេងតាមទំនើងខ្លួនឯង

ហៅថា ស្រៈពេញតួ (ត្រូវសរសេរពេញតួ): អ អា, ឥ ឦ, ឧ ឩ, ឯ ឰ, ឱ ឳ; ឬ អ អា, អិ អី អឹ អឺ, ។ល។ អោ អៅ អុំ អំ អាំ អះ; ស្រៈមិនពេញតួ ដែលប្រើផ្សំជាមួយនឹងព្យញ្ជនៈ ហៅថា ស្រៈផ្សំ ត្រូវសរសេរតំនួសដូច្នេះ

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ,

ផ្សំជា ក កា កិ កី កឹ កឺ ។ល។ កោ កៅ កុំ កំ កាំ កះ, ឬ ផ្សំជាមួយនឹងស្រៈអ ពេញតួជា អ អា អិ អី ។ល។ អុំ អំ អាំ អះ ផង ក៏បាន ។

ស្រៈពេញតួនោះ គឺស្រៈប្រើជាតួអក្សរដូចតួព្យញ្ជនៈដែរ ដូចពាក្យថា អគុណ, អាគ្នេយ៍, អាចារ្យ, ឥឡូវនេះ ឦសាន, ឧត្តរ, ឩស្សាហ៍, ឪឡឹក ដើមឪឡោក, ឫក្សពារ, ឬស្សី, មែនឬទេ?, ឮកណាស់, ខ្ញុំឮហើយ, ឯណា, ឰង៉, ព្រះឧស្ឋ, ក្រឪ... ជាដើម ។

ឯស្រៈផ្សំនោះ គឺស្រៈដែលផ្សំនឹងព្យញ្ជនៈ ទើបប្រើបាន ដូចជា "សូម, លេង, ទៅ, បាន ...ជាដើម ។ ស្រៈផ្សំនេះអាចនាំព្យញ្ជនៈឲ្យចេញសំឡេងបាន មានសូរព្ទ តាមព្យញ្ជនៈដែលជាឃោសៈនឹងអឃោសៈ, ប៉ុន្តែស្រៈ ៣ តួ គឺ ួ ឿ ៀ នេះ ទោះបីជាក៏ផ្សំនឹងព្យញ្ជនៈ មានសំឡេងគឹកកង៏ក្តី មិនគឹកកង៏ក្តី ក៏នៅតែបញ្ចេញសំឡេងដូចគ្នា ដូចជាអក្សរ ក អានថា កួ កឿ កៀ, អក្សរ គ ក៏អានថា គួ គឿ គៀ ដែរ បែបនេះជាតួយ៉ាង ។

# ព្យញ្ជនៈ

(៣) អក្សរក្រៅពីស្រៈដូចពោលមកហើយ ហៅថា “ព្យញ្ជនៈ” ប្រែថា ‘ អក្សរធ្វើនូវសេចក្ដីឲ្យប្រាកដ” ។ ព្យញ្ជនៈនោះមាន ៣៣ តួ គឺ ក ខ គ ឃ ង ច ឆ ជ ឈ ញ ដ ឋ ឌ ឍ ណ ត ថ ទ ធ ន ប ផ ព ភ ម យ រ ល វ ស ហ ឡ ំ[១] ។

ព្យញ្ជនៈទាំង ៣៣ តួនេះ ហៅថា “និស្សិត ប្រែថា អក្សរលុះណាតែអាស្រ័យនូវស្រៈផង ទើបបញ្ចេញសូរស័ព្ទបាន” គឺថាព្យញ្ជនៈទាំងអស់ លុះតែអាស្រ័យនឹងស្រៈផង ទើបអាចបញ្ចេញសំឡេងបាន ប៉ុន្តែមានសមត្ថភាពអាចនាំស្រៈដែលខ្លួនអាស្រ័យនោះ ឲ្យលាន់ឮតាមរំពងរបស់ខ្លួនផងដែរ ហើយធ្វើនូវសេចក្ដីឲ្យច្បាស់លាស់ប្រាកដឡើងផង; ឯស្រៈពិតមែនតែបញ្ចេញសំឡេងតាមទំនើងខ្លួនឯងបាន ប៉ុន្តែមិនអាចធ្វើសេចក្ដីឲ្យច្បាស់លាស់ថាជាអ្វី ដោយខ្លួនឯងទាំងអស់នោះបានទេ ដូចជាពាក្យថា “ទៅណា កុំដើ...” បើប្រសិនជាសរសេរសុទ្ធតែស្រៈថា “េ–ៅ–ា ុំ េ–ើ” ដូច្នេះ នឹងយកសេចក្ដីថាជាអ្វីពុំបាន, លុះតែដាក់ព្យញ្ជនៈចូលមកជាមួយផង នោះទើបដាក់ប្រាកដថា “ទៅណា កុំដើ” ឡើងបាន ។

ប្រមូលសេចក្ដីដោយខ្លីថា ស្រៈផ្សំហើយនឹងព្យញ្ជនៈនេះ លុះណាតែអាស្រ័យនូវគ្នានឹងគ្នា នោះទើបយកមកប្រើកើត ខ្វះណាមួយមិនបាន ។

---

១ មានសូរសំឡេងថា « អ័ង » ។ ប៉ុន្តែជនជាតិដទៃខ្លះ គេថា « អុំម » ខ្លះថា « ម៉ឹ » ព្រោះគេឲ្យសំឡេងនៅរស់ គឺនៅមានសូរឮទៅតាមស្រៈ ។

ព្យញ្ជនៈទាំង ៣៣ តួនោះចែកចេញជា ២ ពួកគឺវគ្គ ១, អវគ្គ ១, ។ វគ្គចែកចេញទៅទៀត មាន ៥ ពួក ក្នុងពួកមួយៗ មានអក្សរ ៥ តួ ។ គឺ កខគឃង ៥ តួនេះ ហៅថា ពួកអក្សរ ក, ចឆជឈញ ៥ តួនេះ ហៅថា ពួកអក្សរ ច, ដឋឌឍណ ៥ តួនេះ ហៅថា ពួកអក្សរ ដ, តថទធន ៥ តួនេះ ហៅថា ពួកអក្សរ ត, បផពភម ៥ តួនេះ ហៅថា ពួកអក្សរ ប ។ ព្យញ្ជនៈ ទាំង ២៥ តួនេះ ជាពួកៗ តាមវិធីតម្រួតគ្នា ឯវិធីដែលតម្រួតគ្នានោះដូច្នេះ:

ព្យញ្ជនៈទី ១ ត្រូវតម្រួតលើតួឯង ទឹងលើព្យញ្ជនៈ ទី ២; ព្យញ្ជនៈទី ៣ ត្រូវតម្រួតលើតួឯងទឹងលើព្យញ្ជនៈទី ៤; តាមលំដាប់វគ្គ របស់ខ្លួនៗ, ព្យញ្ជនៈទី ៥ ត្រូវតម្រួតលើព្យញ្ជនៈទាំង ៤ តួក្នុងវគ្គរបស់ខ្លួនៗបាន ទឹងលើតួឯងបានដែរ លើកតែ "ង" មួយចេញ ដែលទឹងតម្រួតលើតួឯងពុំបាន ។ ព្យញ្ជនៈក្នុងអវគ្គ ៣ តួ គឺ យ, ល, ស នេះ តម្រួតលើតួឯងបាន ។

ពាក្យដែលបានពោលមកនេះ ចំពោះតែព្យញ្ជនៈដែលមានកំណត់ត្រូវតម្រួតគ្នា តាមលំដាប់វគ្គទឹងតម្រួតគ្នាលើតួឯង ។ នៅមានវិធីផ្សេងពីនេះទៅទៀត គឺព្យញ្ជនៈជាវគ្គតម្រួតគ្នា លើព្យញ្ជនៈជាអវគ្គ ឬ ក៏ព្យញ្ជនៈជាអវគ្គតម្រួតគ្នាលើព្យញ្ជនៈជាអវគ្គតួផ្សេងគ្នា ។

អវគ្គ ប្រែថា ព្យញ្ជនៈឥតពួក" ព្រោះមិនមានពួកតាមវិធីតម្រួត ឡើយ, ឬ ហៅថាសេសវគ្គ ប្រែថា "ព្យញ្ជនៈសល់ក្រៅពីពួកក៏បាន; មាន ៨ តួ គឺ យ, រ, ល, វ, ស, ហ, ឡ, អំ ។

ព្យញ្ជនៈទាំងអស់មានសូរសំឡេងជាពីរពួក គឺព្យញ្ជនៈមាន សំឡេងតូច ហៅថា អឃោសៈ ១ ពួក, ព្យញ្ជនៈមានសំឡេងធំ ហៅថា ឃោសៈ ១ ពួក ។

ពួកអក្សរអឃោសៈ គឺ កខ, ចឆ, ដឋ, តថ, បផ, ស, ។

ពួកអក្សរឃោសៈ គឺ គឃង, ជឈញ, ឌឍណ, ទធន, ពភមៈ យ, រ, ល, វ, ហ, ឡ[1] ។ អក្សរខាងចុងវគ្គទាំង ៥ នឹងខាងចុងសេសវគ្គ ឈ្មោះនិគ្គហិត គឺ ង, ញ, ណ, ន, ម, អំ ។

បណ្ដាព្យញ្ជនៈទាំងអស់ ព្យញ្ជនៈពួកខ្លះមានសំឡេងតែមួយ, ខ្លះ ទៀតមានសំឡេងផ្សំ ។ តួព្យញ្ជនៈដែលមានសំឡេងតែមួយ ហៅ ថា សិថិល (ធូរ), តួដែលមានសំឡេងផ្សំ ហៅថា ធនិត (តឹង) ។

អក្សរសិថិល គឺ កគ, ចជ, ដឌ, តទ, បព, យ, រ, ល, វ, ស, ហ, ឡ នឹង និគ្គហិត គឺ ង, ញ, ណ, ន, ម, អំ ។

អក្សរធនិត គឺ ខឃ, ឆឈ, ឋឍ, ថធ, ផភ ។ ធនិតនេះបានជាថាមាន សំឡេងផ្សំ ព្រោះអក្សរសិថិលផ្សំនឹង "ហ" បង្កើតបានជាធនិត ដូចជាៈ

---

១ ឯអក្សរ "អំ" បើផ្អែកខាងភាសាសំស្ក្រឹតចាត់ជាឃោសៈ, ផ្អែកខាងភាសាបាលី ចាត់ជាឃោសាឃោសវិមុត្ត គឺរួចស្រឡះចាកឃោសៈនឹងអឃោសៈ ។

| សិថិល | សិថិលទឹងហ | បង្កើតជាធនិត | សំឡេងធនិត |
|---|---|---|---|
| ក | ក + ហ | ខ | ក្ហ |
| គ | គ + ហ | ឃ | គ្ហ |
| ច | ច + ហ | ឆ | ច្ហ |
| ជ | ជ + ហ | ឈ | ជ្ហ |
| ដ | ដ + ហ | ឋ | ដ្ហ |
| ឌ | ឌ + ហ | ឍ | ឌ្ហ |
| ត | ត + ហ | ថ | ត្ហ |
| ទ | ទ + ហ | ធ | ទ្ហ |
| ប | ប + ហ | ផ | ប្ហ |
| ព | ព + ហ | ភ | ព្ហ |

វេលាដែលមាន ត្រូវថាត្តួលសំឡេងពីអក្សរសិថិលទៅផ្សំទឹងអក្សរ 'ហ', សម្រួលសំឡេងសិនថា កហ = ក្ហ (ខ), គហ = គ្ហ (ឃ) ។ល។ ចហ = ច្ហ (ឆ), ពហ = ព្ហ (ភ) គឺជម្រាលសំឡេងពី "ក" ទៅ "ហ", ពី "គ" ទៅ "ហ" ។ល។ ពី "ច" ទៅ "ហ",

ពី "ព" ទៅ "ហ" ហើយសិម្រកសោបធក់ផ្ដាច់សំឡេងអក្សរទាំងពីរតួ ឲ្យទៅជាសំឡេងតែមួយ ។

អក្សរ "ហ" នេះ គ្រាន់តែជាជំនួយនាំអក្សរសិថិលឲ្យក្លាយទៅជាធនិត មានសំឡេងតឹងខ្លាំងជាងប្រែក្រតីដើមរបស់ខ្លួនប៉ុណ្ណោះ មិនមែនទាញសំឡេងឲ្យក្លាយមកតាមអំណាចខ្លួនទេ ព្រោះអក្សរធនិតទាំងនោះសុទ្ធតែមានសំឡេងអក្សរសិថិលដែលជាគូនឹងខ្លួនជាគោល (១) ។

## គរុនិងលហុ

អក្សរគរុនោះគឺស្រៈណាជាទីឃៈអក្សរដូចៈ -ា -ី -ឹ -ូ -ួ -ើ -ឿ -ៀ -េ -ែ -ៃ -ោ -ៅ អស់នេះ ហៅថា ទីឃគរុ ។

មួយទៀតត្រូវឲ្យចូលចិត្តកងវិធីបំបែកអក្សរ ក កា ដូចេះ: កា កី កឹ កូ កួ កើ កឿ កៀ កេ កែ កៃ កោ កៅ ។ល។ ខ្លា ខ្លី ខ្លឹ ខ្លូ ខ្លួ ខ្លើ ខ្លឿ ខ្លៀ ខ្លេ ខ្លែ ខ្លៃ ខ្លោ ខ្លៅ ហៅថា ទីឃគរុ ។ តួនិគ្គហិត គឺ កុំ កំ កាំ ។ល។ ខ្លុំ ខ្លំ ខ្លាំ ហៅថា និគ្គហិតគរុ ។ មួយវិញទៀត តួណាជាស្រៈអក្សរដែលនៅខាងដើមតួសំយោគ ដូចជា: អត្ត, យក្ខ, មគ្គ, វគ្គ, ជាដើម យ៉ាងនេះ ហៅថា សំយោគគរុ ។

---

១ ក + ហ > ខ; គ + ហ៊ > ឃ; ច + ហ > ឆ; ជ + ហ៊ > ឈ; ។ល។

ម្យ៉ាងទៀត ពាក្យណាជាពាក្យត្រូវសង្កត់ខ្យល់ឲ្យដូចក្នុងមេ កក់ កង កច កញ កត កន កប កល កស កយ ក៏ហៅថា គរុ ដូចគ្នា ។ តួស្រៈសំស្ក្រឹត គឺ អា ឦ ឩ ឫ ឭ ឯ ឰ ឱ ឳ ក៏ហៅថា ទីឃគរុ ។

ឯអក្សរលហុនោះ គឺតួរស្សៈស្រៈ ដូចជាតួ ៈ ិ ឹ ុ ះ ។ ឲ្យចូលចិត្តក្នុងការបំបែកអក្សរ ក កា ដូច្នេះ គឺ ក កិ កឹ កុ កះ ។ល។ ឡ ឡិ ឡឹ ឡុ ឡះ ។

តួព្យញ្ជនៈទាំង ៣៣ តួ មាន ក ជាដើម ហៅថា លហុ ទាំងអស់ ។ មួយទៀត ស្រៈណាជាទីឃៈ តែត្រូវជាពាក្យប្រើវិសជនីយវិញ ដូចជា នេះ នោះ ប្នេះ ប្នោះ ជាដើម យ៉ាងនេះ ក៏ហៅថា លហុ ដែរ ។

ស្រៈក្នុងសំស្ក្រឹត គឺ អ ឥ ឧ ឫ ឭ ហៅថា លហុ ដូចគ្នា ។

## គូនៃអក្សរ

(៤) ក្នុងវគ្គមួយ ៗ សឹងមានអក្សរជាគូនឹងគ្នាដូចខាងក្រោម:

| | | | | | | | |
|---|---|---|---|---|---|---|---|
| វគ្គ ទី ១ | អក្សរ ក | ជាគូនឹង | ខ, | គ | ជាគូនឹង | ឃ |
| — ទី ២ | — ច | — | ឆ, | ជ | — | ឈ |
| — ទី ៣ | — ដ | — | ឋ, | ឌ | — | ឍ |
| — ទី ៤ | — ត | — | ថ, | ទ | — | ធ |
| — ទី ៥ | — ប | — | ផ, | ព | — | ភ |

ឯអក្ខរៈខាងសេសវគ្គ ជាតួសិថិលទាំងអស់ ឥតមានគូឡើយ, អក្ខរៈជាវគ្គន្តៈ (ទីបំផុតវគ្គ) ទាំង ៥ ក៏ជាសិថិល មិនមានគូដូចគ្នាដែរ, អក្សរកំព្រានោះ គឺ ង, ញ, ណ, ន, ម, យ, រ, ល, វ, ស, ហ, ឡ, អំ ។

## ជើងព្យញ្ជនៈ

(៥) ព្យញ្ជនៈទាំងអស់ សុទ្ធតែមានជើងសម្រាប់ផ្ញើពីក្រោមព្យញ្ជនៈឯទៀត ។ បញ្ចូលសំដីគ្នា ហាក់ដូចជាមានព្យញ្ជនៈតែមួយតួ ដូច្នេះពួកផ្ញើជើងទាំងប៉ុន្មាន ក៏ត្រូវផ្សំនឹងស្រៈដូចព្យញ្ជនៈនានាដែរ ប៉ុន្តែត្រូវចាំថា មានព្យញ្ជនៈមួយពួក សំដីលំនុនបានទៅជាពីរយ៉ាង គឺពួក ង, ញ, ន, ម, យ, រ, ល, វ, នេះ បើយកទៅផ្ញើនឹងព្យញ្ជនៈណាមួយ សំដីក៏ដួលទៅតាមព្យញ្ជនៈនោះ ដូចឧទាហរណ៍ថា ន ផ្ញើនឹង ខ បានទៅជា ខ្ន, ន ផ្ញើនឹង គ បានទៅជា គ្ន ជាដើម; ក្រៅពីពួក ៨ តួនេះ ជាព្យញ្ជនៈសំដីវែង ទោះយកទៅផ្ញើនឹងព្យញ្ជនៈណា ៗ ក៏ដោយ តែងទាញសំឡេងគេឲ្យប្រព្រឹត្តតាមអំណាចរបស់ខ្លួន ដូចជា ប ផ្ញើនឹង ម នៅតែសំឡេង ប ដដែល (ម្ប), គ ផ្ញើនឹង ផ នៅតែសំឡេង គ ដដែល (ផ្គរ) ។

ព្យញ្ជនៈខាងក្រោមនេះ ច្រើនតែយកជើងទៅផ្ញើនឹងព្យញ្ជនៈឯទៀត ។

ព្យញ្ជនៈ សំដីដួលទៅតាមព្យញ្ជនៈដែលយកទៅផ្ញើ គឺ ង្, ញ្, ន្, ម្, យ្ ្រ, ល្, ្វ ។

ព្យញ្ជនៈសំដីរងទាញសំឡេងគេឲ្យប្រែព្រឹត្តតាមសភាពរបស់ខ្លួន គឺ ក្ក, គ្គ, ច្ច, ជ្ឈ, ដ្ត, ទ្ទ, ប្ប, ព្ព, ស្ស, ហ្ហ, អ ។

## តួព្យញ្ជនៈបន្ថែម

(៦) ដើម្បីនឹងប្រើការឲ្យគ្រប់គ្រាន់ក្នុងភាសាខ្មែរ លោកបន្ថែមព្យញ្ជនៈ ដោយថែមវណ្ណយុត្តិ មូសិកទន្ត នឹងត្រីសព្ទលើតួព្យញ្ជនៈខ្លះ តួព្យញ្ជនៈនោះ គឺ ង៉, ញ៉, ប៉, ម៉, យ៉, រ៉, វ៉ ប៊, ស៊, ហ៊, អ៊; មូសិកទន្ត សម្រាប់ដាក់លើព្យញ្ជនៈមានសំឡេងធំ ធ្វើឲ្យមានសំឡេងតូច ដូចជា ង> ង៉, ញ> ញ៉, ។ល។ រ> រ៉, វ> វ៉; ឬក៏ដាក់លើព្យញ្ជនៈដែលមានសំឡេងតូចស្រាប់ហើយ ឲ្យរឹតតែតូចទៅទៀត ដូចជាអក្សរ ប> ប៉ ។ ឯត្រីសព្ទសម្រាប់ដាក់លើព្យញ្ជនៈដែលមានសំឡេងតូចឲ្យទៅជាសំឡេងធំ ដូចជា ប> ប៊, ស> ស៊, ហ> ហ៊, អ> អ៊ ។

តួព្យញ្ជនៈទាំងអស់នេះ បើកាលណាមានស្រៈនិស្ស័យ ិ ី ឹ ឺ ើ -ាំ ភ្ជាប់លើតួ គេផ្លាស់វណ្ណយុត្តិ ( ៉ ៊ ) ជា ( ុ ) ដូចជាពាក្យថា: បុិន, មុី, មុឺន, ញុាំញុើ... ដូច្នេះជាដើម ។

(មានត)

ព្រះរាជាណាចក្រកម្ពុជា

# គណៈរដ្ឋមន្ត្រី

មន្ទីរស្តីការក្រសួងសិក្សាធិការ

យុវជននឹងសិល្បការ

ភ្នំពេញ នៅថ្ងៃទី ៩ ខែមេសា គ.ស. ១៩៥២

លេខ ៣៩១៥ /ក

អ្នកឧកញ៉ារដ្ឋមន្ត្រីក្រសួងសិក្សាធិការ យុវជននឹងសិល្បការ

មកលោកអធិបតីសមាគមមិត្តសាលាបាលី លេខ ៣៥ អា - វិថីឧកញ៉ាពេជ្រ - ភ្នំពេញ

ជ្រាប ។

កម្មវត្ថុ: បោះពុម្ពផ្សាយអក្សរអង្គុលីលេខនឹងអក្សរជរៈលេខ ក្នុងទស្សនាវដ្តី "មិត្តសាលាបាលី" ឆ្នាំ ១៩៥២ ។

តបសំបុត្រលោកលេខ ៣៥ ចុះថ្ងៃទី ៧-៤-៥២ ខ្ញុំមិនយល់ទាស់ទេ អំពីបំណងរបស់លោក ដែលគិតបោះពុម្ពផ្សាយអក្សរអង្គុលីលេខនឹងជរៈលេខ ក្នុងទស្សនាវដ្តី "មិត្តសាលាបាលី" ឆ្នាំ ១៩៥២ ។

សូមលោកទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ចម្លងត្រឹមត្រូវ

តាមច្បាប់ដើម

បណ្ណាធិការ

ហត្ថលេខា: ជុណ-អ៊ុក

# អារម្ភកថានៃអក្សរអង្គុលីលេខ

អក្សរអង្គុលីលេខ មិនមែនជាអក្សរបង្កើតឡើងថ្មីសុទ្ធ ទាំងមិនមែនជាអក្សរស្រង់យកពីអក្សរនានាជាតិមកបង្កើតទេ ជាអក្សរគឺគណៈកម្មការវប្បធម៌បានបង្កើតតាមបែបអក្សរខ្មែរយើងមុន ដែលកំពុងប្រើក្នុងសម័យបច្ចុប្បន្ន ដោយការរិះរកទៅឃើញថាត្រូវកែតខ្លះ ទាំងកែរបៀបសរសេរខ្លះ ទើបស្រួលក្នុងការយកទៅប្រើតម្រូវក្នុងអង្គុលីលេខជាគ្រឿងដែលយើងត្រូវការប្រើ ដើម្បីញុំាងកិច្ចការឲ្យអនុវត្តទៅរហ័សទាន់កាលៈទេសៈ ។

អក្សរនេះកាលក្នុង គ. ស. ១៩៤៩ ផ្លូវការបានប្រកាសឲ្យប្រើម្តងប្រជាជនជាច្រើនក៏បានដឹងហើយ សឹងមានក្រមលេខ ៥២៥ N. S. ចុះថ្ងៃទី ៣ ខែសីហា គ. ស. ១៩៤៩ ជាតាងស្រាប់ ៗ រាជរដ្ឋាភិបាលសម័យនោះចាត់ការប្រមូលគ្រឿងទព្យសម្ភារៈ តែមិនទាន់បានគ្រប់គ្រាន់នៅឡើយទទួលកើតមានឧបសគ្គ ក៏អាក់ខានមិនបានចាប់ប្រើតាំងពីកាលនោះមក ៗ លុះដល់មកក្នុង គ. ស. ១៩៥២ នេះ រដ្ឋសភាទាំងរាជរដ្ឋាភិបាលបានសើរើចាត់ការប្រើអក្សរអង្គុលីលេខនោះទៀត បានបញ្ចេញមតិស្របគ្នា ថាត្រូវតែយកបែបអក្សរអង្គុលីលេខ ដែលបាន

បង្កើតហើយនោះមកប្រើ, សព្វថ្ងៃកំពុងចាត់ការប្រមូលគ្រឿងឧបករណ៍សម្រាប់ប្រើ, កាលបើបានគ្រប់គ្រាន់ក្នុងពេលណា នឹងចាត់ការប្រើភ្លាមក្នុងពេលនោះ មិនបង្អង់ឡើយ ។

ដោយសមាគមមិត្តសាលាបាលី មានសេចក្ដីត្រូវការនឹងចុះផ្សាយអក្សរអង្គុលីលេខតាមទស្សនាវដ្ដីមិត្តសាលាបាលី ដើម្បីឲ្យប្រជាជនខ្លួនបានចេះដឹងអក្សរនោះទាន់ពេល តាមគោលបំណងនៃរាជរដ្ឋាភិបាលដែលបានគ្រោងទុក ទើបខ្ញុំយកអក្សរនោះមករៀបរៀងជាបែបរៀនឡើងដើម្បីតម្រូវតាមបំណងសមាគម ។

ការរៀបរៀងបែបរៀនអក្សរនេះ មិនបានធ្វើលំអិតសព្វគ្រប់ដូចជាសៀវភៅបែបរៀនកុមារដ្ឋានទេ គឺធ្វើជាមូលបទខ្លីៗ ហើយពន្យល់សេចក្ដីយោលទៅរកវិធីរៀនរបស់អក្សរយើង មុនដែលកំពុងប្រើសព្វថ្ងៃចំពោះត្រង់បទណាដែលមានលំនាំដូចគ្នា ។ ចំណែកបទណាដែលប្លែកគ្នានោះ ទើបបានពន្យល់ដោយច្បាស់លាស់ក្នុងទីនេះ ។ វិធីដែលរៀបចំដូច្នេះ គឺសម្រាប់តែអ្នកដែលចេះអក្សរខ្មែរស្រាប់ នឹងអាចរៀនបានដោយខ្លួនឯងហើយឆាប់ចេះផង ឯអ្នកដែលមិនទាន់ចេះអក្សរខ្មែរសោះនោះពុំអាចនឹងយកវិធីនេះទៅរៀនបានឡើយ ។

សៀវភៅវិធីរៀនអក្សរខ្មែរយើងមុនមានបែបផ្សេងៗ ជាច្រើន តាមមតិនៃអ្នកនិពន្ធ, ចំពោះខ្ញុំជាអ្នករៀបរៀងវិធីរៀនអក្សរនេះ ខ្ញុំនឹងរៀបរៀងតាមគោលដូចមានតទៅនេះ :

១- ព្យញ្ជនៈ ២- ស្រៈ ៣- បំបែក ៤- សម្គាប់ ៥- ផើត ៦- ប្រកប ៧- វណ្ណយុត្តិ ៨- ពាក្យ ៩- សញ្ញា ១០- សេចក្ដីផ្សេងៗ ។

ចំពោះអ្នកដែលចេះអក្សរខ្មែរបែបមុនច្បាស់លាស់ហើយ តាមខ្ញុំប្រមាណមើលទៅ បើបានអានបែបរៀនអក្សរនេះ ដោយពិនិត្យពិច័យតែមួយចប់ ក៏អាចចេះអក្សរអង្គុលីលេខនេះបានភ្លាម ដោយមិនបាច់ខាតពេលព្យាយាមរៀនយូរឡើយ ។

ខ្ញុំសូមអភ័យអំពីលោកអ្នកនិពន្ធទាំងឡាយ ក្នុងការរៀបរៀងវិធីរៀនអក្សរនេះ, ដ្បិតការរៀបរៀងនេះមុខជាមានការខ្វះខាតពុំលែងឡើយ; តែទុកជាយ៉ាងណា ក៏គង់មានផលដល់អ្នកដែលត្រូវការចេះដឹងអក្សរនេះជាច្រើន ហើយនឹងបានទុកជាគតិវិចិន្ត័យតទៅទៀត ។

ទីបំផុត ដោយអានុភាពនៃសេចក្ដីព្យាយាមរៀបរៀងវិធីរៀនអក្សរនេះ សូមឲ្យកម្ពុជជាតិ ជំនាញក្នុងការគ្រប់យ៉ាង ។

អៀង - ប៊ាង

# អក្សរអង្គុលីលេខ

អក្សរខ្មែរសំរាប់ប្រើតម្រូវអង្គុលីលេខ មានមូលបទត្រូវចេះដូចត ទៅនេះ :–

## ១– ព្យញ្ជនៈ

ព្យញ្ជនៈ មានសម្លេងធ្ងន់ស្រាល មានការសរសេររៀងតួ ទឹង មានការអានជាប់លំដាប់លំដោយ ដូចព្យញ្ជនៈយើងមុនដែលកំពុងប្រើ សព្វថ្ងៃ ប៉ុន្តែត្រង់គ្មានជើងដោយមិនត្រូវការប្រើ ទឹងប៉ុន្តែចំនួន មានដល់ទៅ ៣៤ ព្រោះថែមតួ (ប) នៅខាងចុងបំផុតមួយទៀត (ដែលត្រូវអានថា ប៉) ដូចតារាងខាងក្រោមនេះ :–

ក ខ គ ឃ ង    ច ឆ ជ ឈ ញ

ដ ឋ ឌ ឍ ណ    ត ថ ទ ធ ន

ប ផ ព ភ ម    យ រ ល វ ស

ហ ឡ អ ឬ

ព្យញ្ជនៈ ទាំង ៣៤ តួនេះ តួដែលបានកែប្រែប៉ុន្តែតាក់រូបភាពដើម ទឹងកែបន្ថែមឡើងទៀត មានតែ ១១ គត់ គឺ

ឋ ឈ ញ ឌ ឍ

យ ល ស ហ ឡ ឬ

ហេតុបានជាកែតួឲ្យមានសណ្ឋានយ៉ាងនេះ មកអំពីតួព្យញ្ជនៈនេះ កាលដើម មានខ្សែបន្ទាត់បញ្ឈរដល់ទៅ ៣ ជាហេតុនាំឲ្យទំនាស់ដល់ការយកទៅប្រើតម្រួតអក្ខលីលេខមិនបានល្អមិនបានស្រួល លើកលែងតែតួ ប ដែលមានខ្សែបន្ទាត់បញ្ឈរតែ ២ ស្រាប់ ហើយកែបន្ថែមមកទៀត ព្រោះមានប្រាថ្នាបំពេញសេចក្ដី ២ យ៉ាង ដែលទឹងមាននិយាយដោយច្បាស់លាស់នៅខាងមុខក្នុងពួក សម្លាប់ ។

អៀង-ថាង

(មាគត)

អក្សរជាតិណា ជាគោលថ្លៃថ្លា
នៃជាតិនោះឯង, ខ្មែរយើងគួរគិត
ពិនិត្យប្រឹងប្រែង ប្រើអក្សរឯង
ជាគោលជាតិខ្មែរ!

ប. ត.

# ពាក្យដើម ជវលេខ ១ អៀវ-កើស

ជវលេខនេះ ជារបស់លោកអ្នកឧកញ៉ា អៀវ-កើស អតីតប្រធានរដ្ឋសភា ។ លោកបានបង្រៀនខ្ញុំ នឹងពួកស្មៀនរដ្ឋសភា ក្នុងខែកញ្ញា គ.ស. ១៩៤៨ ដែលជាវេលាវិស្សមកាលនៃរដ្ឋសភា ។

ក្នុងរយៈវេលាជាងមួយខែប៉ុណ្ណោះ ក៏បានចប់សព្វគ្រប់តាមរបៀបបទរៀន លោកបានប្រដៅខ្ញុំនឹងពួកស្មៀនរដ្ឋសភា ឲ្យខិតខំហាត់សរសេរតទៅទៀត ។ ខ្ញុំក៏បានឆ្លៀតឱកាសហាត់សរសេរតាមដម្បូន្មានលោក ។

មុនដម្បូងខ្ញុំបានយកបទរៀនផ្សេងៗ ដែលងាយអានមកហាត់សរសេរតាម ហើយក៏យកមកអានភ្លាមផ្ទៀងមើលនឹងអត្ថបទដើម ។ ធ្វើយ៉ាងនេះអស់រយៈវេលាមួយខែ ។ តពីនោះ ខ្ញុំក៏បានយកច្បាប់ផ្សេងៗ មានច្បាប់ព្រហ្មទណ្ឌជាដើម មកសរសេរចម្លង សរសេររួចហើយ ទុកឲ្យកន្លងទៅរវាងពីរថ្ងៃ ទើបយកមកអាន ។ ធ្វើយ៉ាងនេះអស់រយៈវេលាមួយខែ ។

កាលបើការចាំសញ្ញានឹងការអានមានសន្ទុះគ្រាន់បើហើយ ខ្ញុំក៏ហាត់សរសេរតាមសូត្រ មុនដំបូងបានយកសេចក្ដីកត់ហេតុនៃការពិភាក្សារដ្ឋសភា ឲ្យគេសូត្រមួយៗ ហើយសរសេរតាម ។ កាលសេចក្ដីថ្នឹកមានកាន់តែច្រើនឡើង ខ្ញុំក៏ឲ្យគេសូត្ររហ័សជាងមុន ។ ធ្វើយ៉ាងនេះ

អស់រយៈវេលា ៤-៥ខែ ទើបខ្ញុំសុំឲ្យគេសូត្រអត្ថបទមួយហើយសរសេរតាម ឃើញល្បឿននៃការសរសេរ ក្នុងមួយនាទីបានជាងមួយរយពាក្យ ។

កាលលទ្ធផលនៃការសរសេរបានសំរេចខ្លះយ៉ាងនេះហើយ ខ្ញុំក៏មានបំណងជាខ្លាំងថា ធ្វើម្តេចឲ្យជនជាតិយើងមានបំណេះដរលេខនេះច្រើនឡើង ដើម្បីឲ្យបានគ្រប់គ្រាន់តាមសេចក្តីត្រូវការរបស់ប្រទេស ដូចជាកត់តាមពាក្យនិយាយនៅពេលប្រជុំសភា គណៈរដ្ឋមន្ត្រីនឹងសន្និសិទជាដើម ។ ដល់មកពេលនេះ សមាគមមិត្តសាលាបាលីត្រូវការយករបៀបដរលេខ មកបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីមិត្តសាលាបាលីនេះ ។ ខ្ញុំក៏មានសេចក្តីត្រេកអរដោយសមតាមបំណងខ្លះ ទើបរៀបរៀងដរលេខ អៀវ-កើស តាមទំនងដែលខ្ញុំបានរៀនផ្ទាល់ពីលោក ។

ហេតុនៃការកើតឡើង នឹងការរៀនដរលេខយ៉ាងណានោះ ដូចមានក្នុងពាក្យនាំនឹងដម្បូន្មានរបស់លោកអ្នកឧកញ៉ា អៀវ-កើស ជាប់ជាមួយនេះស្រាប់ ។

ខ្ញុំសូមឧទ្ទិសកុសលដែលកើតពីសេចក្តីនឿយហត់បន្តិចនេះ ជូនដល់វិញ្ញាណក្ខន្ធរបស់លោកអ្នកឧកញ៉ា អៀវ-កើស ៖

សៀង-ឌិន

## ពាក្យនាំ ជវលេខ អឿវ-តេគីស

ជវលេខជាអ្វី ? — ពាក្យ ជវលេខ មកពីភាសាបាឡីសំស្ក្រឹត: ជវ ប្រែថា រហ័ស ថា ឆាប់, លេខ ប្រែថា ការសរសេរ ឬរបស់ដែលគេសរសេរ ។ ជវលេខ ជាសិល្បៈមួយ (un art) ដែលប្រើសញ្ញាផ្សេងៗតាមសន្មត ដើម្បីសរសេរឲ្យបានលឿនទាន់ពាក្យនិយាយ ។

ប្រវត្តិជវលេខ .— នៅទ្វីបអឺរ៉ុប គេមានប្រើជវលេខជាង ២ ០០០ ឆ្នាំមកហើយ ។ មានពស្តុតាងថា ជវលេខមានប្រើក្នុងប្រទេសក្រិកនាសម័យស្ត្រាត ៤០០ ឆ្នាំ មុនគ្រិស្តសករាជ មានប្រើក្នុងប្រទេសរ៉ូមនាសម័យកាតុង ប្រហែល ១០០ ឆ្នាំ មុនគ្រិស្តសករាជ ។

ក្នុងសម័យព្រេងនាយនោះ មានការសិក្សាជវលេខក្នុងសាលារៀន ដើម្បីយកទៅកត់ពាក្យប្រៀនប្រដៅនៃគ្រូអាចារ្យ កត់បាឋកថានៃអ្នកនយោបាយដែលមានឥទ្ធិពល និងកត់សេចក្ដីជំនុំជំរះក្នុងសាលាតុលាការ ។

តែតមក ក្នុងមជ្ឈិមយុគ (moyen-âge) កាលអារ្យធម៌ក្រិកនិងអារ្យធម៌រ៉ូម អាប់រស្មីងងឹតទៅ សិល្បៈនេះក៏គ្មានគេរៀនសូត្រប្រើការឡើយ ។

អារ្យធម៌ក្រិក-រ៉ូម ដែលហាក់ដូចជារលត់បាត់បង់ទៅ ប្រហែល ១.០០០ ឆ្នាំ មានពូជនៅសល់ខ្លះរៀងមក ។ ពូជនោះបានលូតលាស់ឡើងវិញបន្តិចម្ដងៗ នៅទ្វីបអឺរ៉ុបភាគខាងលិច តាំងពីសតវត្សទី ១៥ មក ។ លុះដល់មកចុងសតវត្សទី ១៨ នាកាលអារ្យធម៌នោះលូតលាស់ច្រើនខ្លាំង

ឡើង សេចក្ដីត្រូវការគត់ត្រាឲ្យបានលឿនទាន់ពាក្យនិយាយ ក៏កើតមានឡើងជាថ្មីទៀត នាំឲ្យមានអ្នកតែងផរលេខជាច្រើននាក់ ដូចជាលោកតៃ-ឡ័រ (Samuel Taylor) នៅប្រទេសអង់គ្លេស (គ.ស. ១៧៨៦) លោកគូឡុង ដឺតេវ៉ិណូត៍ (Coulon de Thévenot) នៅប្រទេសបារាំង (គ.ស. ១.៧៨៧) លោកអែម៉េ ប៉ារី (Aimé Paris) នៅប្រទេសស្វិស លោកកាប៊ែលស្ប៊ើគើរ (Gabelsberger) នៅប្រទេសអាល្លឺម៉ង់ ។

នៅប្រទេសស្វិសនឹងប្រទេសអាល្លឺម៉ង់ គេនៅប្រើរបៀបផរលេខតាមដែលពោលខាងលើនេះ ដល់មកសព្វថ្ងៃ តែនៅប្រទេសអង់-គ្លេសនឹងសហរដ្ឋអាមេរិក គេប្រើរបៀបផរលេខពិតម៉ាន់ (Pitman) ។ នៅប្រទេសបារាំង គេប្រើផរលេខរបៀបប្រេវ៉ូស្ដ-ដឺឡូណេ (Prévost-Delaunay) នឹងរបៀបឌុយប្លូយេ (Duployé) តែគេប្រើរបៀបប្រេវ៉ូស្ដដឺ-ឡូណេ ច្រើនជាង ។

**ប្រវត្តិនៃរបៀបប្រេវ៉ូស្ដ.— ដឺឡូណេ.—** ដូចយើងបានពោលមកហើយ កាល គ.ស. ១៧៨៧ លោកគូឡុង-ដឺតេវ៉ិណូ បានតែងរបៀបផរលេខមួយយ៉ាងៗ របៀបនេះស្រួលអានតែសរសេរមិនសូវបានលឿន ។

នា គ.ស. ១៧៩២ លោកប៊ែរតាំង (Théodore Pièrre Bertin),, បានយករបៀបផរលេខរបស់លោកតៃឡ័រ ដែលធ្វើសំរាប់ភាសាអង់គ្លេស មកកែសម្រួល សំរាប់ប្រើក្នុងភាសាបារាំង ។ របៀបផរលេខលោកប៊ែរតាំងនេះ សរសេរបានរហ័សល្អ តែមិនងាយអាន ។

ទើបលោកប្រេវ៉ូស្ត (Hippolyte-Prévost) នា គ.ស. ១៨២៦ បាន យករបៀបតាំងពីរនេះ មកសម្រួលបញ្ចូលគ្នា ធ្វើជារបៀបមួយឲ្យបាន តាំងស្រួលអាន ហើយសរសេរលឿនផង ។

នា គ.ស. ១៨៧៨ លោកដឺឡូណេ (Albert-Delaunay) ដែលជា សិស្សរបស់លោកប្រេវ៉ូស្ត ហើយដែលជាអ្នកជរលេខយ៉ាងជំនាញ បាន រៀបសម្រួលរបស់លោកប្រេវ៉ូស្ត តាំងឡើងជារបៀបជរលេខដែលគេ ប្រើសព្វថ្ងៃនេះ សំរាប់ភាសាបារាំង ឈ្មោះថារបៀបប្រេវ៉ូស្ត-ដឺឡូណេ ។

ហេតុដែលនាំឲ្យកើតជរលេខខ្មែរ.— ក្នុងសភានីតិបញ្ញត្តិ ដែលមានក្នុងប្រទេសប្រជាធិបតេយ្យនានា សុទ្ធតែមានធ្វើសេចក្ដីកត់ ហេតុនៃពេលជំនុំ ចុះសេចក្ដីពិភាក្សាយកទៅបោះពុម្ពផ្សាយដល់មហាជន ដើម្បីឲ្យប្រជារាស្ត្របានដឹងនូវកិច្ចការផែនដី ដែលអ្នកតំណាងទៅប្រតិ- បត្តិជួសខ្លួន ។ ដើម្បីកត់ពាក្យនិយាយ ឆ្លងឆ្លើយគ្នាក្នុងសភាបាន ដោយពេញលេញ ត្រូវឲ្យមានវិធីសរសេរកាត់ឲ្យបានឆាប់រហ័ស ។ ទើបក្នុងប្រទេសនានានោះ គេមានអ្នកជរលេខប្រចាំសភាគេជាដរាប ។

នា គ.ស. ១៩៤៦ កាលប្រទេសយើងទើបមានរដ្ឋសភានឹងគេ ជាដំបូង គឺរដ្ឋសភាបណ្ដោះអាសន្ន ដើម្បីព្រាងរដ្ឋធម្មនុញ្ញ ខ្ញុំបាន ទទួលជ្រើសតាំងជាប្រធាន ។ ខ្ញុំបានសង្កេតឃើញថា ការធ្វើសេចក្ដី កត់ហេតុ ពុំមានដំណើរស្រួលបួលសព្វគ្រប់ឡើយ ព្រោះស្មៀនត្រូវប្រើ

អក្សរធម្មតា សរសេរពុំបានលឿនល្មមសេចក្ដីត្រូវការ ។ កត់ហេតុបានតែជាសេចក្ដីសង្ខេប ជួនកាលអ្នកកត់មិនយល់គំនិតអ្នកនិយាយដោយច្បាស់លាស់ រួបរួមសេចក្ដីខុសស្រឡះទៅក៏មាន ។ សេចក្ដីសំខាន់ខ្លះកត់មិនទាន់រំលងចោលទៅក៏មាន ។ ជាការណ៍នាំឲ្យខ្ញុំបង្អៀតបង្អល់ក្នុងចិត្តមិនតិចឡើយ ។

កាលរដ្ឋសភាស្ថាពរកើតឡើង នា គ.ស. ១៩៤៨ ខ្ញុំបានទទួលជ្រើសតាំងជាប្រធានម្ដងទៀត ។ ការបង្អៀតបង្អល់ក្នុងចិត្ត ក៏មានកាន់តែខ្លាំងឡើង នឹងរកនរណារៀបចំបង្កើតជរលេខខ្មែរ សំរាប់ប្រើពុំបាន ។ ឯខ្លួនខ្ញុំធ្លាប់បានរៀនវិជ្ជានេះដែរ កាលទៅសិក្សាក្នុងសាលាជំនួញជាន់ខ្ពស់ នាមហាវិទ្យាល័យហាណូយ តែបានលះបង់ចោលពុំបានប្រើការមកប្រហែល ២០ ឆ្នាំហើយ ភ្លេចភ្លាំងអស់ទៅវិញ ។ មួយទៀតការកិច្ចនៃប្រធានរដ្ឋសភា ដែលទទួលតំណែងជាអគ្គលេខាធិការនៃគណៈបក្សធំមួយទៀតផង ពុំសូវទុកសេចក្ដីទំនេរ ពេលទំនេរចិត្តដល់ខ្លួនខ្ញុំឡើយ ។ ប៉ុន្តែដោយតាល់គំនិតហើយក៏ត្រូវតែច្នៀតពេលរៀនជរលេខបាកំងឡើងវិញ ហើយរៀបរៀងសម្រួលសំរាប់ប្រើក្នុងភាសាខ្មែរ ។

លក្ខណៈនៃរបៀបជរលេខខ្មែរនេះ — ជរលេខបាកំងដែលខ្ញុំបានរៀននោះ គឺជរលេខរបៀបប្រេវ៉ុស្ដ-ដឺឡូណេ ។ ដើម្បីតែងជរលេខសំរាប់ប្រើក្នុងភាសាខ្មែរ នោះបើគ្រាន់តែយកគោលការណ៍ របស់ជរលេខ

បារាំងមកជាទីតាំង ហើយសន្មតសញ្ញាថ្មីទាំងអស់ដោយខ្លួនឯង ឃើញថានឹងបានស្រួលជាង ឬបើមិនស្រួលជាងច្រើនណាស់ទេ ក៏គង់សមហេតុសមផល (logique, national) ជាងដែរ ។ ប៉ុន្តែបើធ្វើដូច្នេះទៅ អ្នកចេះជួរលេខបារាំង ហើយយកមករៀនជួរលេខខ្មែរផង មុខជានឹងវង្វេងនឹងប្រើជួរលេខទាំងពីរជាគូគ្នាពុំបាន ។ គឺដោយហេតុនេះហើយ ទើបខ្ញុំយកសញ្ញារបស់ជួរលេខបារាំងមកប្រើ លុបចោលសញ្ញាខ្លះដែលយើងមិនត្រូវការ ហើយបង្កើតសញ្ញាថ្មីទៀតដែលខានពុំបាន ។

របៀបជួរលេខខ្ញុំនេះ ខ្ញុំបានចាប់បង្រៀនស្មៀនវត្តសភា ក្នុងខែកញ្ញា គ. ស. ១៩៤៨ ដែលវេលានោះជាវិស្សមកាល (vacances) ។

សូមឧទ្ទិសការហត់នឿយរបស់ខ្ញុំបន្តិចនេះដល់មាតុភូមិជាទីស្រឡាញ់ ដោយសង្ឃឹមថានឹងមានប្រយោជន៍ខ្លះទៅថ្ងៃក្រោយ ។

រូបកាយមនុស្សសត្វ តែងទ្រុឌទ្រោមបាត់,
កេរ្តិ៍ឈ្មោះនោះឯង ឋិតថេរក្នុងលោក
មានជោគជាក់ស្តែង: យើងគួរប្រឹងប្រែង
សាងកេរ្តិ៍ឈ្មោះទុក !

ប. ព.

# ជម្រាបជូនដល់គ្រូនិងអ្នករៀន

## ជីវលេខ អៀវ-កើស

---

សេចក្ដីរៀបរៀងរបស់ខ្ញុំនេះ ធ្វើយ៉ាងសង្ខេបបំផុតដោយគ្មានពេលគ្រប់គ្រាន់ ៗ ដើម្បីនឹងឧបត្ថម្ភដល់អ្នករៀន ឲ្យបានស្រួលក្នុងការបង់ចាំ គ្រូគួររកពាក្យឧទាហរណ៍ឲ្យបានក្រែលបន្តិច ដាក់ក្នុងបទរៀន (leçon) នីមួយ ៗ សំរាប់ឲ្យសិស្សប្រើសញ្ញាក្នុងបទរៀននោះសរសេរជាពាក្យជីវ-លេខ នេះមួយយ៉ាង, មួយយ៉ាងទៀត គួរគ្រូប្រើសញ្ញាក្នុងបទរៀននីមួយៗនោះ សរសេរជាពាក្យជីវលេខ សំរាប់ឲ្យសិស្សហាត់អានថែមទៀតផង ៗ

ការរៀនជីវលេខមានពីរវយៈ : វយ ទី ១ រៀនឲ្យចាំសញ្ញាទាំងអស់យកមកសរសេរបានហើយអានកើត, វយៈទី ២ ហាត់សរសេរលឿន ៗ

ក្នុងវយៈទី ១ :

ក ) កុំបង់សរសេរលឿនឲ្យសោះ ;

ខ ) ត្រូវខំសរសេរសញ្ញាទាំងឡាយដោយផ្ចិតផ្ចង់យ៉ាងបំផុត ឲ្យបានល្អត្រឹមត្រូវដូចគំរូ ដើម្បីឲ្យធ្លាប់ដៃ ៗ បើថ្ងៃក្រោយសរសេរញាប់យ៉ាងណាទៅ ប្រសិនជាវៀងឃ្លាតខ្លះ ក៏កុំឲ្យវៀងឃ្លាតដល់បាត់រូបនោម ;

គ) ក្នុងបទរៀនទីមួយៗ ចូរហាត់សរសេរសញ្ញា ហាត់សរសេរពាក្យ៖ឧទាហរណ៍ជាពាក្យជវលេខ ហាត់អាន ហាត់ហើយ ហាត់ទៀត លុះត្រាតែចាំសញ្ញាក្នុងបទរៀននោះស្ទាត់ សឹមចាប់បទរៀនមួយតទៅទៀត ;

ឃ) កាលចប់បទរៀនអស់ហើយ ចូរយកអត្ថបទផ្សេងៗ មកហាត់ចំឡងជាជវលេខ ហើយអានឡើងវិញខ្លួនឯង ឲ្យទាល់តែបានស្រួលបួល ៗ ដើមដំបូង សរសេររួចអានភ្លាម ក្រោយបន្តិចទៅ ចូរទុកពេល ២-៣ ថ្ងៃ ដល់ភ្លេចសេចក្ដីក្នុងអត្ថបទនោះខ្លះហើយ សឹមយកមកអានល្បងមើល ;

ង) ជវលេខ ពុំមែនជាការកត់ពាក្យតាមនិរុត្តិសាស្ត្រ (étymologie) ទេ គឺកត់តាមតែសំឡេង ដូចជាពាក្យថា ប្រយោជន៍ បារម្ភ កត់តែសំឡេងជាប្រយោច បារម ៗ មួយទៀត ពាក្យទាំងឡាយសរសេរជាប់ពីគ្នាមួយម៉ាត់ ៗ ៗ ក្នុងការហាត់សរសេរ ត្រូវព្យាយាមឲ្យចាំរូបរាងពាក្យដែលប្រើញឹកញយ ដើម្បីកាលណាឃើញពាក្យនោះមក អាចស្គាល់ស្រេចមិនចាំបាច់ប្រកបសញ្ញានានានៃពាក្យនោះ ហើយដើម្បីសរសេរបានដោយងាយ ៗ

ក្នុងវយ ទី ២ :

ក) ការរៀនជវលេខ ដើម្បីគ្រាន់តែសរសេរបានដូចអក្សរធម្មតាប៉ុណ្ណោះ នរណាក៏អាចធ្វើបាន ឲ្យតែមានសេចក្ដីព្យាយាមគ្រប់គ្រាន់ ។ តែឯការប្រើសញ្ញាជវលេខ ដើម្បីសរសេរឲ្យលឿនទាន់ពាក្យនិយាយវិញ នោះតោងមានស្មារតីវៃវាងល្អណាស់ ហើយមានវិជ្ជាទូទៅ (connaissances générales) ដ៏គួរសម ឬត្រូវចេះដឹងក្នុងការដែលខ្លួនមានភារៈកត់ត្រាឲ្យល្មមយល់បាននូវសេចក្ដីដែលខ្លួនកត់នោះផង ទើបអាចទៅជាអ្នកជវលេខបាន ។ ហេតុនេះ បើនរណាយល់ថា ខ្លួនគ្មានគុណសម្បត្តិដូចពោលខាងលើនេះទេ មិនគួរខំរៀនជវលេខឲ្យខាតពេលឡើយ ;

ខ) ការរៀនក្នុងរយៈទី១ បើធ្វើដោយប្រញាប់ អាចចប់ក្នុងមួយខែ ឬពីរខែ ។ ឯការរៀនក្នុងរយៈទី២ ត្រូវប្រើវេលាយូរខែ អាចដល់មួយឆ្នាំ ឬយូរជាងនោះទៅទៀត ។ ដូច្នេះត្រូវមានសេចក្ដីព្យាយាមអត់ធន់ជាប់ក្នុងចិត្ត ;

គ) ត្រូវរកគ្រូឲ្យបង្ហាត់សរសេរលឿន គឺសូត្រអត្ថបទអ្វីមួយឲ្យសិស្សសរសេរតាម ដោយប្រើនាឡិកាកាប់វិនាទីលៃល្បឿនតាមនាទីនិងតាមភាគ ១ ក្នុងនាទី (១/៤) នៃនាទី ។ អត្ថបទដែលគួរប្រើសំរាប់សូត្រឲ្យសរសេរតាមនោះ គឺសេចក្ដីពិភាក្សានៃរដ្ឋសភាដែលមានចុះផ្សាយក្នុងរាជកិច្ច ព្រោះជាពាក្យដែលប្រហែលគ្នានឹងពាក្យនិយាយធម្មតា ;

ឃ) បើត្រូវហាត់ដោយឥតគ្រូ គួររកពឹងគេឲ្យសូត្រហើយសរសេរតាម រួចអានផ្ទៀងមើលនឹងអត្ថបទដើម ;

ង ) ត្រូវរកឱកាសសរសេរដវលេខ ឲ្យបានយ៉ាងច្រើនបំផុត ឲ្យបានញឹកញយបំផុត ។ របស់ដែលកត់ទុកសំរាប់ការផ្ទាល់ខ្លួនគួរសរសេរដវលេខ ។ ការសរសេរទៅអ្នកដវលេខ ឬអ្នករៀនដវលេខដូចគ្នា ក៏គួរធ្វើជាដវលេខ ;

ច ) យកសេចក្ដីដែលចាំមាត់ស្រាប់ មានពាក្យកាព្យជាដើមមកសរសេរហើយសរសេរទៀត ទាល់តែស្ទាត់ដៃ ;

ឆ ) លទ្ធផល (résultat) នៃការហាត់ដែលប្រាថ្នានោះ គឺធ្វើឲ្យការសរសេរដវលេខទៅជានិស្ស័យនៃអ្នករៀន លុះត្រាតែសរសេរបាន ដោយឥតនឹកគិត ;

សញ្ញាដវលេខ ត្រូវសរសេរឲ្យសមល្មម កុំធំពេក កុំតូចពេក ។ ធំពេក នាំឲ្យឆាប់រួយដៃ នាំឲ្យយឺតពេល តូចពេក នាំឲ្យពិបាកអាន ។

មានសញ្ញាខ្លះ ត្រូវសរសេរសង្កត់ ។ ហេតុនេះ បើប្រើដីខ្មៅរឹងពេកកាលសង្កត់ទៅ នាំឲ្យបាក់, បើប្រើដីខ្មៅទន់ពេក នឹងអាចធ្វើប្រគាកលើក្រដាស មិនស្រួលដែរ ។ គួរជ្រើសយកតែដីខ្មៅដែលទន់ល្មម ។

បើខំឲ្យមែនទែន ក្នុងវេលា៦ខែ នឹងអាចសរសេរបាន ១០០ ឬ ១២០ ម៉ាត់ក្នុងមួយនាទី ។ កាលបានល្បឿននេះហើយសឹមល្បងកត់ពាក្យអ្នកនិយាយថ្លែងការណ៍ ឬសូត្របាឋកថា ។

បើអ្នកថ្លែងនិយាយញាប់ពេក ចូរកុំស្ទន់កាំងស្មារតី ។ ចូរចំកត់តែពាក្យសំខាន់ៗ ដែលអាចនាំឲ្យរៀបប្រយោគបានឡើងវិញក្នុងពេលក្រោយ ។

ចូរចាំថា ស៊ូទុកពាក្យដែលសរសេរខុសមួយគ្រាសិន ជាជាងខាតពេលកែកំពុងសរសេរ ស៊ូរំលងពាក្យមួយម៉ាត់ ជាជាងត្រឡប់មកបន្ថែម ឲ្យខូចពេលនាំរំលងអស់ច្រើនម៉ាត់ ។

ពាក្យដែលមានសន្ទតក្នុងសៀវភៅនេះ ពុំមែនត្រូវមានតែចំនួនប៉ុណ្ណោះទេ ។ អ្នកប្រើការអាចសន្ទតពាក្យកាត់យកខ្លួនឯងថែមទៀត តាមតែយល់ថាជាការគួរ ។

(មានត)

ដើម្បីជម្កើង ប្រទេសយើងឡើង
គួរយើងប្រឹងប្រែង ប្រើអក្សរយើង
ឲ្យថ្កើងចាំងថែង ដូចស្រុកគេឯង
ក្នុងលោកសេរី!

ប. ព.

ឯកសារ ស្តីពីប្រវត្តិសាស្ត្រ នៃកម្ពុជរដ្ឋ

# ភាគទី ៣

ភ្ជាប់តាមអារ៉េតេថ្ងៃទី ៦ កុម្ភៈ ១៩០១

## ស្រង់ពីប៊ុល្លីតាំងនៃវិជ្ជាស្ថាន បារាំងបូព៌ាប្រទេស

## ភាគ ១, ១៩០១ (១)

លោកហ៉ុយ-ប៊ុក ក្រុមការនៅពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

លោកឧត្តមប្រឹជា ចាប-ពិន បណ្ឌិត នៅពុទ្ធសាសនបណ្ឌិត្យ

ពិនិត្យកែ

## បញ្ជីរាយនាមប្រាសាទបុរាណ នៃកម្ពុជរដ្ឋ

## ១ – ទីរ៉េស៊ីដង់កំពង់ចាម

---

១ ខេត្តសៀមរាបនឹងបាត់ដំបង ជាខេត្តរបស់ខ្មែរ តែបានទៅជាខេត្តសៀម ពី គ. ស. ១៧៩៥ ក្នុងរាជ្យអង្គអេង, ដល់ថ្ងៃទី ២៧ មិថុនា ១៩០៧ ទើបបានមកជាខេត្តខ្មែរវិញ; ព្រោះគេតែងប៊ុល្លីតាំងនេះក្នុង គ. ស. ១៩០១ នៅពេលដែលខេត្តទាំងពីរនេះ នៅជាខេត្តសៀមនៅឡើយ បានជាក្នុងបញ្ជីរាយប្រាសាទតទៅខាងមុខនេះ មិនឃើញរាយនាមប្រាសាទក្នុងខេត្តទាំងពីរនេះមានប្រាសាទអង្គរជាដើម ។

## ក) ខេត្តកំពង់សៀម

វត្តនគរៈ ព្រះវិហារ, កំពែង, នាគ, រូបចំឡាក់ផ្សេងៗ នៅខាងកើតកំពែង

ភ្នំប្រុសៈ មានរូបព្រះវិស្ណុនៅពីលើក្លោងទ្វារ

## សិលាចារិកនៅកន្ទោង

អំពេៈ បូជនីយដ្ឋានថ្មបាយក្រៀម

យាយហមៈ មានប្រាសាទ ៣ ប្រាសាទមានក្បាច់រចនា; រូបចំឡាក់បាក់បែកជាច្រើននៅខាងមុខ ខាងកើត ហើយនឹងរោងសំណាក់ ១ នៅខាងក្រៅកំពែង

សង្គៈ សិលាចារិកមកពីយាយហម

គោកតាព្រហ្មៈ បូជនីយដ្ឋានធ្វើពីលោហធាតុដែក (limonite)

ហាន់ជ័យៈ បូជនីយដ្ឋានធ្វើពីឥដ្ឋ, កុដិថ្ម

បាយក្រៀមៈ សិលាចារិកផ្សេងៗ

## ខ) ខេត្តជើងព្រៃ

ព្រះធាតុៈ បូជនីយដ្ឋានធ្វើពីឥដ្ឋ កំពែងធ្វើពីលោហធាតុដែក; សាលាផ្សេងៗ

គុកត្រពាំងគុក: បូជនីយដ្ឋានធ្វើពីឥដ្ឋ

គុកព្រះគុក: បូជនីយដ្ឋានឥដ្ឋមានសិលាចារឹក

គុកត្រពាំងស្រុក: បូជនីយដ្ឋានឥដ្ឋ មានសសរក្បាច់របនា ទឹងជញ្ជាំងកំពែង, សិង្ហ

គុកអំពិលទ្វារ: បូជនីយដ្ឋានបីកន្លែងធ្វើពីឥដ្ឋ; កំពែង, ក្បាច់របនាផ្សេងៗ ក្បាច់របនានៃសើនខាងជើង?

ព្រីងជ្រឹ: បូជនីយដ្ឋាន ឥដ្ឋ, កំពែង, សិលាចារឹក,

តាំងក្រសាំង: សិលាចារឹកនឹងក្បាច់ចំឡាក់

ប្រសាទខ្ចិត: បូជនីយដ្ឋាន ធ្វើពីលោហធាតុដែក

ភ្នំត្រប់: ក្បាច់របនាពីរនៅអមសងខាងទ្វារ, បូជនីយដ្ឋានបីកន្លែង

ភូមិបាព្រះ: បូជនីយដ្ឋានធ្វើពីឥដ្ឋ, ក្បាច់របនា

ភ្នំព្រះបទ: ក្បាច់របនា (Faux linteaux)

ភ្នំជី: បូជនីយដ្ឋានធ្វើពីលោហធាតុដែក យ៉ធ្វើពីឥដ្ឋ (galerie) កំពែង

## គ) ខេត្តត្បូងឃ្មុំ

សិលាចារឹកអង់ទិម

គុកព្រះធាតុពណ្ណរាយៈ បូជនីយដ្ឋានធ្វើពីលោហធាតុដែក (limonite)

បន្ទាយព្រៃអង្គរៈ ក្រុមបូជនីយដ្ឋានពីរកន្លែងនឹងបូជនីយដ្ឋាន ៣ កន្លែងសិលាចារឹក ធ្វើពីឥដ្ឋ

ក្រុមព្រៃគីៈ បូជនីយដ្ឋានបី ធ្វើពីឥដ្ឋ

ប៊ុងអង្គៈ បូជនីយដ្ឋាន ធ្វើពីឥដ្ឋ កំពែងលោហធាតុដែក សិលាចារឹក

គិរៈ សិលាចារឹកថ្មបាយក្រៀម (grès)

ព្រះធាតុព្រះស្រីៈ បូជនីយដ្ឋាន ធ្វើពីឥដ្ឋ, យ៉មានសសរវៀង (péristyle) ប្រាសាទពីរ; ក្បាច់ចំឡាក់ផ្សេងៗ; សិលាចារឹក, (Stèle) អក្សរចារឹក (Inscriptions)

ប្រាសាទភូមិមៀងៈ បូជនីយដ្ឋានធ្វើពីឥដ្ឋ អក្សរចារឹក

ទួលបារិកៈ សិលាចារឹកពីរបែកបាក់ខ្វះ

ព្រះធាតុខ្មែរាំងៈ បូជនីយដ្ឋានធ្វើពីឥដ្ឋ សិលាចារឹកពីរ

ព្រះធាតុជ្រោលៈ បូជនីយដ្ឋាន ធ្វើពីឥដ្ឋ

ព្រះធាតុស្រមៈ បូជនីយដ្ឋាន ធ្វើពីឥដ្ឋ

ប្រាសាទជ្រោល: បូជនីយដ្ឋានបួន ធ្វើពីឥដ្ឋ

ព្រះធាតុខ្ទឹ: សិលាចារឹក, បូជនីយដ្ឋានធ្វើពីឥដ្ឋ

ព្រះធាតុត្រពាំងជ្រោយ: បូជនីយដ្ឋានជាច្រើនធ្វើពីឥដ្ឋនឹង លោហធាតុដែក

ព្រះធាតុបារាយណ៍: បូជនីយដ្ឋានពីរធ្វើពីលោហធាតុដែក មួយទៀតធ្វើពីឥដ្ឋ

## ឃ) ខេត្តស្រីសន្ធរ

ព្រះធាតុបារាយណ៍: បូជនីយដ្ឋានធ្វើពីលោហធាតុដែក, ក្បាច់ចំឡាក់

ព្រះវិហារសួគ៌: ក្បាច់ចំឡាក់

វត្តស៊ីធរ: ព្រះចេតិយប្រាំនឹងហើយនឹងសិលាចារឹកពីរ

បំឡុង: បូជនីយដ្ឋានបី, ពីរធ្វើពីលោហធាតុដែក, មួយធ្វើពីឥដ្ឋ

ស្វាយ-សាតភ្នំ: សិលាចារឹក, ក្បាច់ចំឡាក់

កោះសម-ធំ: រូបព្រះព្រហ្ម

## ២– ទីរ៉េស៊ីដង់ក្រចេះ

## ក) ខេត្តសម្បូណ៌

សំបុក: សិលាចារិក; សើនធ្វើពីឥដ្ឋ

ព្រះធាតុខ្វាន់ពី: សើនពីរធ្វើពីឥដ្ឋ

សូភាស: ក្រុមបូជនីយដ្ឋានធ្វើពីឥដ្ឋ ក្បាច់ចំឡាក់បាក់បែក, សិលាចារិក

### ១) ខែត្រស្ទឹងត្រែង[១]

វត្តស្ទឹ: បូជនីយដ្ឋានបីធ្វើពីឥដ្ឋ

មន្ទីរ: បូជនីយដ្ឋានធ្វើពីឥដ្ឋ

## ៣ – ទីរ៉េស៊ីដនភ្នំពេញ

វត្តបទុមវតី: សិលាចារិកបី

ក្រសួងសាធារណការ: សិលាចារិកមួយ

## ៤ – ទីរ៉េស៊ីដនព្រៃវែង

### ក) ខែត្រមុខកំពុត (ឬហៅលជាមុខកំពូល)

ភ្នំក: បូជនីយដ្ឋានធ្វើពីឥដ្ឋ

### ខ) ខែត្រព្រៃវែង

គាំប្រផុស: សិលាចារិកមួយ

---

១ ស្ទឹងត្រែងពីដើមនៅក្នុងខែត្រក្រចេះ, ឥឡូវនៅក្នុងខែត្រកំពង់ចាម ។

## គ) ខេត្តបាភ្នំ

ព្រះវិហារធំ: សិលាចារិកមួយ; មានរូបចំឡាក់បាក់បែក

ព្រះវិហារតូច: បូជនីយដ្ឋានធ្វើពីឥដ្ឋនឹងលោហធាតុដែក

ក្ដីអង្គ: សិលាចារិកបាក់បែក

ក្ដីត្រប់: ក្បាច់ចំឡាក់-សិលាចារិក

ព្រះវិរ: សិលាចារិក

ព្រះក្រឡាញ់ធំ: សិលាចារិក: ក្បាច់ចំឡាក់

កូ. ជ្រៀប:[១] បូជនីយដ្ឋានឥដ្ឋ

ព្រៃបា: បូជនីយដ្ឋានឥដ្ឋ

## ឃ) ខេត្តសីធរកណ្ដាល

វត្តពោធ: សិលាចារិក

ព្រៃបុងស្រុក: បូជនីយដ្ឋានឥដ្ឋ

## ៥– ទីអេស៊ុដន៍ស្វាយរៀង

### ខេត្តស្វាយរៀង

អេស៊ីជង្ស: លិង្គ (ព្រះឥសូរ) មួយ ក្បាច់សិល្ប នៅលើគ្រោងទ្វារបាក់បែក

---

១ ប្រហែលជាកញ្ច្រៀច ?

សំរោង: សិលាចារឹក

## ៦ — ទីរ៉េសុីដង់តាកែវ

### ក) ខេត្តទ្រាំង

ដាច់-ជុំ, វត្តក្រោម: សិលាចារឹក

ដាច់-ជុំ, វត្តលស់: សិលាចារឹក

ប្រាសាទភ្នំបាយ៉ង់: ធ្វើពីឥដ្ឋនឹងលោហធាតុដែក

គុស: សិលាចារឹក

ត្រមៀង: សិលាចារឹក

### ខ) ខេត្តព្រៃកប្បាស

អង្គបុរី: សិលាចារឹក

ប្រាសាទភ្នំដា: បួនទីយដ្ឋានធ្វើពីលោហធាតុដែក រូបចំឡាក់

គុកមហាឫសី: ប្រាសាទធ្វើពីថ្មភក់

អន្លក់: សិលាចារឹក

ព្រៃផ្គាំ: សិលាចារឹក

បំនង: សិលាចារឹក

## គ) ខេត្តបាទី

ភ្នំជីសូរ: ប្រាសាទមានកំពែង, យ៉ធ្វើពីថ្មភក់, ថ្មលោហធាតុដែក និងឥដ្ឋ; ដណ្ដើរ, ប្រាសាទអាណាប សែនថ្កុល និងសែនហាវណ: សិលាចារឹកមួយ

ប្រាសាទនាងខ្មៅ: បូជនីយដ្ឋានពីរធ្វើពីឥដ្ឋ, សិលាចារឹកមួយ

ប្រាសាទស្រះកែវ: បូជនីយដ្ឋានមួយធ្វើពីឥដ្ឋ, វត្តគោត, សិលាចារឹក

ភ្នំតាម៉ៅ: បូជនីយដ្ឋានធ្វើពីឥដ្ឋ ក្បាច់ចំឡាក់

ភ្នំបុជុះ: បូជនីយដ្ឋានធ្វើពីឥដ្ឋ ក្បាច់ចំឡាក់

បាទីយាយពៅ: បូជនីយដ្ឋានធ្វើពីថ្មភក់

បាទីតាព្រហ្ម: ប្រាសាទមានកំពែងធ្វើពីថ្មភក់ និងលោហធាតុដែក: សិលាចារឹក, ក្បាច់ចំឡាក់

(មានត)

# រឿងសម័យថ្មី

---

និទានមានរឿងមួយ ក្នុងគ.ស. ១៩៥១ កន្លងទៅហើយថ្មីៗនេះគឺ នៅភូមិហាំចិនហ្សេន (Hechingen) ជិតទីក្រុងស្តុតការ៍ (stuttgard) ប្រទេសអាល្លឺម៉ង់ មានគ្រួសារអាមេរិកមួយឈ្មោះវ៉ាល្លិសហ្សែរ (Wallishauser)ៗ គ្រួសារនេះមានបងប្អូននៅប្រទេសអាមេរិក ។ បងប្អូននៅប្រទេសអាមេរិក តែងផ្ញើតាមប្រៃសណីយ៍ ទៅវ៉ាល្លិសហ្សែរជារឿយៗ នូវកញ្ចប់មានគ្រឿងបរិភោគនឹងអីវ៉ាន់ផ្សេងៗ ។

ថ្ងៃមួយនោះ វ៉ាល្លិសហ្សែរ បានទទួលកញ្ចប់មួយ ។ ក្នុងបណ្ដាចំណីបរិភោគទាំងឡាយ វ៉ាល្លិសហ្សែរឃើញមានប្រអប់មួយស្អាតល្អ ដែលពេញទៅដោយវត្ថុមានភាពប្រហែលគ្នានឹងម្សៅ ដួនជាថ្ងៃនោះជាថ្ងៃជប់លៀងក្នុងគ្រួសារផង ក៏វ៉ាល្លិសហ្សែរនឹកក្នុងចិត្តថា "បងប្អូនអញនៅអាមេរិកនេះ ដូចជាដឹងចិត្តតែម្ដង! ពេលឯងជប់លៀងចេះផ្ញើម្សៅនេះមកឲ្យឯងស្ងោរស៊ុប" ក៏វ៉ាល្លិសហ្សែរយកម្សៅនោះអស់ពាក់កណ្ដាលប្រអប់ដាក់ទៅក្នុងឆ្នាំងស្ងោរស៊ុបខ្លួនគេ តាំងស្ងោរអស់ពេលវេលាជាយូរ ទឹកស៊ុបនៅតែថ្លា ទើបវ៉ាល្លិសហ្សែរបែកប្រាជ្ញាយកម្សៅជំនួសថែម មិនយូរប៉ុន្មានឡើងរសល្មមៗ ទឹកស៊ុបទៀតក៏ឡើងខាប់ល្អ ។

ដល់ពេលបរិភោគ ជួបជុំគ្រួសារ ព្រមទាំងកូនស្រីម្នាក់របស់វ៉ាល្លិសហ្សែរ ដែលនៅជិតគ្នានោះ ក៏បានអញ្ជើញមកដែរ អង្គុយជុំតុមួយ

លិទ្ធមាត់លិទ្ធកក្អាកក្អាយសប្បាយ ដោយបានស៊ីបចំរើបថ្មី ៗ ក្នុងពេល
នោះតាំងពីកូនពៅរហូតដល់មនុស្សចាស់ នាកាលបោយយកស៊ីបមក
ដាក់ឲ្យនាំគ្នាហុតហើយសំឡឹងមុខគ្នា យល់ស្របថាស៊ីបនេះឆ្ងាញ់មែន
មានឱជារសល្អមែន ៗ នាងក្ញយស្រីនោះ បានហៅឲ្យបោយថែមដល់ទៅ
៣ ដង ! ៗ

រឿងនេះយើងឈប់ស្ទះលែងទឹកដល់តទៅទៀត ៗ

ក្រោយពីពេលដប់លៀងនេះកន្លងមកបានពីរថ្ងៃ ព៉ល្លិស្វៃហ្សរបាន
ទទួលសំបុត្រមួយពីអាមេរិក ៗ ពេលល្ងាចត្រដាក់ ព៉ល្លិស្វៃហ្សរហៅ
គ្រួសារជួបជុំ ដើម្បីអានសំបុត្រឲ្យដឹងដំណឹងសុខទុក្ខគ្រប់គ្នា ៗ លុះមកជួប
ជុំគ្នាកាលណាហើយ ព៉ល្លិស្វៃហ្សរក៏ហែកសំបុត្រ ហើយអានខ្លាំង ៗ
សេចក្ដីថាប៉ុណ្ណេះជាដើម :

"យើងខ្ញុំមានសេចក្ដីទុក្ខសោក ជូនដំណឹងថា ជីដូនយើងគាត់
អនិច្ចកម្មទៅហើយ ! មុនគាត់ទឹងរំលាងខ្លួន គាត់បានផ្ដាំថា ឲ្យយក
ធាតុគាត់ទៅបញ្ចុះនៅភូមិហ៊ិចិនហ្សេន ដែលជាកន្លែងគាត់កើតកុំឲ្យខាន ៗ
"ឥឡូវនេះ យើងផ្ញើធាតុគាត់ នៅក្នុងប្រអប់ដាក់ក្នុងកញ្ចប់នេះ ដើម្បី
ឲ្យបងប្អូននៅប្រទេសអាល្លឺម៉ង់ សំរេចកិច្ចតាមបណ្ដាំជីដូនតទៅ" ៗ

សំបុត្រនេះបានអានចប់ហើយកាលណា ក៏អ៊ូអរកងរំពងថា "យក
ជីដូនស្ងោរស៊ុប! យកជីដូនស្ងោរស៊ុប! យកជីដូនស្ងោរស៊ុប! ឆោឡា

ឡើងគ្រប់គ្នា ខ្លះបង្គោរ ខ្លះខាក ខ្លះស្ដោះ ខ្លះញ័រសាច់ ខ្លះខ្យល់ចាប់ . . នាងកយនោះឈឺខ្លាំងជាងគេ !... ឈឺទាំងអស់គ្នា ទន់ដៃទន់ជើងទាល់តែរទេះដឹកអ្នកជម្ងឺមកដឹកទាំងគ្រួសារទៅដេកពេទ្យ ឈឺមែនទែន មុខថ្លស់ក្អកសក្បុះស្រងូតៗ គ្រប់គ្នា . . . នឹកឃើញរឿងនេះឡើងកាលណាស្អើម ផាលចេញមកពីក្នុងពោះអត់ទ្រាំមិនបាន . . . ដេកពេទ្យអស់កន្លះខែ ទើបបានស្រាកឈឺគ្រាន់បើ . . . ។

រឿងនេះ យើងជាពុទ្ធមាមកៈគួរកើតសង្វេគកល់រូប ៗ រូបដូចនេះមិនខុសគ្នាពីរូបយើងកល់គ្នា ៗ កាលយើងនៅរស់មានជីវិត យើងបេះរីកកាយអបអរស្រឡាញ់រាប់អានគ្នា; ឲ្យតែផុតខ្យល់ពីចុងច្រមុះហើយ រូបនេះទៅជារបស់មួយដែលគេខ្ពើម សូម្បីតែទៅជាផេះទៅហើយ ហើយគ្រាន់តែច្រឡំយកទៅស្ងោរស៊ុប បរិភោគរួចពីរបីថ្ងៃទៅហើយ ទុះនោះលោមកដឹងជាក្រោយ ក៏អាចនាំឲ្យទៅជាឈឺគ្រប់គ្នាក្នុងគ្រួសារ មានឧទាហរណ៍ដូចខាងលើស្រាប់ ។

ហេតុនេះ បើយើងប្រុសគួរធ្វើខ្លួនឲ្យទៅជា អសុភានុបស្សី ចុះបើបែរជាស្រីនោះគប្បីឲ្យទៅជា អសុភានុបស្សិនី កុំឃ្លៀងឃ្លាតឡើយ ។

ភ៉យ - ល្អុត

# សកុន្តលា

(ដកពីសៀវភៅលេខ ១២ — ឆ្នាំ ១៩៥១)

---

— ៨ —

## ព្រះរាជកុមារព្រៃ

ពាក្យ ៨

ទីងថ្ងៃពីមេនកាស្រស់កល្យាណ សែនសោយសុខក្សេមក្សាន្តស្ថាន
កោសីយ៍

ឥតខ្វល់ខ្វក់តក់ស្លុតនឹងបុត្រី ចិត្តអប្រិយដូជាតិឃ្លាតច្បាប់ក្បួន ៗ
គិតតែលេងក្មេងភ្លាត់មាត់ប្រៀងផ្សំ នឹងពួកស្នំលំហែលំហើយខ្លួន
ប្ដូរខ្លះខ្វងតែងកាយយ៉ាងសមសួន ខំតែស្ងួនរូបឆោមឲ្យឆើតឆាយ ៗ
មានថ្ងៃមួយទេវីដេញពិណលេង លាន់គគ្រេងគគ្រឹមសើចសប្បាយ
ដួនខ្សែពិណដាច់ម៉ាត់បាត់សៀងសាយ ក្ដៅក្រហាយស្ដាយខាតការ
កំសាន្ត ៗ

ក៏ព្រួចព្រឹក្សស្បូរចូររបេល ផ្សាយតាមខ្យល់ដល់នាងក្មាងរំភាន
គឺស្បូវសៀងសកុន្តលាកែវកល្យាណ មុនបោកប្រាណសន្ធប់បាត់ស្មារតី ៗ
មេនកាព្រួយហើយកើតស្រយុត អាណិតបុត្រស្លុតចិត្តគិតប្រណី
ម្តមាហោះផ្លោះចាកស្ថានកោសីយ៍ ទៅត្រកងបុត្រីយកទៅ ៗ
លឿនដូចខ្យល់ដល់ភ្នំកំពូលមាស ក្នុងកាសចំពោះស្រស់ខ្ពុំខ្ពៅ
ផ្ដេកកូនស្នេហ៍ថៃថ្លាសដោយទៅភើ លុះឆោមផ្ដៅដឹងខ្លួនបើកនេត្រា ៗ

បានយន់យល់ទេវីនៅពីមុខ នាងគ្រាន់បានក្សាន្តទុក្ខបុកឧរា
សួរដើមដានបានដឹងជាមាតា សកុន្តលាប្រារព្ធរឿងកំសត់ ។
មេនកាសាសងលួងលោមស្ដី រួបធ្វើស្រីនៅក្នុងអាស្រមបទ
នៃឥសីកស្សបដែលហ្មត់ចត់ កសាងព្រតលើភ្នំកំពូលមាស ។
ទេពអប្សរចុះមកថៃថួន មើលមាសសួនហូរហៃតែពេញពាស
កុំឲ្យនាងកើតទុក្ខព្រោះនិរាស សូន្យវិនាសសុខភាពអសារបង់ ។

តែនិមិលខ្វល់ចិត្តតតមានហ្លៃ រលឹកតែស្វាមីស្រីធោមយន់
មិនអស់ចិត្តត្បិតក្ស័ត្រកាត់មិនគង់ សំដីទ្រង់ដោះដៃចោលថ្ងៃទៅ ។
សែនខ្លោចផ្សាឧរាឆាបឆួលឆេះ ស្ទើរលេះរលួយចាំនិត្យនៅ
កើតទុក្ខទ្រមស្គាំងស្គមអស់រាងរៅ មិនដឹងទៅទីណាកំឡាចិត្ត ។
ពួកបំរើធ្វើម្ដេចគេចមិនស្រាន្ត សែនរំខានប្រាណប្រឹងតែពិនិត្យ
រឿងវេទនាជានិច្ចផុតគំនិត ទឹងរិះគិតបន្ទៃបន្ទប់បាត់ ។
គេនៅចោមរោមជុំលេងគឹកកង សព្វសាសងធ្ងងធ្ងើយអ៊ូរអក្តាត់
តែនាងនាថចម្បែងតែឯងស្ងាត់ មិនអាចកាត់ឲ្យល្ហែថូរថ្ងៃថា ។
“ឱព្រះបង់ម្ដងនេះគ្មានអាល័យ គ្មានអាលោះដោះដៃចោលខ្ញុំណា
ចោលខ្ញុំនៅចម្បែងឯងឯកា ឯងឯកោខ្លោចផ្សាឧរាក្ដៅ ។
ឧរាក្ដួលឆួលឆេះនឹមមិនបាត់ ឆាកមិនបានឃើញក្ស័ត្រមូលនិត្យនៅ
មូលនិត្យនៃបអែបទីងព្រលឹងពៅ ព្រលឹងពេញទុក្ខជ្រៅនៅឯកកាយ ។

នៅឯកាជ្រប់មុខទុក្ខព្រួយព្រម ទុក្ខព្រួយព្រើលមិនល្មមទ្រមព្រោះស្តាយ
ទ្រមព្រោះស្តុបគេបកែប្រែជិនណាយ ប្រែជិននឿយឆោមឆាយឆ្ងាយ
ពីស្រី ។

ឆ្ងាយពីស្រស់អស់ចិត្តត្រូវអស់ចង់ ត្រូវអស់ជាតិឃ្លាតអង្គផ្គង់រកថ្មី
ផ្គង់រកថ្មាងតោងយករូបពិសី រូបពិសេសមេត្រីជាថ្មីទៀត ។
ជាថ្មីទៅពៅគ្មានឃាត់ឃាំងទេ ឃាត់ឃាំងតែមករេរិះឈ្លបឈ្លៀត
រិះឈ្លបឈ្លបញេ្ចបអង្គឲ្យបង្វៀត ឲ្យបង់ស៊ាយថយស្ទៀតលះបង់បោះ ។
លះបង់បាត់មិនគួរមានជីវិត មានជីវិតគិតគិតអ៊ីជល់ម៉្លោះ
អ៊ីជល់ម៉្លោះបេះរស់នៅផ្ទួប្តោះ នៅផ្ទួប្តេះស្ទួយសោះហាក់ដូចស្លាប់ ” ។
នាងសោយសោកអាមោក្ខឥតស្រាកស្រាន្ត ទុក្ខទំព្រាណផលទេត្រឃាត់
មិនស្ដាប់
កើតសង្រេងសង្រែគ្មានសណ្ដាប់ មិនក្រឡាប់ប្រែចិត្តជាថ្មីឡើយ ។
លុះប្រសូតបុត្រភ្ញាស្រស់បញ្ចាង់ ល្អអស់អង្គត្របះទើបល្ហៃល្ហើយ
គ្រាន់ក្សាន្តទុក្ខមុខស្រស់គិតត្រាណត្រើយ បានធូរស្បើយស្រស់ស្រាយ
សប្បាយចិត្ត ។
ឯបុត្រនាងឥសីលោកប្រទាន ឈ្មោះសរិទាមានរុងរឿងបុទ្ធិ
រូបបីដូចចន្ទពេញបុណ្ណមីពិត គួរផ្ទេកផ្ទិតស្និទ្ធស្នាលត្រអាលអរ ។

លុះកុមារចំរើនវ័យប្រាំពីរឆ្នាំ　អស់សត្វចាំគាល់ហៅដោយស្មោះស័រ
តាមបំរើគោរពពេញកុះករ　រត់ឈ្មួចវៃហាហមប្តមកុមារ ។
តាំងបល្ល័ង្កក្រោមពោធិ៍ធំស្កឹមស្កៃ　បាំងវែងថ្ងៃត្រដាក់ស្រួលអស្ចារ្យ
ប្រាំពីរយោជន៍ជុំវិញតាំងរាជការ　បរិវារគឹកកងរំពងព្រៃ ។
ពេលព្រឹកព្រានហត្ថីត្រកង　ក្បែត្របាសប្បងហៃទៅខ្ពស់លៃ
នាំកុមារចុះស្ទឹងស្រួបទឹកវៃ　ស្រោចស្រប់ថ្ងៃជំរះសព្វពង្គកាយ ។
ទើបនាំមកដើមពោធិ៍ដាក់ភូបាល　នៅលើក្បាលពស់ថ្នាន់បុទ្ធិសាយ
ដែលរក្សាពោធិ៍នោះឥតទៅឆ្ងាយ　ថ្នាន់ខ្វល់ខ្វាយដំឡើងពពាបាំង ។
គ្រប់ជុំជិតបីជូបព្រះរាជកូស　បើកខ្ពង់ខ្ពស់ការពារវែងស្ប្យចាំង
ព្រមក្មេងផ្គរទឹងអស់សត្វខ្លាំង　សម្បើមខ្លាំងឥតក្ដិកក្ដុងព្រឹក្សា ។
ឯដំរីខ្លាឃ្លាតកាចស្ទុកឈ្លូក　ប្រមោយលូកបក់ផាត់ត្បូកាយា
ឲ្យរហើយដល់អង្គកុមារា　ថែរក្សាផ្លាស់គ្នាជានិច្ចកាល ។
ឯខ្លាឃ្មុំជាអគ្គមហាសេនា　សិង្ហសង្ហាមេទ័ពអ្នកផ្ចាញផ្ចាល
បច្ចាមិត្រស្ញប់ស្ញែងក្រែងសព្វកាល　សិង្ហប្រឹងក្រាលបារមីរស្ងួតឆ្ងាយ ។
ចំណែកខ្លាអង្គក្រុងអ្នកចាំថៃ　ចាំដង្ហែកុមារជិតព្រះកាយ
តែងបន្ទឹសំរែកស្នូរសៀងសាយ　សត្វទាំងឡាយខ្វបខ្វាបជាប្រក្រតី ។
ខាងថ្កៃព្រៃលៃបើផ្តើតំរួត　ជានាយត្រួតប៉ូលិសប៉ុនល្បាញល្បី
ចែងចាត់ការយាមល្បាតកាលរាត្រី　ថៃនរបតីកៀកកិតឥតឲ្យហ្មង ។

មានមហាគលិកមួយដែរគឺសត្វសេក    ជាងសំដីអនេកពេកកន្លង
សម្បូណ៌បែកព្រោកប្រាជ្ញសព្វសាសន៍ ប៉ុនចាំចងរឿងការស្រុកឆ្ងាយជិតៗ
ទំនានថ្វាយកុមារជាកំសាន្ត    តាំងខ្លួនប្រាណបំពុះបន្ទុស្និទ្ធ
ចាក់ក្រមាចក្បាច់តុកថ្វាយទ្រង់បុទ្ធិ    រីករាយចិត្តក្អាកក្អាយសប្បាយក្រៃៗ
ភជកុមារថ្នមថ្នាក់កូនបក្សី    ដោយមេត្រីស្រភាយសង់ប្រស្រ័យ
តោងមែកពេចធ្មើទោងយោងយោលដៃ    តាមទិស្សយ័រយ័ក្នុងលេង
ទឹងសត្វ ៗ

ពួកពានរឈររបេះប្រលេះផល    គ្នារចល់បិយកមកថ្វាយក្សត្រ
ឲ្យស្ដេចសោយតាមពេលគ្មានអត្ដខាត់ សុខស្រួលក្ដាត់លើភ្នំកំពូលមាសៗ

ប៉េង — យ៉ាន់

(មាឌត)

អក្សរសាស្ត្រ    ប្រាជ្ញលោកប្រកាស
ជាពិតប្រាកដ    ជាពន្លឺជាតិ
ភ្លីស្អាតបាតបង់,    អក្សររលត់
ជាតិក៏រលាយ;

ប. ព.

## បញ្ញត្រ្តៈ

# រឿងជាងតម្បាញក្លែងភេទជាព្រះវិស្ណុ

(តមកពីសៀវភៅលេខ ១២ ឆ្នាំ ១៩៥១)

---

អ្នកតម្បាញ កាលបានស្ដាប់ពាក្យព្រះរាជបុត្រីនិយាយប្រាប់ហើយក៏ព្រួយចិត្តខ្លាំង ព្រោះគិតទៅឃើញថា "កាលបើសត្រូវវាយយកព្រះរាជធានីនេះបាន ខ្លួនអាត្មាអញនេះក៏ត្រូវស្លាប់ដែរ ហើយនឹងព្រាត់ប្រាសខានបានជួបមុខភរិយាទៀត បើដូច្នោះ គួរអាត្មាអញឡើងជិះលើគ្រុឌយន្តហើយហោះឡើងលើអាកាសវេហាស៍ សំដែងឫទ្ធិឲ្យកងទ័ពបច្ចាមិត្រមើលឃើញ កាលបើសត្រូវមើលឃើញហើយ នឹងសំគាល់អាត្មាអញនេះថាជាព្រះវាសុទេព (ព្រះនារាយណ៍) ពិតមែន មុខជានឹងបាក់បបខ្លបខ្លាបរត់ខ្ចាត់ខ្ចាយមិនខាន ណាមួយ ត្រូវស្លាប់ដោយកម្លាំងសែនទ្យា-នុភាពនៃធ្នូពុកកេ្ខកអាត្មាអញផង, ព្រោះថា :–

២០៤ សត្វពស់ បើទុកជាមិនមានពិសក៏ត្រូវតែបញ្ចេញពពាហើយបើកវែកដែរ ទោះជាមានពិសក្ដីមិនមានពិសក្ដី ការបើកវែកជាការមួយនាំឲ្យគេភ័យខ្លាច ។

មួយទៀត, បើអាត្មាអញហោះឡើងលើអាកាស ដើម្បីការពារព្រះរាជធានីនេះ អាត្មាអញមុខជានឹងត្រូវស្លាប់មិនខាន តែបើស្លាប់ជាក៏ល្អមើលដែរ, ព្រោះថា :–

២០៥[១] នរណាមួយលះបង់ជីវិតខ្លួន ដើម្បីគោព្រាហ្មណ៍ គ្រូ ភរិយានឹងពជធានីរបស់ខ្លួន នរជននោះនឹងមានខ្លួនជាទីពឹង" ។

លុះគិតស្រេចយ៉ាងនេះហើយ អ្នកតម្បាញផុសលាងមុខមាត់ពីបច្ចូសសម័យហើយនិយាយនឹងព្រះរាជបុត្រីថា: "មាសថ្លៃបងអើយ! កាលណាសត្រូវវិនាសស្លាប់អន្តរាយអស់ហើយ កាលនោះបងនឹងបានបរិភោគរសអាហារនឹងទឹក តពីនោះទៅមិនយូរប៉ុន្មាន បងលែងបានមកជួបមុខប្អូនមាសថ្លៃតទៅទៀតហើយ ប៉ុន្តែប្អូនទៅក្រាបទូលព្រះវររាជបិតាថា ឲ្យបរិពលសេនានុភាពទាំងអស់បណ្ដាដែលសល់ទាំងប៉ុន្មាន ចេញពីព្រលឹមហើយចូលលុកលុយសត្រូវ ចំណែកខាងបង បងនឹងហោះទៅលើអាកាសវេហាស៍ហើយបំភ័យអរិន្ទរាជសត្រូវឲ្យខ្លបខ្លាចតេជានុភាពរបស់បង ធ្វើដូច្នេះសកលយោធាព្រះវររាជបិតាងាយប្រយុទ្ធសម្លាប់សត្រូវពីខាងក្រោយខ្នង ជ: បើមិនធ្វើដូច្នេះទេ បងនឹងសម្លាប់សត្រូវទាំងឡាយនោះដោយខ្លួនបង តែសត្រូវទាំងឡាយដែលស្លាប់ទៅហើយដោយដៃបងនឹងទៅកើតស្ថានសួគ៌ទាំងអស់ ក្នុងករណីយ៍នេះ ត្រូវតែសកលយោធាព្រះវររាជបិតាសម្លាប់ឲ្យខ្ទេចខ្ទីដោយដៃខ្លួនឯង ដើម្បីកុំឲ្យវាបានទៅ

---

១ បញ្ចតន្ត្រៈ សេចក្ដីប្រែជាភាសាបារាំងនៃលោកឡង់ស៊ឺរ៉ូ មានគាថាពើសដូច្នេះ គឺៈ បើមានចន្ទ្រគ្រោះ ឬសូរ្យគ្រោះ អ្នកណាដែលរងគ្រោះដោយការពារជនដទៃ អ្នកណាមានជ័យ អ្នកនោះត្រូវបានពាក្យសរសើរ ។

កើតក្នុងស្ថានសួគ៌ ។ ព្រះរាជបុត្រីបានព្រះសណ្ដាប់ដូច្នោះហើយ ត្រេកអរណាស់ ស្ដេចយាត្រាយកសេចក្ដីទៅក្រាបបង្គំទូលព្រះវរបិតាភ្លាមតាមបង្គាប់អ្នកតម្បាញ ។ ឯព្រះរាជាក៏រឹតតែជឿថែមឡើងទៀត ទ្រង់ក្រោកពីព្រលឹមហើយស្ដេចបរពលយោធា ដ៏មានរបៀបរៀបរយចរចេញទៅដើម្បីលុកចូលប្រយុទ្ធ ។ ឯអ្នកតម្បាញជាប់ចិត្តទឹងស្មាប់ខ្លួនយ៉ាងនេះហើយ ក៏ហោះហើរលើអាកាសរហោស៍ កាន់កៅទណ្ឌសរនៅដៃហើយចេញទៅដើម្បីធ្វើសង្គ្រាម ។

កាលនោះ ព្រះនារាយណ៍ដ៏មានបុណ្យ ដែលជាអ្នកដឹងអតីតអនាគត បច្ចុប្បន្ន មានព្រះបន្ទូលដោយញញឹមចំពោះបុត្រនាងវិនតា(១) ដែលចូលមកក្រាបបង្គំគាល់តាមតែព្រះចិន្ដាថា: "នៃគ្រុឌ! ឯងដឹងទេអ្នកតម្បាញនេះក្លែងភេទខ្លួនជាអាត្មាអញ ជិះគ្រុឌឈើយន្ត ទៅបង្កូនស្រីស្ដេច?" ។ គ្រុឌឆ្លើយតបថា: "បពិត្រព្រះទេពម្ចាស់លោក! ខ្ញុំទូលបង្គំបានដឹងព្រឹត្តិការណ៍នេះដែរ ឥឡូវនេះ តើយើងត្រូវធ្វើដូចម្ដេច?" ។ ព្រះនារាយណ៍ដ៏មានបុណ្យឆ្លើយតបថា: "ថ្ងៃនេះ អ្នកតម្បាញសុខចិត្តស្លាប់ ហើយចរចេញទៅដើម្បីច្បាំង ក្នុងចម្បាំងគង់នឹងមានយោធាណាម្នាក់ចំណានបាញ់សរដ៏មុតមកត្រូវស្លាប់មិនខានទេ កាលណាក៏ស្លាប់ទៅមុខជាសកលយោធាទាំងអស់មកប្រជុំគ្នាហើយនិយាយថា

១ គ្រុឌជាយានជំនិះ ជាកូននៃនាងវិនតាដែលជាភរិយាព្រះកស្សប ។

បានបាញ់សម្លាប់ព្រះរាំសុទេព(១) នឹងគ្រុឌហើយ តទៅ លោកតាំងមូលទឹងលែងគោរពអាត្មាអញទៀតហើយ បើដូច្នេះ ឯងចូលទៅឲ្យឆាប់ៗ! ទៅចូលក្នុងរូបគ្រុឌយន្ត ឯអាត្មាអញនឹងទៅជ្រែកចូលក្នុងរូបអ្នកតម្បាញ ដើម្បីនឹងឲ្យអ្នកតម្បាញបាញ់សត្រូវយកជ័យបាន, ដោយការបំផ្លិចបំផ្លាញសត្រូវបាននេះ តេជានុភាពយើងនឹងរឹតធំឡើងមិនខាន លុះព្រះនារាយណ៍នឹងគ្រុឌប្រឹក្សាគ្នាយល់ព្រមហើយ គ្រុឌជ្រែកចូលទៅក្នុងរូបគ្រុឌយន្ត ព្រះនារាយណ៍ក្នុងរូបអ្នកតម្បាញ ។ ដោយតេជានុភាពព្រះនារាយណ៍ដ៏មានបុណ្យចូលក្នុងខ្លួនអ្នកតម្បាញ ដៃកាន់កង់ចក្រស័ង្ខដំបងនឹងកៅទ័ណ្ឌបិតនៅលើអាកាសតែមួយស្របក់ ដូចជាគេលេងកីឡាបណ្ដាលឲ្យកងទ័ពសត្រូវដែលក្លៀវក្លាទៅជាខ្សោយកំលាំងចិត្ត ត្រូវកងទ័ពព្រះរាជាចូលលុកវាយបកជ័យស្លាប់អន្តរាយអស់ ហើយលេចឮរន្ទឺពេញលោកថា ព្រះរាជាឈ្នះសត្រូវ ហើយដោយបានព្រះនារាយណ៍ជាព្រះរាជជ័តុបតិ ។

ឯអ្នកតម្បាញបានឃើញអរិរាជសត្រូវចាលចាញ់គេជាដៃស្លាប់វិនាសអន្តរធានដូច្នោះហើយ ត្រេកអររីករាយសប្បាយចិត្តណាស់ ក៏ចុះពីអាកាសនភាល័យមកវិញដោយក្ដីរុងរឿងដ៏ក្រៃលែង ។ កាលដែលអ្នកតម្បាញចុះមកដល់ផែនពសុធា ពពួកអាមាត្យយោធាមុខមន្ត្រីរាជបរិពារព្រមទាំង

---

១ ព្រះនារាយណ៍ ។

អ្នកនគរទាំងឡាយដែលស្គាល់ច្បាស់លាស់នូវអ្នកតម្បាញ នោះថាមិនមែន ជាព្រះនារាយណ៍ដ៏មានបុណ្យទេ គឺជាអ្នកតម្បាញដែលខ្លួនធ្លាប់ស្គាល់មក ហើយ បបួលគ្នាឈ្លូនទៅសាកសួរដំណើរដើមទងដែលនាំឲ្យមានព្រឹត្ត-ការណ៍ដូច្នេះ ។ អ្នកតម្បាញក៏រៀបរាប់ប្រាប់តាំងពីដើមរហូតដល់ចុង ។ ព្រះកុម្ភបាល ទ្រង់មានជ័យមង្គលដោយបានបង្រាបព្រះអរិរាជសត្រូវឲ្យ ហិនហោចហើយ មានព្រះរាជហឫទ័យត្រេកអរខ្លាំងក្រៃលែង រឹងរឹតតែមាន ព្រះទ័យប្រតិព័ទ្ធចំពោះព្រះរាជធីតុបតិថែមឡើងទៀត ព្រះរាជទានព្រះរាជបុត្រីដល់អ្នកតម្បាញ រៀបចំវិវាហមង្គលាភិសេកនៅចំពោះអាមាត្យមុខមន្ត្រីដោយសេចក្ដីរុងរឿង ព្រមទាំងព្រះរាជទានឲ្យសោយរាជ្យស្នងព្រះអង្គផង ។ អ្នកតម្បាញព្រមមួយអន្លើដោយព្រះអគ្គមហេសី សោយក្ដីសុខទាំង ៤ ប្រការសមតាមក្ដីប្រាថ្នាដែលជាសារប្រសើរក្នុងជីវលោកនេះ បានជាលោកពោលថា: "ការឆបោកដែលគេប្រើប្រកបឲ្យត្រូវទំនង ហើយអាចឲ្យសម្រេចផលបាន" ។

ចចកករដកៈ: បានស្ដាប់ចចកទមនកៈនិយាយរៀបរាប់ចប់សេចក្ដី ហើយ និយាយតទៅទៀតថា "សំឡាញ់អើយ! ពាក្យឯងនិយាយនេះ ពិតមែនហើយ តែរូបខ្ញុំនៅតែមិនទាន់អស់សង្ស័យទេ នៅតែមានបារម្ភខ្លាច ព្រោះសញ្ជីវកៈមានប្រាជ្ញា ឯសីហៈកាចឃោរឃៅណាស់ ក្រែងឯង មិនអាចនឹងធ្វើការបំបែកចេញពីគ្នាបាន?" ។ ចចកទមនកៈឆ្លើយតបវិញ

ថា: "នែសំឡាញ់! អ្នកខ្សោយអាចទៅជាអ្នកខ្លាំងបានដែរ ដោយវិធីនេះ ខ្ញុំអាចនឹងសម្លាប់សញ្ជីវកៈបានដោយពន្លឺប្រាជ្ញារបស់ខ្ញុំ ព្រោះថា:–

២០៦ – សរដែលនាយខ្មាន់ធ្នូបំណានបាញ់ទៅហើយ បើមិនត្រូវមួយក៏ត្រូវមួយទៀតដែរ ឯខានមិនខានទេ ឯប្រាជ្ញានៃអ្នកប្រាជ្ញក៏ដូច្នោះដែរ កាលបើបញ្ចេញទៅហើយ អាចនឹងសម្លាប់ប្រជារាស្ត្រទាំងមូល ព្រមទាំងព្រះរាជាផង" ។

ទីបំផុតចចកករដកៈនិយាយជូនពរថា: "បើដូច្នោះ អានុភាពប្រាជ្ញាឯងមានយ៉ាងណា ចូរធ្វើយ៉ាងនោះចុះ សូមឲ្យសំឡាញ់ប្រកបកិច្ចការបំផ្លាញសញ្ជីវកៈនេះឲ្យបាន" ។ ចចកទនកៈឆ្លើយតបដោយម៉ឺងម៉ាត់ថា: "សំឡាញ់ ព្រឹកស្អែកនេះ ការណាដែលមិនទាន់សម្រេចនឹងសម្រេចពិតហើយ, ព្រោះថា:–

២០៧ – កិច្ចណាមួយដែលគេមិនអាចធ្វើឲ្យសម្រេចបានដោយព្យាយាមទេ កិច្ចការនោះគេនឹងអាចធ្វើឲ្យសម្រេចបានដោយឧបាយ ក្អែកដើរឧបាយលួចខ្សែកជាវិការនៃមាស សម្លាប់ពស់វែកបាន" ។

ភិក្ខុ ប៉ាង – ខាត់

(មានត)

# មហាសន្និបាត ឆ្នាំ ១៩៥២

ក្នុងថ្ងៃទី ១៣ ខែមករា ឆ្នាំ ១៩៥២ ពេលម៉ោង៨ព្រឹក, សមាគមមិត្តសាលាបាលីបានធ្វើមហាសន្និបាតនៅសាលាបាលីជាន់ខ្ពស់ បោះឆ្នោតជ្រើសរើសក្រុមអភិបាលនៃសមាគមសម្រាប់ឆ្នាំថ្មី ។ ពេលដែលអស់លោកជាសមាជិក បានអញ្ជើញមកជួបជុំហើយ, លោក ក៉យ-ប៊ុក អធិបតី បានថ្លែងសុន្ទរកថាបើកសម័យប្រជុំ ព្រមទាំងថ្លែងអំពីព្រឹត្ត-ការណ៍នៃសមាគមក្នុងឆ្នាំចាស់ផង ដូចមានសេចក្ដីដែលចុះផ្សាយ នៅខាងចុងស្រាប់ ។

លទ្ធផលនៃការបោះឆ្នោតរើសក្រុមអភិបាលថ្មីនោះ ដូចតទៅនេះ:—

លោក ក៉យ-ប៊ុក អធិបតី, លោក ផេង-ជ្រីវ និង ហេង-យ៉ាន់ អធិបតីរង, លោក ចាប-ពិន អគ្គលេខាធិការ, លោក ហាក់-ឆេត និង ម៉ម-ឃ៉ែម អនុលេខាធិការ, លោក អ៊ុច-រស់ អគ្គហេរញ្ញិក, លោក ម៉ៅ-មុី និង ក៉-ស៊ុយន អនុហេរញ្ញិក, លោក តៃ-ជុន និង ញូង-សឿង បណ្ណារក្ស ។

ក្នុងថ្ងៃក្រោយ លោក ម៉ម-ឃ៉ែម បានសុំលាឈប់ពីមុខងារក្រុមអភិបាលដោយលោកខ្សោយកំឡាំងព្រោះមានជម្ងឺរឿយៗ ពុំអាចនឹងជួយការបានពេញបន្ទុក ហើយសុំឲ្យដាក់លោកជាទីប្រឹក្សាវិញ, ក្រុមអភិ-បាលក៏បានសំរេចតាមសុំ ហើយបានតាំងលោក ហ៊ុ-ហេង ដែលជាប់

ឆ្នោតបន្ទាប់ពីលោក ម៉ម-យ៉ែម កាលជ្រើសរើសទៅថ្ងៃមហាសន្និបាត នោះ ឲ្យជាក្រុមអភិបាលជំនួសតទៅ ។

ទីប្រឹក្សាមានចំនួន ១៦ រូបគឺ សម្តេចព្រះមហាសុមេធាធិបតី សង្ឃ-នាយកគណៈមហានិកាយ ជួន-ណាត, សម្តេចព្រះសុធម្មាធិបតីសង្ឃ-នាយកគណៈធម្មយុត្តិ អ៊ុង-ស្រី, សម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា ល្វី-ឯម, ព្រះពោធិវ័ង្ស ហួត-តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់, ព្រះវិន័យសង្វរ ពជ-គឹង សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់, ឯ.ឧ. សម-ញាណ, ឯ.ឧ. ព៉យ-លុត, លោកឡាំ ឯម, ស្វាយ-ព៉, ជុំ-ទួត, សាម-ឡាមុត, អ៊ូ-គង់, ម៉ម-យ៉ែម, គុយ-ហ៊ុន, ធឹង-ចាប, អ៊ុង-កេត ។

ក្រុមអភិបាលបានជ្រើសតាំងគណៈកម្មការផ្សេងៗតទៅទៀតគឺ :

គណៈកម្មការទស្សនាវដ្តី: លោក ចាប-ពិន ប្រធាននិងបណ្ណាធិការ, លោក ប៊ូ-ប៉ូ អនុប្រធាន, ព្រះទេពសត្ថា សូរ-ហាយ, ព្រះគ្រូសង្ឃសត្ថា ប៉ុណ្យ-សុក្កាជ, ព្រះមហា ប៊ុង-ប៉ម, លោក តៃ-ជុន, អៀង-ថ្វាង, សៀង-ឌិន, ព៉-ស៊ីយន, ញូង-សឿង, ស៊ុន-ហ៊ិន សមាជិក ។

គណៈកម្មការសន្និសីទនិងឃោសនាការ: ឯ.ឧ. សម-ញាណ ប្រធាន, លោក ម៉ៅ-ម៉ី អនុប្រធាន, លោក អ៊ុច-រស់

ផេង-ជ្រីវ, ម៉ែ-ប៉ាន់, ហ៊ី-ហេង, ហាក់-ឆេក, កុយ-ហ៊ុន, ប៊ីង-ហ៊ាត, ចាប-ពិន, អ៊ុច-សេ, សាម-ឡាមុត សមាជិក ។

គណៈកម្មការស្រាវជ្រាវអក្សរសាស្ត្រ: លោក តែ-ជុន ប្រធាន; លោក នង-ដួន, ឈុន-ឌុច, ពៅ-ឈិន, ហ៊ុយ-កាំង, អ៊ី-សំឌក, វង្ស-ប៊ុនកុន, យូ-សន សមាជិក ។

គណៈកម្មការបោះពុម្ពសៀវភៅ: លោក ហេង-យ៉ាន់ ប្រធាន, ព្រះទេពសត្ថា សូរ-ហាយ, ភិក្ខុ ប៉ាង-ខាត់, លោក វរវុធ-វង្ស, សួស្ដី-នាង, ញូង-សឿង សមាជិក ។

(មានត)

អក្សរជាគោលរបស់ជាតិ
ខ្មែរគួរខំឃ្មាតគ្រប់រូបទ្បើង
ប្រើអក្សររបស់ខ្មែរយើង
ឲ្យបានថ្កុំថ្កើងអក្សរខ្មែរ !

ប. ព.

# ពិធីបុណ្យព្រហ្មទាន

ក្នុងថ្ងៃទី ៩ ខែមីនា ព.ស. ២៤៩៦ (គ.ស. ១៩៥២) សមាគមមិត្តសាលាបាលីបានផ្ដើមធ្វើបុណ្យព្រហ្មទានជាលើកទី ៣ ក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង គឺជាពិធីប្រគេនរង្វាន់ដល់សិស្សសាលាបាលីជាន់ខ្ពស់ចំនួន ៩៧ រូប ដែលទើបនឹងប្រឡងជាប់សញ្ញាបត្រក្នុងឆ្នាំ ១៩៥២ ។

ពិធីបុណ្យនេះបានរៀបចំធ្វើនៅឯសាលាបាលីជាន់ខ្ពស់ ចាប់តាំងពីល្ងាចថ្ងៃទី ៨ មីនាមក ដោយមានការចំរើនព្រះបរិត្តនិងធម្មទេសនា ដូចកាលពីឆ្នាំមុនដែរ ។ ប៉ុន្តែចំណែកទេយ្យទាន ឃើញថាបានបរិបូណ៌ណាស់លើសពីចំនួនសិស្សជាច្រើនជាងឆ្នាំមុនទៅទៀត ដោយសេចក្ដីជ្រះថ្លានិងការឧបត្ថម្ភដ៏មុតមាំនៃអស់លោកអ្នកពុទ្ធបរិស័ទទាំងឡាយ ។ ចំនួនលើសទាំងនោះ សមាគមបានចាត់ចែងប្រគេនថែមទៀត ដល់សិស្សដែលប្រឡងជាប់តាំងពីលេខខ្ពស់ៗ រៀងចុះជាលំដាប់ដរាបដល់អស់ទេយ្យទាន ។

ក្នុងថ្ងៃទី ៩ មីនា ពេលម៉ោង ១៦ ខ្វះ ១០ នាទី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានស្ដេចយាងទៅជាព្រះរាជាធិបតីដោយមានក្រុមយោធារក្សាព្រះអង្គនិងក្រុមភ្លេងជាតិចាំទទួលធ្វើការគោរពតាមទំនៀម ។ ក្នុងទី

សន្និបាតនោះ គេបានឃើញឥស្សរជនជាច្រើនដែលអញ្ជើញទៅជាកិត្តិយសគឺ ឯ. ឧ. ហ៊ុយ-កន្ធុល នាយករដ្ឋមន្ត្រី, ឯ. ឧ. ឃួន-ណៃ រដ្ឋមន្ត្រីក្រសួងធម្មការ, ឯ. ឧ. សឺន-សាន ប្រធានរដ្ឋសភា, អ្នកអង្គម្ចាស់ នរោត្តម ម៉ុងតាណា ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ, លោកអលខត ចាងហ្វាងក្រុមឃោសនាការអាមេរិកាំងនៅភ្នំពេញ ហើយនឹងអស់លោកនាម៉ឺនមុខមន្ត្រីឯទៀតជាច្រើនដែលសមាគមសូមអភ័យទោស ដោយពុំបានបញ្ចេញនាមក្នុងទីនេះ ។ បន្ទាប់មក, មានសុន្ទរកថា ៣ លើក ឆ្លើយឆ្លងជាប់តៗគ្នាពណ៌នាអំពីកល្យាណកិច្ចនេះ ជាសេចក្តីថ្លែងនៃលោកប៉ាយ-ប៊ុក អធិបតីសមាគម, ព្រះតេជព្រះគុណចាងហ្វាងសាលាបាលីជាន់ខ្ពស់ ដែលមានព្រះមហាព្រហ្មមុនី ទេព-អ៊ូ ចាងហ្វាងរងទទួលការថ្លែងជួស) នឹង ឯ. ឧ. ឃួន-ណៃ រដ្ឋមន្ត្រីក្រសួងធម្មការ ។

បន្ទាប់មកទៀត, មានការប្រគេនព្រហ្មទានដល់សិស្សទាំង ៩៧ រូប ។ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់បានព្រះរាជទានព្រះរាជទ្រព្យផ្ទាល់ព្រះអង្គចំនួន ២.០០០ រៀល បំពោះពិធីបុណ្យនេះ ក៏ទ្រង់បានប្រគេនផ្ទាល់ព្រះហស្ត នូវព្រហ្មទានទី ១ ដល់សិស្សដែលប្រឡងជាប់លេខខ្ពស់ជាងគេ, រួចហើយ ឥស្សរជនឯទៀតៗ ព្រមទាំងពុទ្ធបរិស័ទទាំងឡាយក៏បានប្រគេនព្រហ្មទានរបស់ខ្លួនៗដល់សិស្សដែលប្រឡងជាប់លេខបន្ទាប់ៗ គ្នាជាលំដាប់ដរាបដល់ទីបំផុត ។

កាលរួចកិច្ចប្រគេនហើយ, ព្រះមហាក្សត្រទ្រង់បានថ្វាយព្រះរាជសុន្ទរកថាទទួលព្រះរាជអំណរគុណការកុសលនេះ ៗ លុះចប់ព្រះរាជសុន្ទរកថាហើយព្រះសង្ឃជាសិស្សទាំងនោះ ទទួលអនុមោទនាដោយមន្តលគាថាទាំងពួង ៗ រួចហើយ ពុទ្ធសាសនិកជនទាំងឡាយដែលមានព្រះរាជាជាប្រមុខក៏បានស្លូត្របត្តិទានគាថាឧទ្ទិសបំណែកផលជាកិច្ចបង្ហើយបុណ្យ ៗ តទៅខាងក្រោយនេះ, យើងសូមចុះផ្សាយនូវសុន្ទរកថាទាំងនោះ ៗ

## សុន្ទរកថា

### នៃលោកអធិបតី

សូមព្រះតេជៈគុណលើត្បូង

សូមព្រះរាជទាន ព្រះបរមរាជវរោកាសក្រាបបង្គំទូលថ្វាយ ព្រះករុណា ជាអម្ចាស់ជីវិត សូមទ្រង់ជ្រាប

ក្រោមលម្អងធូលីព្រះបាទ ៗ

- សូមថ្វាយបង្គំសម្តេច នឹងព្រះថេរានុត្ថេរៈ ទាំងឡាយ,
- សូមក្រាបទូលទ្រង់,
- សូមជំរាបឯកឧត្តម លោកស្រី នឹងលោកអ្នកទាំងឡាយ,

លើកនេះជាលំដាប់ទី ៣ ដែលសមាគមមិត្តសាលាបាលីបានប្រឹងប្រែងដោយពេញកំឡាំង ដើម្បីរក្សាពិធីចែកព្រហ្មទានដល់សិស្សសាលាបាលីជាន់ខ្ពស់ដែលបានប្រឡងជាប់សញ្ញាប័ត្រ ទុកជាប្រពៃណី

ដីថៃថ្លាតទៅអនាគត ដោយយល់ថាជាវិធីដ៏វិសេសមួយសំរាប់ញុំាងសេចក្តីជ្រះថ្លា ឲ្យកាន់តែមុតមាំឡើងក្នុងព្រះពុទ្ធសាសនា ដែលជាកេរ្តិ៍មត៌កដ៏ប្រសើរនៃបុព្វបុរសរបស់យើង ហើយជាសាសនានៃសន្តិសុខដែលមនុស្សសត្វទាំងឡាយតែងត្រូវការទូទៅ ។ មិនតែប៉ុណ្ណោះសោត ពិធីនេះជាកិច្ចសម្រាប់បង្រួបបង្រួមសាមគ្គី រវាងពុទ្ធសាសនិកជនឲ្យជិតស្និទ្ធជាប់លាប់ឋិតថេរឡើងទៀតផង ។ ឯពិធីចែកព្រហ្មទាននេះ សមាគមពុំបានជាអ្នកផ្តើមធ្វើឡើងមុនគេទេ គ្រាន់តែបានលើកយកគ្រឿងដំណែលដ៏ប្រពៃនេះមកកាន់តាមប៉ុណ្ណោះ ព្រោះពិធីនេះមានធ្វើតាំងពីពេលមុនកើតសាលាបាលីជាន់ខ្ពស់ម៉្លេះ ដែលជំនាន់ការសិក្សាព្រះបរិយត្តិធម៌នៅក្នុងវត្តព្រះវិហារព្រះកែវមរកត ។ កាលនោះ សិស្សដែលដេញប្រយោគជាប់ជាមហា ៣ ប្រយោគ និង ៤ ប្រយោគ តែងបានទទួលព្រះរាជទ្រព្យរង្វាន់អំពីព្រះករុណាជាអម្ចាស់ជីវិត មានផ្ទិតនឹងត្រៃចីវរជាដើម ហើយក្នុងជំនាន់នោះ បំណេះវិជ្ជាខាងព្រះពុទ្ធសាសនា គេលើកជាបំណេះវិជ្ជាជាន់ខ្ពស់ក្នុងប្រទេស ។ លំដាប់តមក អតីតពុទ្ធិកសមាគមនឹងក្រុមពុទ្ធសាសនបណ្ឌិត្យ បានបំពេញកិច្ចនេះបានតែ ១ លើកក្នុងឆ្នាំ ១៩៤២ ។ ឯសមាគមមិត្តសាលាបាលី ទើបនឹងបានចាប់ធ្វើពិធីនេះឡើងវិញពីឆ្នាំ ១៩៥០ មក ។

(មានត)

ទស្សនាវដ្ដីនេះ ល្អឥតក្ចឹង
ដោយផ្សាយដំណឹង ជា ២ ផ្នែក:

១- ខាងពុទ្ធសាសន៍ យ៉ាងល្អឯក;

២- ខាងចំណែក អក្សរសាស្ត្រ ៗ

លោកអ្នកបើបាន អានសិក្សា
មេត្តាកុំភ្លេច ជួយប្រកាស
ប្រាប់គេឲ្យជាវ ច្រើនដេរដាស
ជួយពុទ្ធសាសន៍, អក្សរខ្មែរ!

ថ្លៃជាវប្រចាំឆ្នាំ:

ក្នុងកម្ពុជរដ្ឋ .............១២០រ,០០
ក្រៅកម្ពុជរដ្ឋ .............១៥០,០០